ការិយាល័យឧត្តមស្នងការ
អង្គការសហប្រជាជាតិទទួល
បន្ទុកសិទ្ធិមនុស្ស



# លិខិតុបករណ៍នីតិរដ្ឋ សម្រាប់បណ្តារដ្ឋទាំងឡាយ ក្រោយបរិបទជម្លោះ

## *ការបង្កើនឲ្យបានជាអតិបរមានូវកេរ្តិ៍ដំណែល របស់តុលាការកូនកាត់*

អង្គការសហប្រជាជាតិ

ការិយាល័យឧត្តមស្នងការ
អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស

# លិខិតុបករណ៍នីតរដ្ឋ
# សម្រាប់បណ្តារដ្ឋទាំងឡាយក្រោយបរិបទជម្លោះ

## ការបង្កើនឲ្យបានជាអតបរមានូវកេរ្តិ៍ដំណែល
## របស់តុលាការកូនកាត់

អង្គការសហប្រជាជាតិ
ទីក្រុងញូវយ៉ក និងហ្សឺណែវ ២០០៨

## កំណត់

ការតាក់តែង ដែលបានដាក់ឲ្យប្រើប្រាស់ និងការរៀបចំឯកសារក្នុងការបោះពុម្ពផ្សាយនេះ មិនឆ្លុះបញ្ចាំងនូវការសំដែងមតិណាមួយទៅលើផ្នែកណាមួយរបស់អគ្គលេខាធិការដ្ឋាន នៃសហប្រជាជាតិ ដែលទាក់ទងនឹងឋានៈផ្លូវច្បាប់របស់ប្រទេស ដែនដី ទីក្រុងឬ តំបន់ណាមួយ ឬក៏របស់អាជ្ញាធររបស់គេ ឬ ទាក់ទងនឹងការកំណត់ព្រំដែននៃដែនដីរបស់គេឡើយ។

*

ឯកសារបោះពុម្ពផ្សាយនេះអាចដកស្រង់ ឬបោះពុម្ពឡើងវិញបានដោយសេរី ល្គឹះណាការទុកចិត្តត្រូវបានធានា ហើយនិងឯកសារបោះពុម្ពឡើងវិញមួយច្បាប់ត្រូវផ្ញើមកកាន់ការិយាល័យឧត្តមស្នងការ អង្គការសហប្រជាជាតិ ដែលមានអាស័យដ្ឋាននៅវិមានប្រជាជាតិ រុក្ខវិថីសន្តិភាព ៨១-៤ ជៈ-១២១១ ហ្សឺណែវ ប្រទេសស្វ៊ីស។

**HR/PUB/08/2**

UNITED NATIONS PUBLICATION
*Sales No. E.08.XIV.2*
ISBN 978-92-1-154182-3

*ការបោះពុម្ពផ្សាយនេះត្រូវបានបកប្រែជាភាសាខ្មែរដោយការិយាល័យ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស-ការិយាល័យប្រចាំប្រទេសកម្ពុជា ខែកញ្ញា ឆ្នាំ២០១២*

# មាតិកា


បុព្វកថា ........ v

សេចក្តីផ្តើម ........ 1

I. **បញ្ហាជាបឋម ........ 5**

ក. សារតារ ........ 5

ខ. និយមន័យនៃកេរ្តិ៍ដំណែល ........ 8

គ. វិសាលភាព ........ 10

II. **ការពិចារណាជាបឋម ........ 14**

ក. អាណត្តិ ........ 14

ខ. ផែនការ ........ 17

គ. ភាពម្ចាស់ការ ........ 19

ឃ. ដៃគូការងារ ........ 21

ង. រចនាសម្ព័ន្ធ ........ 23

ច. ការចៀសវាងនូវកេរ្តិ៍ដំណែល "អវិជ្ជមាន" ........ 29

ឆ. ទំនាក់ទំនងរវាងកេរ្តិ៍ដំណែល និងយុទ្ធសាស្រ្តបញ្ចប់ ........ 32

III. **ការអនុវត្តន៍កេរ្តិ៍ដំណែល៖ ការលើកកម្ពស់វប្បធម៌នីតិរដ្ឋ និងសិទ្ធិមនុស្ស ........ 33**

ក. "ផលនិទស្សន៍"៖ ផលប៉ះពាល់លើវប្បធម៌នីតិរដ្ឋ ........ 33

ខ. កម្មវិធីផ្សព្វផ្សាយដល់សហគមន៍ និងព័ត៌មានសាធារណៈ ........ 36

គ. ការអភិវឌ្ឍន៍សង្គមស៊ីវិលក្នុងស្រុក ........ 39

IV. **កេរ្តិ៍ដំណែល៖ ការអភិវឌ្ឍន៍ធនធានមនុស្ស និងវិជ្ជាជីវៈ ........ 41**

ក. ការជ្រើសរើសបុគ្គលិក ........ 41

ខ. ការអភិវឌ្ឍន៍វិជ្ជាជីវៈ ........ 50

V. ហេដ្ឋារចនាសម្ព័ន្ធជាក់ស្តែង ឬសម្ភារៈជាក់ស្តែងចាត់ទុកជាកេរ្តិ៍ដំណែល. .......... 62

VI. កំណែទម្រង់ច្បាប់ចាត់ទុកជាកេរ្តិ៍ដំណែល .......... 65

ក. ការរួមវិភាគទានរបស់តុលាការកូនកាត់ចំពោះកំណែទម្រង់ច្បាប់ .......... 65

ខ. ផលប៉ះពាល់នៃករណីយុទ្ធសាស្ត្រ .......... 69

សេចក្តីសន្និដ្ឋាន .......... 71

ឧបសម្ព័ន្ធ .......... 73

# បុព្វកថា

ការិយាល័យឧត្តមស្នងការ អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជាមានក្តីសោមនស្ស ដើម្បីប្រកាសដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវសំណៅជាភាសាខ្មែរ ស្តីពីលិខិតុបករណ៍គោលនយោបាយរបស់ខ្លួន "*ការបង្កើនឲ្យបានជាអតិបរមានូវកេរ្តិ៍ដំណែល របស់តុលាការកូនកាត់*"។ ជាមួយនឹងការផលិតក្នុងការបោះពុម្ពផ្សាយនេះ យើងសង្ឃឹមថា នឹងជួយជ្រោមជ្រែងដល់រាជរដ្ឋាភិបាលកម្ពុជា ស្ថាប័នតុលាការ មេធាវី ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល ដើម្បីទទួលបាននូវអត្ថប្រយោជន៍ដ៏ពេញលេញ ពីឱកាស ដែលបង្កើតឡើងដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) និងជួយធានាថា តុលាការនេះបន្សល់ទុកនូវកេរ្តិ៍ដំណែលវិជ្ជមាន ដល់ប្រព័ន្ធយុត្តិធម៌កម្ពុជា ដោយការលើកកម្ពស់ការគោរពសិទ្ធិមនុស្ស។

មកដល់បច្ចុប្បន្ននេះ អន្តរកាលរបស់ប្រទេសកម្ពុជា ស្តីពីប្រជាធិបតេយ្យបានដើរលើផ្លូវអស់រយៈពេលជាង២ទស្សវត្សរ៍ហើយ ចាប់តាំងពី*កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស* ត្រូវបានចុះហត្ថលេខា កាលពីថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១។ កិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសនេះ ដើម្បីដាក់ឲ្យមានការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនានា ដែលបានប្រព្រឹត្តឡើងក្នុងអំឡុងនៃរបបខ្មែរក្រហម (ថ្ងៃទី១៧ ខែ មេសា ឆ្នាំ១៩៧៥-ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩) អូសបន្លាយអស់រយៈពេលជិតសាមសិបឆ្នាំ បន្ទាប់ពីរបបនេះត្រូវបានបង្ខំឲ្យចេញពីអំណាច និងបន្ទាប់ពីមានកិច្ចចរចារ ដ៏អូសបន្លាយយ៉ាងយូររវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងអង្គការសហប្រជាជាតិ។ ដូច្នេះ ដំណើរការយុត្តិធម៌របស់ អ.វ.ត.ក ត្រូវបានបង្កើតឡើងនៅពេលមួយ នៅពេលដែលអង្គការសហប្រជាជាតិ និងជំនួយដៃគូ អភិវឌ្ឍន៍សម្រាប់ប្រទេសត្រូវបានបង្កើត

ឡើងយ៉ាងរលូន ហើយប្រទេសកម្ពុជា ដោយផ្ទាល់ក៏ទទួលបាននូវស្ថិរភាពជាបណ្ដើរៗដែរ។

ជាលទ្ធផល អ.វ.ត.ក គឺជាតុលាការកម្ពុជា ដែលប្រើប្រាស់បុគ្គលិកកម្ពុជាលើសលុប ដែលទទួលបានផលប្រយោជន៍ពីជំនួយរបស់អង្គការសហប្រជាជាតិ ដែលខុសគ្នាពីតុលាការកូនកាត់ផ្សេងៗទៀត ដែលបានពឹងផ្អែកយ៉ាងខ្លាំងលើការប្រើប្រាស់បុគ្គលិកអន្តរជាតិ ដើម្បីសម្រេចបាននូវដំណើរការជំនុំជម្រះក្ដី។ ពេលខ្លះ ថ្វីបើបញ្ហានេះមានន័យថាសមត្ថភាពរបស់តុលាការ ដើម្បីបំពេញបាននូវបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិបានចោទជាសំណួរក៏ដោយ ក៏តុលាការនេះបានផ្ដល់នូវមធ្យោបាយ ដ៏សំខាន់ក្នុងការធានាកិច្ចខិតខំប្រឹងប្រែងកំពុងដំណើរការ ស្ដីពីការបង្កើតនីតិរដ្ឋ នៅប្រទេសកម្ពុជា ដោយធ្វើការធានាអំពីភាពជាម្ចាស់ការ ក្នុងស្រុកស្ដីពីដំណើរការ និងផ្ដល់ឱកាសដល់មន្ត្រីតុលាការ ច្បាប់ និងវិជ្ជាជីវៈ ដើម្បីបំពេញការងាររួមគ្នាជាមួយសហការីអន្តរជាតិ ដើម្បីផ្លាស់ប្ដូរបទពិសោធន៍ និងធានាឲ្យមានគណនេយ្យភាព ចំពោះអំពើឃោរឃៅកាលពីអតីតកាល។ ឋានៈរបស់តុលាការក្នុង *ស្ថានភាពបច្ចុប្បន្ន* ក៏បានធ្វើឲ្យប្រសើរឡើងនូវលទ្ធភាពសម្រាប់ការពិគ្រោះយោបល់ជាសាធារណៈអំពីកិច្ចដំណើរការនីតិវិធី។ ការពិភាក្សាអំពីសិទ្ធិរបស់ជនជាប់ចោទ និងផលប្រយោជន៍របស់ជនរងគ្រោះ ដែលអាចចូលរួមជាលើកដំបូងក្នុងដំណើរការយុត្តិធម៌ របស់តុលាការមានចរិកជាអន្តរជាតិ ដែលបានជួយ បង្កើនសេចក្ដីត្រូវការយុត្តិធម៌ក្នុងស្រុក។ លើសពីនេះទៀត កិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក បានគាំទ្រដល់កិច្ចសន្ទនាថ្នាក់តំបន់ និងថ្នាក់ជាតិ អំពីអ្វីបានកើតមានឡើងក្នុងអំឡុងពេលរបបខ្មែរក្រហម ហើយជាពិសេស បានធ្វើឲ្យយុវជនកម្ពុជាបានដឹងឮ កាលពីពេលថ្មីៗបំផុតនូវអ្វីៗកើតមានឡើងជាទំព័រប្រវត្តិសាស្ត្រ នៅប្រទេសកម្ពុជា ដែលក្នុងនោះមាន

ប្រជាពលរដ្ឋកម្ពុជា ដ៏តិចតួចបំផុតមានអារម្មណ៍ និយាយបើកចំហរដោយសុវត្ថិភាព។

លិខិតុបករណ៍គោលនយោបាយនេះបានដាក់បទពិសោធន៍ របស់កម្ពុជាក្នុងទស្សនៈវិស័យអន្តរជាតិ។ ក្នុងការធ្វើដូច្នេះ លិខិតុបករណ៍នេះខិតខំប្រឹងប្រែង ដើម្បីផ្តល់នូវទស្សនៈស៊ីជម្រៅស្តីពីបរិបទកម្ពុជា ពីបទពិសោធន៍របស់ប្រទេសផ្សេងៗ និងលើកទឹកចិត្តឲ្យមានការពិចារណានៅប្រទេសកម្ពុជា អំពី "បទពិសោធន៍" ពីប្រទេសផ្សេងៗទាំងនោះ។ លិខិតុបករណ៍នេះក៏ផ្តល់នូវមគ្គុទ្ទេសដល់ប្រជាពលរដ្ឋកម្ពុជាផងដែរ ក្នុងវិធីដ៏ប្រសើរបំផុត ដើម្បីអាស្រ័យលើសន្ទុះ ដែលបានបង្កើតឡើងដោយអ.វ.ត.ក ក្នុងការលើកកម្ពស់ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌរបស់ប្រទេសកម្ពុជា។ យើងសង្ឃឹមថា ការបោះពុម្ពផ្សាយនេះនឹងជួយដល់ដៃគូការងារផ្សេងៗ ដើម្បីចូលរួមយ៉ាងទូលំទូលាយ និងស៊ីជម្រៅក្នុងការធ្វើឲ្យការប្រើប្រាស់អាចដំណើរការទៅបាន ក្នុងវិធីដ៏ប្រសើរបំផុត នៃព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រ ដែលបង្កើតឡើងដោយ អ.វ.ត.ក និងដើម្បីធានាថា តុលាការនេះត្រូវបានគេចងចាំថា ជាស្ថាប័នមួយ ដែលចារជាព្រឹត្តិការណ៍ដ៏មានសារៈសំខាន់លើវិថីរបស់ប្រទេសកម្ពុជា ឆ្ពោះទៅកាន់ប្រជាធិបតេយ្យសម្រាប់មនុស្សជំនាន់ក្រោយៗទៀត។

*ការិយាល័យឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា*

# បុព្វកថា

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ដែលជាស្ថាប័ននាំមុខ នៃប្រព័ន្ធសហប្រជាជាតិ ស្តីពីយុត្តិធម៌អន្តរកាលបានបើកឲ្យដំណើរការនូវផ្នែកទី២ នៃឈុតសៀវភៅរបស់ខ្លួន ស្តីពីលិខិតុបករណ៍យុត្តិធម៌អន្តរកាល សម្រាប់រដ្ឋទាំងឡាយក្រោយជម្លោះ ស្របពេលជាមួយនឹងការបោះពុម្ពផ្សាយសៀវភៅមួយ ដែលមានចំណងជើងថា *"ការបង្កើនឲ្យបានជាអតិបរមា នូវកេរ្តិ៍ដំណែលរបស់តុលាការកូនកាត់ និងកម្មវិធីសំណង"*។ ការបោះពុម្ពផ្សាយទាំងនេះមានបំណងជួយអភិវឌ្ឍសមត្ថភាពស្ថាប័ន ប្រកបដោយនិរន្តរភាព ក្នុងរង្វង់នៃបេសកកម្មរបស់សហប្រជាជាតិ ក៏ដូចជាជួយជ្រោមជ្រែងដល់រដ្ឋបាលអន្តរកាល និងសង្គមស៊ីវិល ដើម្បីបំពេញការងារប្រកបដោយទេពកោសល្យកាន់តែប្រសើរនៅក្នុងការឆ្លើយតបរបស់គេទៅនឹងសេចក្តីត្រូវការនៃយុត្តិធម៌អន្តរកាល។

ជាញឹកញាប់ ប្រទេសទាំងឡាយ ដែលទើបតែងើបចេញពីជម្លោះ ទទួលរងនូវភាពខ្សោយ ឬអនត្ថិភាពនៃនីតិរដ្ឋ ការប្រតិបត្តិច្បាប់មិនគ្រប់គ្រាន់ សមត្ថភាពមិនគ្រប់គ្រាន់ ក្នុងប្រព័ន្ធរដ្ឋបាលយុត្តិធម៌ និងការកើនឡើងនូវករណីរំលោភបំពានលើសិទ្ធិមនុស្សជាច្រើន។ ជានិច្ចជាកាល ស្ថានភាពនេះ គឺកាន់តែធ្ងន់ធ្ងរឡើងៗ ដោយសារតែកង្វះទំនុកចិត្តពីសាធារណជនចំពោះអាជ្ញាធររដ្ឋទាំងឡាយ និងកង្វះធនធាននានា។

តុលាការកូនកាត់អាចផ្តល់លទ្ធផលវិជ្ជមាន ទៅលើប្រព័ន្ធយុត្តិធម៌ក្នុងស្រុក នៃបណ្តារដ្ឋទាំងឡាយក្រោយដំណាក់កាលជម្លោះ ដើម្បីធានាឲ្យបាននូវកេរ្តិ៍ដំណែលដ៏យូរអង្វែង សម្រាប់នីតិរដ្ឋ និងការគោរពសិទ្ធិមនុស្ស។ លើសពីនេះទៀត *"ការបង្កើនឲ្យបានជាអតិបរមានូវកេរ្តិ៍ដំណែលរបស់*

*តុលាការកូនកាត់"* រិះរកវិធីសាស្ត្រ ដែលតុលាការកូនកាត់អាចទទួលបាននូវអាណត្តិ និងការគាំទ្រផ្នែកនយោបាយ ដែលចាំបាច់កាន់តែមានប្រសិទ្ធភាពថែមទៀត ក្នុងការកសាងសមត្ថភាព និងការទុកដាក់នូវកេរ្តិ៍ដំណែលដ៏ស្ថិតស្ថេរសម្រាប់ប្រព័ន្ធយុត្តិធម៌។ បទដ្ឋានសិទ្ធិមនុស្សអន្តរជាតិដ៏រឹងមាំ និងពោរពេញដោយការអនុវត្តន៍ ដ៏ល្អបំផុតនោះគឺ *"ការបង្កើនឲ្យបានជាអតិបរមានូវកេរ្តិ៍ដំណែលរបស់តុលាការកូនកាត់"* ដែលបានផ្តល់នូវព័ត៌មានដ៏មានសារសំខាន់ ដែលត្រូវចាំបាច់ចំពោះបទអន្តរាគមន៍ដល់ក្រុមគោលដៅណាមួយ ជាពិសេស ចំពោះតុលាការកូនកាត់ ក៏ដូចជាកំណែទម្រង់ប្រព័ន្ធច្បាប់ទូទៅក្នុងស្រុក។ គោលបំណងរបស់តុលាការនេះ គឺមិនមែនដាក់បញ្ញាឲ្យអនុវត្តតាមការធ្វើសេចក្តីសម្រេចចិត្តផ្នែកយុត្តិសាស្ត្រ និងកម្មវិធីនោះទេ ដោយសារតែបញ្ហានេះត្រូវតែយកលំនាំតាមវិស័យណាមួយ ដែលជាការឆ្លើយតបដ៏សមស្របទៅនឹងកាលៈទេសៈ និងបរិយាកាសជាក់លាក់។

*"ការបង្កើនឲ្យបានជាអតិបរមានូវកេរ្តិ៍ដំណែលរបស់តុលាការកូនកាត់"* គឺជាការបោះពុម្ពផ្សាយរួមគ្នាមួយជាមួយនឹង*កម្មវិធីសំណាង* ដោយផ្អែកលើឈុតសៀវភៅរបស់យើងកាលពីឆ្នាំ២០០៦ ជារួមមានការរៀបចំផែនការក្នុងវិស័យយុត្តិធម៌ ការផ្តួចផ្តើមគំនិតរបស់អយ្យការ គណៈកម្មាការស្វែងរកការពិត ការវាយតម្លៃ និងការឃ្លាំមើលប្រព័ន្ធច្បាប់។ លិខិតុបករណ៍ឈុតសៀវភៅនីមួយៗ អាចទ្រទ្រង់ដោយខ្លួនឯងបាន ប៉ុន្តែក៏សមស្របទៅនឹងទស្សនទានប្រតិបត្តិការប្រទាក់ក្រឡាគ្នាផងដែរ។ ជាបឋម គោលការណ៍ដែលត្រូវប្រើប្រាស់ ក្នុងលិខិតុបករណ៍ទាំងនេះ ត្រូវបានប្រមូលពីបទពិសោធន៍មុនៗ និងបទពិសោធន៍ក្នុងកិច្ចប្រតិបត្តិការរបស់សហប្រជាជាតិ។

ការិយាល័យ OHCHR នឹងបន្តធ្វើការតាក់តែងលិខិតុបករណ៍នីតិរដ្ឋទាំងឡាយបន្ថែមទៀត ស្របពេលជាមួយនឹងការចូលរួមពាក់ព័ន្ធ នៅក្នុង

ការអភិវឌ្ឍន៍គោលនយោបាយយុត្តិធម៌អន្តរកាល ហើយនិងក្នុងការឆ្លើយតបតាមសំណើពីប្រព័ន្ធសហប្រជាជាតិទាំងឡាយ ជាពិសេស វត្តមានរបស់កា-រិយាល័យនៅតាមតំបន់ ក៏ដូចជាបណ្ដាដៃគូផ្សេងៗទៀតដែរ។

ខ្ញុំសូមឆ្លៀតឱកាសនេះ សំដែងនូវការដឹងគុណរបស់ខ្ញុំ ចំពោះការផ្តល់មតិយោបល់នានា ដែលបានទទួលពីដៃគូការងាររបស់យើងមកដល់ពេលនេះ និងកតវេទិតារបស់ខ្ញុំចំពោះអ្នកទាំងឡាយដែលបានរួមវិភាគទានចំពោះការផ្តួចផ្តើមគំនិតដ៏មានសារសំខាន់នេះ។



ល្វិស អាប៊ួរ

ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស

# ការទទួលស្គាល់

ការិយាល័យ OHCHR សូមថ្លែងអំណរគុណចំពោះបុគ្គល និងអង្គ-ការទាំងឡាយ ដែលបានផ្តល់នូវមតិ-យោបល់ និងកិច្ចគាំទ្រក្នុងការរៀបចំលិខិតុបករណ៍នេះ។ ជាពិសេស ការិយាល័យនេះសូមទទួលស្គាល់នូវស្នាដៃរបស់អ្នកផ្តល់ប្រឹក្សា ដែលបានទទួលខុសត្រូវជាបឋម ក្នុងការតាក់តែងលិខិតុបករណ៍នេះ គឺលោក Marieke Wierda ។ ការិយាល័យ OHCHR ក៏សូមទទួលស្គាល់ផងដែរ ចំពោះមជ្ឈមណ្ឌលអន្តរជាតិសំរាប់យុត្តិធម៌អន្តរកាល ដែលបានផ្តល់កិច្ចគាំទ្រដ៏មានសារសំខាន់ដល់អ្នកប្រឹក្សាយោបល់។

# សេចក្តីផ្តើម

តុលាការកូនកាត់ត្រូវបានផ្តល់និយមន័យថា ជាតុលាការដែលមានសមាសភាព និងយុត្តាធិការចម្រុះ ដែលគ្របដណ្តប់ទាំងទិដ្ឋភាពជាតិ និងអន្តរជាតិ ដែលតាមធម្មតា ត្រូវប្រតិបត្តិការនៅក្នុងរង្វង់យុត្តាធិការ ដែលបទឧក្រិដ្ឋនានាត្រូវបានប្រព្រឹត្តឡើង។ លិខិតុបករណ៍គោលនយោបាយនីតិរដ្ឋមានទិសដៅបំរើនូវគោលបំណង២៖ ទី១ ខិតខំស្វែងរកតុលាការកូនកាត់ណា ដែលផ្តល់លទ្ធផលវិជ្ជមានដ៏មានសក្តានុពល ដល់ប្រព័ន្ធយុត្តិធម៌ក្នុងស្រុកសំរាប់បណ្តារដ្ឋទាំងឡាយ នៅក្រោយបរិបទជម្លោះ ដើម្បីធានានូវកេរ្តិ៍ដំណែលដ៏យូរអង្វែងសម្រាប់នីតិរដ្ឋ និងការគោរពសិទ្ធិមនុស្ស និងទី២ ត្រូវពិនិត្យមើលអំពីវិធី ដែលតុលាការកូនកាត់ទទួលបាននូវអាណត្តិ និងកិច្ចគាំទ្រដ៏ចាំបាច់កាន់តែមានប្រសិទ្ធភាពថែមទៀត ក្នុងក្របខ័ណ្ឌកេរ្តិ៍ដំណែល និងការកសាងសមត្ថភាព។

ដោយការប្រើប្រាស់បទពិសោធន៍ ទទួលបានពីតុលាការកូនកាត់ដែលបានបង្កើតឡើងតាំងពីឆ្នាំ១៩៩៩ ការបោះពុម្ពផ្សាយនេះណែនាំអំពីគោលនយោបាយដ៏មានប្រសិទ្ធភាព និងអត្ថន័យ ដំណើរការ និងបច្ចេកទេសស្តីពីអន្តរទំនាក់ទំនងរវាងតុលាការកូនកាត់ និងតុលាការក្នុងស្រុក។ ការអនុវត្តន៍ ដែលណែនាំមកនេះនឹងលើកកម្ពស់ អំពីភាពគួរឲ្យទុកចិត្តបានប្រសិទ្ធភាព និងផលប៉ះពាល់ របស់តុលាការកូនកាត់លើស្ថេរភាពយូរអង្វែង និងកិច្ចអភិវឌ្ឍន៍ប្រព័ន្ធយុត្តិធម៌ក្នុងស្រុក ដោយរាប់ទាំងការគោរពដល់ការការពារសិទ្ធិមនុស្ស នីតិរដ្ឋ និងស្ថាប័នច្បាប់នានា។

ជាញឹកញាប់ តុលាការកូនកាត់ត្រូវបានគេបង្កើតឡើង ក្នុងវិធីមួយដែលមានតែជនជាប់ចោទមួយចំនួន ដែលគេស្គាល់ប៉ុណ្ណោះ ជាពិសេស គឺពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរ ដូចជាឧក្រិដ្ឋកម្មសង្គ្រាម ឬក៏ឧក្រិដ្ឋកម្មប្រឆាំង

មនុស្សជាតិដែលនឹងត្រូវប្រឈម ចំពោះមុខតុលាការកូនកាត់។ តាមទ្រឹស្តី ចុងចោទភាគច្រើនបំផុតនឹងត្រូវប្រឈមមុខនឹងយុត្តិធម៌ នៅចំពោះមុខប្រព័ន្ធយុត្តិធម៌ក្នុងស្រុក-គឺជាញឹកញាប់ ស្ថានភាព នៃប្រព័ន្ធយុត្តិធម៌នេះមិនទាន់បានរៀបចំខ្លួនឡើយ។ ក្នុងស្ថានភាពក្រោយជម្លោះ តុលាការក្នុងស្រុកតែងតែទទួលរងនូវបញ្ហាជាច្រើន ជារួមមានកង្វះខាតច្បាប់ អំពើពុករលួយតាមកន្លែង បញ្ហាអសមត្ថភាព លក្ខ័ណ្ឌសេវាកម្ម និងប្រាក់កម្រៃមានកម្រិតទាប មិនទទួលបានយុត្តិធម៌ ព្រមទាំងការទទួលបានតំណាងផ្លូវច្បាប់មិនគ្រប់គ្រាន់ និងតែតិចតួចប៉ុណ្ណោះ ហើយប្រសិន បើមានគឺការរាយការណ៍អំពីសំណុំរឿងផ្នែកច្បាប់ប៉ុណ្ណោះ។

ការបង្កើតតុលាការកូនកាត់នឹងមិនអាច ដោះស្រាយបញ្ហាទាំងអស់នេះបានទេ តែបើរៀបចំតាមបែបផែន និងពិចារណាតាមយុទ្ធសាស្ត្រ តាមរយៈអន្តរាគមន៍ ជាអន្តរជាតិបានកំណត់គោលដៅ ដែលតុលាការកូនកាត់តំណាងឲ្យអាចបន្សល់ទុក នូវអ្វីៗលើសពីការផ្តន្ទាទោស ការសម្រេចឲ្យរួចទោស និង "សាលតុលាការ" ទៅទៀត។ អន្តរាគមន៍ ដើម្បីបង្កើតតុលាការកូនកាត់បង្កើតបានជាឱកាសតែមួយគត់ ក្នុងក្របខ័ណ្ឌ នៃការយកចិត្តទុកដាក់របស់សហគមន៍អន្តរជាតិ ទាំងធនធាន និង កិច្ចខិតខំប្រឹងប្រែង និងជាឱកាសដ៏ខ្លីត្រូវបង្កើនឲ្យបានជាអតិបរមាក្នុងការប្រើប្រាស់ឱកាសនេះ។

កេរ្តិ៍ដំណែលត្រូវញែកឲ្យដាច់ពីផលប៉ះពាល់ផ្នែកសង្គមវិទ្យា ដែលថាការផ្តួចផ្តើមគំនិត របស់អយ្យការអាចលើសពេលវេលាកំណត់ឲ្យ។ ការវិភាគនៃផលប៉ះពាល់នេះត្រូវប្រគល់តួនាទី ដ៏ប្រសើរបំផុតនេះ ដល់អ្នកប្រវត្តិសាស្ត្រ និងអ្នកជំនាញផ្សេងៗ។ ទោះបីជា កេរ្តិ៍ដំណែលខុសប្លែកគ្នាពីកិច្ចប្រឹងប្រែងយ៉ាងទូលំទូលាយ ដើម្បីកសាងឡើងវិញនូវនីតិរដ្ឋ ក្នុងបរិបទពិសេសណាមួយដែលត្រូវចំណាយពេលវេលាច្រើនឆ្នាំក៏ដោយ ក៏កេរ្តិ៍ដំណែលនេះស្វះស្វែងរក

ជំនួយអន្តរជាតិ ដែលផ្តល់ឲ្យដោយតុលាការកូនកាត់ ក្នុងបរិបទទូលំទូលាយមួយ។ កេរ្តិ៍ដំណែលមានទិសដៅ ដើម្បីសម្រេចបានក្នុងការធ្វើឲ្យភាពចន្លោះប្រហោងកាន់តែតូច រវាងការប្រគល់អំណាច ក្នុងការចោទប្រកាន់អំពីឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរតែមួយចំនួនតែប៉ុណ្ណោះ ដែលបានកំណត់បន្ទាប់ពីលទ្ធផលភ្លាមៗ នៃជម្លោះតាមរយៈតុលាការកូនកាត់ និងជាញឹកញាប់ ការខ្វះការប្រគល់អំណាច នៃប្រព័ន្ធយុត្តិធម៌ក្នុងស្រុក ក្នុងបរិបទក្រោយជម្លោះកើតមានឡើង។ តុលាការកូនកាត់មិនត្រូវបានគេមើលឃើញថា ជាតុលាការ ដែលមានការចូលរួមដាច់ដោយឡែក ឬក៏ជាតុលាការបង្កើតបានជាជំហរមួយយ៉ាងឆាប់រហ័ស ក្នុងការដោះស្រាយអំពីបញ្ហាប្រឈមសំខាន់ៗ ក្នុងការកសាង ឬស្តារឡើងវិញនូវប្រព័ន្ធយុត្តិធម៌ ក្នុងបរិបទក្រោយជម្លោះឡើយ។ ផ្ទុយទៅវិញ តុលាការនេះត្រូវបានគេមើលឃើញថា ជាផ្នែកមួយនៃអន្តរាគមន៍ ដែលមានផ្នែកជាច្រើនចូលរួម ព្រមទាំងការបែងចែកធនធានត្រូវចំណាយដោយសមាមាត្រលើផ្នែកនីមួយៗ។

កេរ្តិ៍ដំណែលគឺជាទស្សនទានមានលក្ខណៈចង្អៀត និងអនុវត្តជាក់ស្តែងច្រើន៖ កេរ្តិ៍ដំណែលគម្បីត្រូវបានគេប្រើប្រាស់ ដើម្បីបង្កើតយុទ្ធសាស្ត្រដែលត្រូវបង្កើនឲ្យបានជាអតិបរមា នូវផលប៉ះពាល់ នៃយន្តការក្នុងការរៀបចំតាក់តែង និងប្រតិបត្តិការ។ ប្រព័ន្ធសហ្វវែរ (Software) ដែលបង្កើតបានជាផ្នែកមួយនៃកេរ្តិ៍ដំណែលដែរនោះ រាប់ទាំងគោលនយោបាយ និងដំណើរការដែលជួយធានាថា ប្រព័ន្ធយុត្តិធម៌ក្នុងស្រុកប្រតិបត្តិការការងារមានប្រសិទ្ធភាព និងប្រសិទ្ធិផលថែមទៀត ដោយស្របតាមកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់ខ្លួន។ បញ្ហានេះ រាប់ទាំងកំណែទម្រង់ក្របខ័ណ្ឌច្បាប់ជាសារវ័ន្ត ប៉ុន្តែមិនដាក់កំរិតចំពោះ ការអភិវឌ្ឍន៍វិជ្ជាជីវៈទេ (ឧទាហរណ៍ ជំនាញនៃការផ្លាស់ប្តូរគ្នារវាងវប្បធម៌ ឬវិធីនៃការគិតផ្សេងៗគ្នា) លើកកម្ពស់ការយល់ដឹងអំពីតួនាទីរបស់តុលាការជាស្ថាប័នឯករាជ្យ និងការប្រព្រឹត្តទៅដោយរលូននៃ

ស្ថាប័ននីតិរដ្ឋ ដែលប្រតិបត្តិការក្នុងក្របខ័ណ្ឌសិទ្ធិមនុស្ស ហើយត្រូវបានពិនិត្យពិច័យដោយសង្គមស៊ីវិល។

ទីបញ្ចប់ លិខិតុបករណ៍នេះមិនទាក់ទងជាមួយនឹងការពិចារណាអំពីកេរ្តិ៍ដំណែល ដែលទាក់ទងនឹងសាលាក្តីព្រហ្មទណ្ឌអន្តរជាតិ សម្រាប់អតីតប្រទេសយូហ្គូស្លាវី សាលាក្តីព្រហ្មទណ្ឌ អន្តរជាតិសម្រាប់ប្រទេសរ្វាន់ដា ឬតុលាការព្រហ្មទណ្ឌអន្តរជាតិទេ។ ស្ថានភាពនៃសាលាក្តីអន្តរជាតិត្រូវតែខុសគ្នាពីតុលាការកូនកាត់ ពីព្រោះថាជាទូទៅ តុលាការនេះតែងតែរៀបចំដំណើរការជំនុំជម្រះក្តីនៅបរទេស។ នេះមិនមែនមានន័យថា កេរ្តិ៍ដំណែលរបស់តុលាការនេះមិនទាក់ទងគ្នានោះទេះ តាមពិតទៅ បទពិសោធន៍ខាងក្រោមជាច្រើនត្រូវអនុវត្ត ព្រមទាំងកាន់តែប្រឈមច្រើនថែមទៀត សម្រាប់តុលាការអន្តរជាតិទាំងនោះ។ ទោះបីជាយ៉ាងណាក៏ដោយ ដោយសារតែតុលាការកូនកាត់ស្ថិតនៅក្នុងប្រទេសផ្ទាល់ វាមានសក្តានុពលច្រើន សម្រាប់កេរ្តិ៍ដំណែលជាងដំណើរការយុត្តិធម៌អន្តរជាតិយ៉ាងពិតប្រាកដ។

សូម្បីតែស្ថានភាព នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ក៏ត្រូវមានការលើកលែងច្រើនដែរ។ ក្នុងន័យទូលាយ របបនៃលក្ខន្តិកៈទីក្រុងរ៉ូម និងគោលការណ៍ នៃភាពបង្គ្រប់បានគូសបញ្ជាក់ថា តុលាការនេះនឹងផ្តល់លទ្ធ-ផលផ្ទាល់របស់ខ្លួនទៅដល់ប្រព័ន្ធច្បាប់ក្នុងស្រុក របស់រដ្ឋភាគី នៃលក្ខន្តិកៈទីក្រុងរ៉ូមតម្រូវឲ្យធ្វើវិសោធនកម្មច្បាប់ជាតិរបស់គេ ដើម្បីអនុវត្តនូវកាតព្វ-កិច្ចសន្ធិសញ្ញារបស់គេ។ លើសពីនេះទៀត ចំណាត់ការនៃតុលាការព្រហ្ម-ទណ្ឌអន្តរជាតិអាចទាំងប្រែក្លាយដំណើរការនានា ក្នុងស្រុក និងតុលាការអាចខិតខំប្រឹងប្រែងជាក់លាក់ ដើម្បីជួយជ្រោមជ្រែងយុត្តាធិការជាតិ។ ទោះបីជាយ៉ាងណាក៏ដោយ បញ្ហាទាំងនេះហួសពីវិសាលភាពនៃលិខិតុបករណ៍នេះ។

# I. បញ្ហាជាបឋម

## ក. សាវតារ

នាពេលថ្មីៗ តុលាការកូនកាត់បានចម្រើនលូតលាស់យ៉ាងត្រដែត ជាការអភិវឌ្ឍន៍គោលនយោបាយ ដ៏មានសារសំខាន់បំផុតមួយក្នុងដំណើរ-ការយុត្តិធម៌អន្តរកាល ដែលត្រូវបានបង្កើតឡើង ក្នុងកាលៈទេសៈផ្សេងៗដ៏ទូលំទូលាយ ដើម្បីឆ្លើយតបចំពោះសេចក្តីត្រូវការផ្សេងៗ។ អ្នកជំនាញអន្តរ-ជាតិ វិជ្ជាជីវៈច្បាប់ នៅកូសូវ៉ូ (សៀរបៀ) និងទីម័រខាងកើតត្រូវបានច្របាច់បញ្ចូលទៅក្នុងប្រព័ន្ធតុលាការក្នុងស្រុក ដោយរដ្ឋបាលរបស់សហប្រជាជាតិ ដើម្បីរកវិធីដោះស្រាយបញ្ហាប្រឈមនៃការជំនុំជម្រះរឿងក្តីឧក្រិដ្ឋ ដែលមានលក្ខណៈធ្ងន់ធ្ងរ និងសំណុំរឿង ដែលមានចរិកនយោបាយដ៏ស្មុកស្មាញ ប្រឆាំងនឹងសាវតារប្រព័ន្ធជាតិ ដែលមានលក្ខណៈទន់ខ្សោយក្រៃលែង។ តុលាការកូនកាត់ (ឬដំណើរការ) ត្រូវបានបង្កើតឡើងដោយបេសកម្មរបស់រដ្ឋ បាលបណ្តោះអាសន្ន សហប្រជាជាតិនៅខេត្តកូសូវ៉ូ (UNMIK) នៅឆ្នាំ ២០០០ (កម្មវិធីចៅក្រម និងព្រះរាជអាជ្ញាអន្តរជាតិ) និងដោយរដ្ឋបាលអន្តរ-កាលរបស់សហប្រជាជាតិនៅទីម័រខាងកើត (UNTAET) នៅឆ្នាំ២០០០ (អង្គភាពឧក្រិដ្ឋកម្ម កំរិតធ្ងន់ និងគណៈវិនិច្ឆ័យពិសេស សម្រាប់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរ)។ អង្គជំនុំជម្រះឧក្រិដ្ឋកម្មសង្គ្រាមពិសេសត្រូវបានបង្កើតឡើងនាឆ្នាំ ២០០៥ នៅបូស្នៀ និងហឺហ្សីហ្គូវីណា ដោយសារមានកិច្ចព្រមព្រៀងរវាងការិយាល័យរបស់តំណាងជាន់ខ្ពស់សាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិ សម្រាប់អតីតប្រទេសយូហ្គូស្លាវី និងអាជ្ញាធរជាតិ។

ក្នុងបរិបទផ្សេងៗទៀត សហប្រជាជាតិត្រូវបានអញ្ជើញដោយអាជ្ញាធរជាតិនានាដើម្បីបង្កើតសាលាក្តីកូនកាត់ក្នុងរង្វង់ដែនដីរបស់ខ្លួន។ ករណីនេះគឺកើតមាននៅប្រទេសសេរ៉ាឡេអូន ដែលតុលាការពិសេសសម្រាប់ប្រទេស

សេរ៉ាឡេអូនត្រូវបានបង្កើតឡើង ដោយកិច្ចព្រមព្រៀងរវាងសហប្រជាជាតិ និងរដ្ឋាភិបាលនៃប្រទេសសេរ៉ាឡេអូននាឆ្នាំ២០០២។ ស្រដៀងគ្នានេះដែរ អង្គការសហប្រជាជាតិ និងរដ្ឋាភិបាលនៃប្រទេសកម្ពុជា បានសម្រេចដំណើរ-ការចរចារដ៏យូរអង្វែង ហើយបានព្រមព្រៀងគ្នាបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នាឆ្នាំ២០០៣ ដើម្បីជំនុំជម្រះក្តីពួកខ្មែរក្រហម។ បច្ចុប្បន្ននេះកិច្ចចរចារកំពុងដំណើរការជាមួយរដ្ឋាភិបាលប៊ូរុនឌី និងដោយអនុលោមតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាលេខ ១៦៦៤ (២០០៦) ជាមួយរដ្ឋាភិបាលនៃប្រទេសលីបង់។

ហេតុផលដ៏សមស្រប ក្នុងការបង្កើតតុលាការកូនកាត់មានលក្ខណៈផ្សេងៗគ្នា ស្មុកស្មាញ និងអាស្រ័យដោយបរិបទជាតិ។ ហេតុផលមួយចំនួនដែលគេលើកជាញឹកញាប់មាន៖

- *ខ្វះសមត្ថភាព ឬធនធាននៅថ្នាក់ជាតិ៖* ជាញឹកញាប់ តុលាការកូន-កាត់ត្រូវបានបង្កើតឡើង ក្នុងកាលៈទេសៈ ដែលប្រព័ន្ធតុលាការក្នុងស្រុកមិនអាចលៃលកដោះស្រាយបញ្ហាបាន ដោយសារតែខ្វះសមត្ថភាពផ្នែកបច្ចេកទេស និងច្បាប់ ឬក៏ខ្វះខាតធនធានជាមូល-ដ្ឋានដើម្បីជំនុំជម្រះសំណុំរឿងឧក្រិដ្ឋកម្មនានា ទាំងពីអតីតកាល និងបច្ចុប្បន្ន ប្រកបដោយយុត្តិធម៌។ ជាលទ្ធផល អន្តរាគមន៍ចម្រុះមានគោលបំណងចែករំលែកកិច្ចប្រឹងប្រែង នៅក្នុងកាលៈទេសៈខ្លះ ដើម្បីកសាងឡើងវិញនូវសមត្ថភាពផ្នែកច្បាប់។ ឧទាហរណ៍ជំនួយអន្តរជាតិ គឺជាសមាសភាព នៃកិច្ចខិតខំប្រឹងប្រែងដ៏ទូលំ-ទូលាយ ដើម្បីដាក់ឲ្យប្រតិបត្តិការតុលាការឧក្រិដ្ឋកម្ម នៅទីម៉-ខាងកើត កូសូវ៉ូ និងបូស្នៀ និងហឺហ្សេហ្គូវីណា។ តុលាការកូន-កាត់ត្រូវបានបង្កើតឡើង ដើម្បីយកជ័យជំនះលើឧបសគ្គនានា

ក្នុងប្រព័ន្ធតុលាការក្នុងស្រុកផងដែរ ដូចជានិទោសកម្ម ឬអភ័យ-ឯកសិទ្ធិ ដែលមានអំណាចត្រួតត្រា ដោយការអនុវត្តន៍ច្បាប់អន្តរ-ជាតិផ្ទាល់ ឬដើម្បីធានាថា បទដ្ឋានយុត្តិធម៌អន្តរជាតិត្រូវបានគេអនុវត្ត។

- *ភាពលំអៀងដោយសារភ័យខ្លាចឬខ្វះឯករាជភាពក្នុងប្រព័ន្ធច្បាប់*៖ក្នុងកាលៈទេសៈខ្លះ សមាសធាតុអន្តរជាតិត្រូវបានបញ្ចូលក្នុងដំណើរការ ដើម្បីយកជ័យជំនះលើទស្សនៈ នៃភាពលំអៀង ឬក៏កង្វះឯករាជភាពក្នុងប្រព័ន្ធច្បាប់ ដែលអាចរារាំងដល់ការចោទប្រកាន់លើសំណុំរឿងទាំងឡាយយ៉ាងអង់អាច។ បញ្ហានេះ គឺជាកត្តាលើកទឹកចិត្ត ដើម្បីបង្កើតនូវសមត្ថភាពចម្រុះ ជារួមនៅអតីតប្រទេសយូកូស្លាវី ឬប្រទេសកម្ពុជា។ បញ្ហានេះក៏ត្រូវបានគេសន្មត់ផងដែរថា ចៅក្រម និងព្រះរាជអាជ្ញាអន្តរជាតិ ជាទូទៅនឹងងាយរងគ្រោះតិចតួច ចំពោះការគំរាមគំហែងផ្នែកសន្តិសុខ ឬនូវសម្ពាធនយោបាយ។

លើសពីនេះទៀត ភាពសមហេតុផល ដែលលើកមកសំអាងខាងលើ គឺជាបញ្ហាប្រឈម ដែលគេលើកមកសំអាងជាញឹកញាប់ ក្នុងការផ្តន្ទាទោសបទឧក្រិដ្ឋធ្ងន់ធ្ងរនានា។

- *ការរួមវិភាគទាន ចំពោះសិទ្ធិទទួលបាននូវយុត្តិធម៌ និងសំណងប្រកបដោយប្រសិទ្ធភាព*៖ តុលាការកូនកាត់ដើរតួនាទីស្នូលក្នុងការធានាថា ជនសង្ស័យទាំងឡាយ ដែលទទួលខុសត្រូវខាងព្រហ្មទណ្ឌត្រូវបានស៊ើបអង្កេត ផ្តន្ទាទោស និងដាក់ទណ្ឌកម្ម។

- *ការរួមវិភាគទាន ចំពោះការបញ្ជាប់នូវវប្បធម៌និទណ្ឌភាព*៖ តុលា-

ការកូនកាត់មានគោលបំណងជួយបញ្ចប់និទណ្ឌភាព ដោយការ-ធានាជាពិសេស ធ្វើការផ្តន្ទាទោសនូវមហាឧក្រិដ្ឋកម្ម។ ជាបន្ត-បន្ទាប់ វិធីបែបនេះអាចជួយដល់កិច្ចលើកកម្ពស់នីតិរដ្ឋ ជាពិសេសនៅកន្លែងណា ដែលនិទណ្ឌភាពគឺជាបុព្វហេតុដើមនៃជម្លោះ។ ការ-ស្តារឡើងវិញឲ្យមានការគោរពនីតិរដ្ឋ និងចង្អុលបង្ហាញឲ្យឃើញថា ឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ព្រមទាំងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ មិនត្រូវរួចពីការដាក់ទណ្ឌកម្ម ដែលត្រូវបានគេមើលឃើញថាជាមូលដ្ឋានគ្រឹះនៃសន្តិភាព ប្រកបដោយនិរន្តរភាព និងអន្តរកាលប្រជាធិបតេយ្យឡើយ។

- *ការរួមវិភាគទាន ចំពោះការផ្សះផ្សារជាតិ៖* មតិមួយចំនួនលើកឡើងថា ក្នុងបរិបទក្រោយជម្លោះ ដំណើរការជំនុំជម្រះត្រូវរួមវិភាគទានចំពោះការផ្សះផ្សារជាតិ។ កិច្ចពិភាក្សាដ៏ទូលំទូលាយស្តីពីបញ្ហានេះ មិនត្រូវបានពិនិត្យពិច័យបន្ថែមទៀតក្នុងឯកសារនេះឡើយ។

## ១. និយមន័យនៃកេរ្តិ៍ដំណែល

*ទស្សនទាន* នៃកេរ្តិ៍ដំណែលបានកើនឡើងនូវភាពលេចធ្លោ ដោយសារតែការបង្កើតតុលាការ និងសាលាក្តីកូនកាត់។ ក្នុងបរិបទនេះ កេរ្តិ៍ដំណែលត្រូវបានគេឲ្យនិយមន័យថា ជាផលប៉ះពាល់ដ៏យូរអង្វែង របស់តុលាការកូនកាត់ស្តីពីការលើកកម្ពស់នីតិរដ្ឋ នៅក្នុងសង្គមពិសេសណាមួយ ដោយការរៀបចំដំណើរការជំនុំជម្រះក្តី ដោយប្រសិទ្ធភាព ដើម្បីរួមវិភាគទានក្នុងការបញ្ចប់និទណ្ឌភាព ហើយនៅពេលជាមួយគ្នានេះ ក៏ធ្វើការពង្រឹងសមត្ថភាពតុលាការក្នុងស្រុកផងដែរ។ គោលបំណងគឺថា ផលប៉ះពាល់នេះត្រូវតែបន្តទៅទៀត ទោះបីជា បន្ទាប់ពីការងារតុលាការកូនកាត់បានបញ្ចប់ហើយ ក៏ដោយ។ ឥឡូវនេះសេចក្តីត្រូវការក្នុងការបន្សល់ទុក នូវកេរ្តិ៍ដំណែលមួយ គឺត្រូវទទួលយកដោយខកខានមិនបាន ជាផ្នែកមួយនៃគោលនយោបាយរបស់អង្គការសហ-

ប្រជាជាតិ។ ឧទាហរណ៍ លោកអគ្គលេខាធិការបានបញ្ជាក់ នៅក្នុងរបាយ-ការណ៍របស់លោកស្តីពីនីតិរដ្ឋ និងយុត្តិធម៌អន្តរកាល តាមបណ្តាសង្គមនានា ដែលស្ថិតក្នុងជម្លោះ និងក្រោយជម្លោះថា៖ ពីពេលនេះតទៅសាលាក្តីអន្តរជាតិ ឬសាលាក្តីកូនកាត់ណាមួយ ដែលនឹងបង្កើតឡើងនាពេលអនាគត គឺត្រូវតែពិចារណាជាអាទិភាពផងដែរ ពីយុត្តិសាស្រ្តក្នុងការទាញយកនូវផលចំណេញចុងក្រោយ និងក្នុងគោលបំណង នៃកេរ្តិ៍ដំណែល សម្រាប់ប្រទេសដែលពាក់ពន្ធ័ទាំងនោះ។

ដោយសារតែទស្សនទាន នៃកេរ្តិ៍ដំណែលផ្ទាល់ មិនត្រូវបានគេជំទាស់ជាពិសេស (យ៉ាងហោចណាស់ក្នុងក្របខ័ណ្ឌទ្រឹស្តី) បញ្ហាប្រឈមភាគច្រើនបំផុតគឺទាក់ទងនឹងវិសាលភាព និងការអនុវត្តន៍ ដូចគេបានយល់ដឹងស្រាប់អំពីប្រវត្តិ នៃតុលាការកូនកាត់ទាំងនេះ។ កត្តាជោគជ័យទាំងឡាយមានតិចតួច បើទោះជាមិនបរាជ័យទាំងស្រុងក៏ដោយ។ ការបញ្ចូលនូវសមត្ថ-ភាពចម្រុះយ៉ាងច្រើនជាអនេក ក្នុងការឆ្លើយតបទៅនឹងបញ្ហាប្រឈមភ្លាមៗ និងសេចក្តីត្រូវការជាក់ស្តែង គឺនៅកូសូវ៉ូ និងទីម័ខាងកើតជាច្រើន ដោយជំទាស់ទៅនឹងការចូលរួមជាផ្នែកមួយ នៃអន្តរាគមន៍អន្តរជាតិខាងយុត្តិសាស្រ្ត និងភាពយូរអង្វែង។ កិច្ចផ្តួចផ្តើមគំនិតផ្នែកកេរ្តិ៍ដំណែល នៅប្រទេសកម្ពុជា និងសេរ៉ាឡេអូនបានប្រឈមនឹងភាពស្មុកស្មាញ ខាងនយោបាយក្នុងការបញ្ចូលសមត្ថភាពអន្តរជាតិ ទៅក្នុងប្រព័ន្ធច្បាប់ក្នុងស្រុក ដែលមានស្រាប់។ កេរ្តិ៍ដំណែលត្រូវបានរំខានដោយសម្ពាធនានា ដើម្បីរៀបចំការជំនុំជម្រះក្តីក្នុងរង្វង់ពេលវេលាមួយដ៏ពិតប្រាកដ និងការបែងចែកធនធានក្នុងប្រទេសសេរ៉ាឡេអូន។ បញ្ហានេះនៅតែត្រូវបានគេមើលឃើញថា តើការបញ្ចូលបន្ថែមនូវសមាសភាពបុគ្គលិកអន្តរជាតិគ្រប់គ្រាន់ឬទេ ក្នុងការជំនះនឹងការជ្រៀត-ជ្រែកផ្នែកនយោបាយ ដែលមានភស្តុតាងក្នុងប្រព័ន្ធយុត្តិធម៌ក្នុងស្រុកនៅប្រទេសកម្ពុជា។

និទ្ទាការថ្មីៗនេះមានលក្ខណៈយុត្តិសាស្ត្រ តាមដែលអាចធ្វើទៅបាន ដោយសារតែអន្តរាគមន៍ពីមុនៗមក មិនមានលក្ខណៈយុត្តិសាស្ត្រទេនោះ ដើម្បីពង្រឹងរចនាសម្ព័ន្ធមានស្រាប់ និងពិចារណាអំពីនិរន្តរភាពរចនាសម្ព័ន្ធមានស្រាប់ទាំងនោះ។ វិធីសាស្ត្រនេះបានអនុវត្តនៅប្រទេសបូស្នៀ និងហើ្ស-ហ្សីហ្គូវីណា (Herzegovina) ហើយក៏ជាអ្វីដែលគេរំពឹងទុកថានឹងអនុវត្តនៅប្រទេសប៊ូរុនឌី។ គំរូ ដែលនឹងត្រូវបន្សល់ទុកនូវកេរ្តិ៍ដំណែលដ៏ល្អបំផុត ដែលភាគច្រើនពឹងផ្អែកលើបរិបទជាក់ស្តែង ហើយលិខិតុបករណ៍នេះនឹងព្យាយាមផ្តល់អនុសាសន៍ ស្តីពីយុត្តិសាស្ត្រជាក់លាក់មួយចំនួនដើម្បីបង្កើនកេរ្តិ៍ដំណែលនេះឲ្យបានជាអតិបរមា។

## គ. វិសាលភាព

បញ្ហានេះត្រូវចំណាយពេលវេលាច្រើនឆ្នាំ ដើម្បីបញ្ចប់ សូម្បីតែវគ្គបណ្តោះបណ្តាលច្បាប់ជាមូលដ្ឋាន ដែលសឹងតែកើតមានគ្រប់ប្រព័ន្ធច្បាប់ទាំង-អស់។ កំណែទម្រង់ប្រព័ន្ធតុលាការជាមូលដ្ឋាន ដែលដំណើរការមិនប្រក្រតី និងកសាងនូវវប្បធម៌មួយផ្នែកនីតិរដ្ឋ និងគោរពសិទ្ធិមនុស្សគឺជាគោលដៅដ៏យូរអង្វែងមួយ។ ដូច្នេះ ទោះបីជាព្រំដែន នៃទ្រឹស្តីបានប្រាកដចេញពីក្នុងរង្វង់នៃផលប៉ះពាល់ដ៏មានសក្តានុពល របស់តុលាការកូនកាត់ក៏ដោយ ក៏បញ្ហាសំខាន់ត្រូវមានការរំពឹងទុកដ៏ប្រាកដនិយម នៃកិច្ចប្រឹងប្រែងផ្នែកកេរ្តិ៍ដំ-ណែល។ ម្យ៉ាងវិញទៀត បញ្ហានេះក៏ងាយស្រួលធ្វើសេចក្តីសន្និដ្ឋានមួយដោយប្រៀបធៀបពីបទពិសោធន៍ ដែលកេរ្តិ៍ដំណែលត្រូវការចាំបាច់នូវយុត្តិ-សាស្ត្រមួយ ដែលនឹងមិនកើតឡើងដោយចៀសមិនផុតដោយស្វ័យប្រវត្តិ ឬដោយអាសារ័ណ។ ផ្ទុយទៅវិញ ការគូសបញ្ជាក់ច្រើនហួសហេតុពេកអំពីកេរ្តិ៍-ដំណែលអាចនាំមកនូវក្តីរំពឹងមិនប្រាកដនិយមឡើយ។ ភាគច្រើន តុលាការកូនកាត់តែងតែត្រូវបានកំណត់ជាមុន នូវអន្តរាគមន៍របស់ខ្លួន ដោយមាន

យុត្តាធិការពេលវេលា និងក្របខ័ណ្ឌពេលវេលាដ៏មានកំរិត ហើយស្ថិតក្រោមសម្ពាធ ដើម្បីកំណត់នូវព្រំដែន និងបញ្ចប់គោលបំណងរបស់គេគឺជាដំណើរ-ការជំនុំជម្រះក្តី ដែលមានលក្ខណៈស្មុកស្មាញ ជាជាងពង្រីកនូវអាណត្តិការ-ងាររបស់គេទេ។ ដូច្នេះ បញ្ហានេះនឹងមានសារសំខាន់ ដើម្បីគ្រប់គ្រងនូវក្តីរំពឹងនានាចំពោះកេរ្តិ៍ដំណែល។

នៅពេលជាមួយគ្នានេះដែរ កិច្ចប្រឹងប្រែងជាក់លាក់ និងបន្ថែមដែលបានកំណត់ជាមុនអាច ជួយបង្កើនឲ្យបានជាអតិបរមានូវផលប៉ះពាល់រយៈពេលដ៏យូរអង្វែង ដែលមិនចាំបាច់ធ្វើឲ្យធនធានស្រកចុះជាបន្តបន្ទាប់គួរឲ្យកត់សំគាល់ ។ វិស័យទាំងឡាយ ដែលអាចផ្តល់ឱកាសក្នុងការអនុវត្តន៍ជាក់ស្តែងសំរាប់កេរ្តិ៍ដំណែល ជារួមមានការអភិវឌ្ឍន៍វិជ្ជាជីវៈ កំណែទម្រង់ច្បាប់ និងហេដ្ឋារចនាសម្ព័ន្ធជាក់ស្តែង។ ប៉ុន្តែបញ្ហាកេរ្តិ៍ដំណែលត្រូវពង្រីកឲ្យហួសពីនោះទៀត ទាក់ទងនឹងផលប៉ះពាល់ជាក់ស្តែងទៅលើប្រព័ន្ធច្បាប់ក្នុងស្រុក និងដើម្បីសម្រេចបាននូវការផ្លាស់ប្តូរ ក្នុងក្របខ័ណ្ឌនៃទំនុកចិត្តក្នុងប្រព័ន្ធច្បាប់ ជាមធ្យោបាយដែលអាចសម្រេចបាន សម្រាប់ដោះស្រាយជម្លោះនាពេលអនាគត និងការរំលោភបំពានសិទ្ធិមនុស្សកំពុងបន្ត។ នេះគឺសំដៅដល់ផលនិទស្សន៍ ដែលធ្វើឲ្យកាន់តែប្រសើរឡើងតាមរយៈសកម្មភាពដល់សហគមន៍មានប្រសិទ្ធភាព និងការពាក់ព័ន្ធរបស់សង្គមស៊ីវិលកាន់តែទូលំទូលាយថែមទៀត។

តុលាការកូនកាត់តែមួយ នឹងមិនអាចអនុវត្តបាននូវយុត្តិសាស្ត្រកេរ្តិ៍-ដំណែល ប្រកបដោយជោគជ័យបាននោះទេ។ របាយការណ៍របស់អគ្គលេ-ខាធិការសហប្រជាជាតិបញ្ជាក់ថា កំណែទម្រង់ប្រព័ន្ធច្បាប់ជាតិ ត្រូវតែធ្វើ និងជម្រុញឡើងដោយម្ចាស់ការក្នុងប្រទេសដោយខ្លួនឯង ហើយ ថា នៅទី-បញ្ចប់នឹងមិនមានកំណែទម្រង់ផ្នែកនីតិរដ្ឋ ការស្តាបនាឡើងវិញនូវវិស័យ

យុត្តិធម៌ ឬការផ្តួចផ្តើមគំនិត ផ្នែកយុត្តិធម៌អន្តរកាលត្រូវបានដាក់ចេញពីពិភពខាងក្រៅ ដែលអាចសង្ឃឹមថា នឹងមានជោគជ័យ និងនិរន្តរភាព។ លុះ-ត្រាតែ តុលាការកូនកាត់បញ្ចូលរបៀបវារៈក្នុងកំណែទម្រង់ប្រព័ន្ធតុលាការក្នុងស្រុក ដែលរាប់បញ្ចូលទាំងការកសាងទំនាក់ទំនងវិជ្ជមាន ជាមួយនឹងដៃគូផ្នែកច្បាប់ក្នុងស្រុក ហើយនិងវឌ្ឍនភាព នៃកេរ្តិ៍ដំណែលនឹងនៅតែពិសេស និងមិនអាចផ្តាច់ចិត្តបាន។ កត្តាទាំងអស់នេះទាមទារឲ្យមានក្តីរំពឹងទុកអាចសម្រួលបាននូវអ្វីៗ ដែលអាចសម្រេចបានពិតប្រាកដ និងការពិនិត្យមើលតួនាទីរបស់តុលាការកូនកាត់មិនមែនដូចជាអ្នកបើកបរនោះទេ ក៏ប៉ុន្តែជាកាតាលីករ ក្នុងការលើកទឹកចិត្តដល់ដៃគូការងារ ឬកិច្ចផ្តួចផ្តើមគំនិតកាន់តែទូលំទូលាយថែមទៀត ដែលអាចរួមវិភាគទានចំពោះកេរ្តិ៍ដំណែល។

សារសំខាន់ នៃកេរ្តិ៍ដំណែលអាចត្រូវបានគេយល់ដឹងដ៏ប្រសើរបំផុតប្រសិនបើតួនាទី នៃអយ្យការដែលពាក់ព័ន្ធនឹងករណីការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរមិនត្រូវបានគេពិចារណាថា ជាវិសាលភាពពិតប្រាកដរបស់យុត្តាធិការព្រហ្មទណ្ឌសាមញ្ញ ដែលមានស្រាប់ ក៏ប៉ុន្តែចាត់ទុកជាឱកាសវិសាមញ្ញមួយពិតប្រាកដ សម្រាប់សង្គមមួយ ដើម្បីធ្វើឲ្យអន្តរកាលក្លាយជាវប្បធម៌នីតិរដ្ឋជាពិសេសនៅទីណា ដែលតុលាការកូនកាត់មានយុត្តាធិការលើឧក្រិដ្ឋកម្មកាលពីអតីតកាល ដែលផ្ទុយពីឧក្រិដ្ឋកម្មនាពេលបច្ចុប្បន្ន ឬអនាគតកាល។ ចំពោះបញ្ហានេះ យុត្តិកម្មទាំងឡាយមានដូចជា ការធ្វើឲ្យញញើត ឬការដាក់ទណ្ឌកម្មមិនត្រូវបានគេពិចារណាថា ជារឿងសំខាន់ចំពោះការសម្រេចចិត្តដំណើរការជំនុំជម្រះក្តីទាំងនេះឡើយ។ ភាពសមហេតុផលដ៏ប្រសើរមួយសម្រាប់ការចោទប្រកាន់ពាក់ព័ន្ធ នឹងករណីការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរគឺត្រូវតែប្រគល់សិទ្ធិឲ្យប្រជាពលរដ្ឋ *ក្នុងការជំទាស់ទៅនឹងការរំលោភបំពាន និងគាំទ្រឲ្យមានតម្លៃប្រជាធិបតេយ្យពិតប្រាកដ* (ដោយរាប់ទាំងដំណើរការក្តីប្រកបដោយយុត្តិធម៌ផងដែរ)។ ការសម្តែងនូវការជំទាស់ជាផ្លូវការយ៉ាងខ្លាំង

ដោយស្ថាប័នរដ្ឋ ដើម្បីប្តេជ្ញាចិត្តលើតម្លៃសិទ្ធិមនុស្ស និងប្រជាធិបតេយ្យ អាចជួយបញ្ចុះបញ្ចូលប្រជាពលរដ្ឋ ក៏ដូចជាស្ថាប័នទាំងឡាយ អំពីសារ-សំខាន់នៃតម្លៃទាំងនោះ។ ការជំពាក់ជំពិនសម្រាប់កេរ្តិ៍ដំណែលមាន*២វិធី៖ វិធីទី១* គឺដំណើរការកេរ្តិ៍ដំណែល មានសារសំខាន់ដូចគ្នានឹងលទ្ធផលទទួលបានដែរ។ *វិធីទី២* គឺប្រសិនបើតុលាការកូនកាត់ពិសេសណាមួយបរាជ័យក្នុងការដំណើរការនូវអាណត្តិដ៏មានសារសំខាន់របស់ខ្លួន ទាំងការប្រាកដឡើងនៃសញ្ញាជំទាស់ទៅនឹងការប្រព្រឹត្តទៅផ្ទែកព្រហ្មទណ្ឌ ដោយការបរាជ័យក្នុងការអនុវត្តន៍យុត្តាធិការដោយឯករាជ្យ ចំពោះបុគ្គលណា ដែលនឹងរៀបចំផែន-ការ និងសម្របសម្រួលឧក្រិដ្ឋកម្មធ្ងន់ធ្ងរទាំងឡាយ ឬក៏ការពោលអះអាងជាថ្មីអំពីតម្លៃប្រជាធិបតេយ្យ (ដោយរាប់ទាំងសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ដោយសាលាក្តីមួយមិនលំអៀង) កេរ្តិ៍ដំណែលរបស់សាលាក្តីនឹងត្រូវអន់ថយដោយចៀសមិនរួចឡើយ។

# II. ការពិចារណាជាបឋម

## ក. អាណត្តិ

ការផ្តួចផ្តើមគំនិតកាលពីអតីតកាលនៅកូសូវ៉ូ ទីម័រខាងកើត និងប្រ-ទេសសេរ៉ាឡេអូន ស្តីពីបញ្ហាកេរ្តិ៍ដំណែលមិនត្រូវបានបញ្ចូលទៅក្នុងអាណត្តិឲ្យបានជាក់លាក់នោះទេ។ ផ្ទុយទៅវិញ អាណត្តិរបស់គេផ្តោតជាសំខាន់លើយុត្តាធិការនៃបទចោទប្រកាន់។ គោលដៅជាបឋមគឺត្រូវប្រឈមកង្វះឯក-រាជភាព និងភាពលំអៀង ដែលបានលើកឡើងក្នុងរង្វង់ប្រព័ន្ធយុត្តិធម៌ក្នុងស្រុកនៅកូសូវ៉ូ។ ជាញឹកញាប់ កង្វះអាណត្តិជាក់លាក់ស្តីពីបញ្ហាកេរ្តិ៍ដំណែល ឬការកសាងសមត្ថភាពមានន័យថា ជាធម្មតា ព្រះរាជអាជ្ញា និងចៅក្រមត្រូវផ្តោតការយកចិត្តទុកដាក់ តែលើការងារលើសំណុំរឿងក្នុងដៃដែលជំនុំជម្រះតែប៉ុណ្ណោះ។

ចំពោះវិសាលភាពដ៏ធំធេង ការបកស្រាយកេរ្តិ៍ដំណែល គឺត្រូវផ្តល់តួនាទីជាឆន្ទានុសិទ្ធិដល់តួអង្គនីមួយៗ ដោយសារគ្មានអាណត្តិជាក់លាក់ស្តីពីបញ្ហានេះ។ មានចំនួនច្រើន ដែលត្រូវដើរទៅមុខ ដោយសន្សឹមៗដោយស្វ័យប្រវត្តិឆ្ពោះទៅរកវិធីសាស្ត្រ ដែលផ្តោតលើការគ្រប់គ្រងសំណុំរឿងទាំងឡាយដ៏មានប្រសិទ្ធភាព។ តួអង្គទាំងនោះមានឱកាសក្នុងការលើកកម្ពស់ការផ្តួចផ្តើមគំនិតអំពីកេរ្តិ៍ដំណែលដោយជោគជ័យ ក៏ប៉ុន្តែការផ្តួចផ្តើមគំនិតទាំងនេះមិនចាំបាច់ធ្វើជាប្រព័ន្ធទេ ព្រមទាំងមិនចាំបាច់ទទួលយកកិច្ចគាំពារផ្នែកនយោបាយ ឬថវិកាជាមូលដ្ឋានឡើយ។

វិសាលភាព ដែលកេរ្តិ៍ដំណែលគប្បីជាផ្នែកមួយ នៃអាណត្តិស្នូលរបស់តុលាការកូនកាត់គឺ ជាបញ្ហានៃវាទបដិវាទមួយចំនួន។ មតិមួយចំនួនលើឡើងថា តុលាការកូនកាត់ត្រូវផ្តោតលើអាណត្តិស្នូល ក្នុងការជួយបញ្ចប់

និទណ្ឌភាព ត្រូវបានបំពេញដោយរបៀបវារៈនីតិរដ្ឋដ៏រឹងមាំមួយ ដែលមានកេរ្តិ៍ដំណែលជាកម្មវត្ថុមួយសម្រាប់ធ្វើការតាក់តែង និងអនុវត្តន៍។ គេបានលើកហេតុផលថា ការផ្តោត ជាបឋមគឺការអង្កេត និងការចោទប្រកាន់ប្រកបដោយជោគជ័យ ព្រមទាំងធ្វើការផ្តន្ទាទោស និងការលើកលែងបទចោទប្រកាន់ និងការអនុវត្តន៍ទោសជាបន្តបន្ទាប់ នោះនឹងជាព្រឹត្តិការណ៍គន្លឹះ នៃជោគជ័យទាំងជាតិ និងអន្តរជាតិ។ វិធីសាស្ត្រនេះអះអាងថា កេរ្តិ៍ដំណែលអាចមានចេរភាពទៅបាន ទោះបីជាមិនបានកំណត់តាមអាណត្តិ យ៉ាងជាក់លាក់ក៏ដោយ។

មតិផ្សេងៗទៀតបានលើកឡើងថា មានការពិបាកច្រើនស្តីពីការបង្កើតឲ្យមានកិច្ចគាំពារផ្នែកនយោបាយ សម្រាប់កេរ្តិ៍ដំណែល ដោយគ្មានអាណត្តិដ៏ជាក់លាក់មួយ ហើយថា កិច្ចគាំពារផ្នែកនយោបាយ គឺជាកត្តាដ៏សំខាន់សម្រាប់ជោគជ័យផ្នែកកេរ្តិ៍ដំណែល។ ទស្សនៈនេះសន្មត់ជាមុនថា ការបញ្ចប់និទណ្ឌភាព និងការធានានូវការងាររបស់តុលាការ បន្សល់ទុកនូវកេរ្តិ៍-ដំណែលត្រូវកើតមានឡើងក្នុងពេលដំណាលគ្នា និងជាគោលដៅពង្រឹងអញ្ញ-មញ្ញ។ លើសពីនេះទៀត អ្នកជំនាញមួយចំនួន សំដែងទស្សនៈថា អាណត្តិជាក់លាក់ត្រូវកំណត់ឲ្យបានល្អិតល្អន់ តាមដែលអាចធ្វើទៅបាន ពីព្រោះថាអាណត្តិទូលំទូលាយនាំមកនូវសក្តានុពល ក្នុងការជ្រៀតជ្រែកផ្នែកនយោ-បាយច្រើន។ សារសំខាន់ដូចៗគ្នាគឺសេចក្តីត្រូវការ ដើម្បីធានានូវអាណត្តិ និងច្បាប់ថ្មីៗនានាជុំវិញការបង្កើតរបស់ខ្លួនគឺត្រូវបានកែសម្រួលតាមច្បាប់ក្នុងស្រុក ទាំងអង្គហេតុ និងទស្សនៈស៊ីជម្រៅ។

ករណីប្រទេសសេរ៉ាឡេអូន គឺជាការផ្ទេរចំណេះដឹង ក្នុងបរិបទនេះ។ មន្ត្រីជាន់ខ្ពស់មួយចំនួន នៅក្នុងតុលាការពិសេសមានការប្តេជ្ញាចិត្ត ចំពោះកេរ្តិ៍ដំណែល ក៏ប៉ុន្តែការផ្តួចផ្តើមគំនិតរបស់គេ ជានិច្ចជាកាលមិនត្រូវបាន

គាំទ្រដោយគណៈកម្មាធិការគ្រប់គ្រង។ កាលពីមុន គណៈកម្មាធិការគ្រប់គ្រងផ្តោត លើដំណើរការប្រតិបត្តិការ របស់តុលាការពិសេសក្នុងដែនថវិកា និងក្របខ័ណ្ឌពេលវេលាដ៏តឹងតែង ដែលទទួលខុសត្រូវផ្តល់មតិយោបល់ដល់តុលាការពិសេស និងបញ្ហាក្រៅប្រព័ន្ធតុលាការ និងជួយជ្រោមជ្រែងស្វែងរកមូលនិធិ។ នេះគឺមានលក្ខណៈស៊ីសង្វាក់គ្នានឹងឥរិយាបថ ដែលបច្ចុប្បន្ននេះ ទទួលយកក្នុងចំណោមអ្នកតាក់តែងគោលនយោបាយដែលត្រូវចំណាយលុយយ៉ាងច្រើនសន្ធឹកទៅ លើសាលាក្តីពិសេស ព្រមទាំងលទ្ធផលតិចតួចដោយរាប់ទាំងសំណុំរឿងត្រូវបានបញ្ចប់ និងផលប៉ះពាល់ក្នុងតំបន់។ បញ្ហាមួយទៀត ដែលបានកំណត់ព្រំដែនសមត្ថភាព របស់តុលាការពិសេស ដើម្បីរួមចំណែកដល់កេរ្តិ៍ដំណែល ត្រូវបានចែងពីក្របខ័ណ្ឌពេលវេលាដ៏ចង្អៀតនៃអាណត្តិរបស់ខ្លួន ជាអាទិ៍ត្រូវបានគេផ្តល់ឲ្យរវាង៣ឆ្នាំ (ទោះបីជា រយៈ-ពេលនេះត្រូវបានគេបង្ហាញថា មិនអាចអនុវត្តបានក៏ដោយ)។

នៅពេលជាមួយគ្នានេះដែរ អ្នកតាក់តែងគោលនយោបាយអាចមានបំណងប្រាថ្នាចង់ឃើញនូវផលប៉ះពាល់ និងផលប្រយោជន៍យូរអង្វែង និងចាំបាច់ត្រូវជូនដំណឹង និងអប់រំនូវអ្វីៗជាលទ្ធភាពផ្សេងៗអាចធ្វើបាន។ កង្វល់នានាអំពីធនធានត្រូវការចាំបាច់ត្រូវបានលើកឡើង។ អគ្គលេខាធិការបានសំដែងនូវការពេញចិត្តយ៉ាងច្បាស់រួចហើយ ចំពោះការចូលរួមដែលគេបានប៉ាន់ស្មានទាក់ទងនឹងតុលាការកូនកាត់ ទោះបីជាយ៉ាងណាក៏ដោយ ស្ថាន-ភាពបច្ចុប្បន្នគឺថា តុលាការកូនកាត់មាននិន្នាការ ពឹងផ្អែកលើការរួមវិភាគទានដោយស្ម័គ្រចិត្ត។ ទោះបីជាយ៉ាងណាក៏ដោយ ការលើកឡើងនូវកង្វល់ទាំងនេះមិនត្រូវបោះបង់ចោលការកសាងសមត្ថភាពប្រកបដោយចេរភាពឡើយ ក្នុងរង្វង់នៃព្រំដែនប្រាកដនិយម។ ទោះបីជាមានការប្តេជ្ញាចិត្តចំពោះការប្រើ-ប្រាស់ និងការកសាងសមត្ថភាពជាតិ តាមដែលអាចធ្វើទៅបាន *ព្រមទាំងភាគរយសមហេតុផល* នៃថវិកាសរុប (ដូចជាពី៥ ទៅ១០ភាគរយ) ដែល

បំរុងទុកសម្រាប់ការផ្សព្វផ្សាយជាក់លាក់ និងសកម្មភាពកេរ្តិ៍ដំណែលនានា ដែលត្រូវធ្វើដំណើរដ៏វែងឆ្ងាយ។

គ្រោះថ្នាក់គឺបណ្តាលមក ពីការខកខានមិនបានបំពេញដូចបាន លើកឡើងមកនេះ ដូចបាន បង្ហាញបទពិសោធន៍ នៃអង្គភាពផ្នែកឧក្រិដ្ឋកម្ម កំរិតធ្ងន់នៅប្រទេសទីម័រខាងកើត ដែលត្រូវបានបិទទ្វារនោះ ដោយបន្សល់ទុកនូវកេរ្តិ៍ដំណែលដ៏តិចតួច ហើយក៏គ្មានបណ្តឹងសើរើផ្លូវច្បាប់ច្បាស់លាស់ សម្រាប់សំណុំរឿងដែលមិនទាន់បានដោះស្រាយដែរ។ មានការផ្សារភ្ជាប់ដ៏ចាំបាច់ និងរៀងរហូតមករវាងការជំនុំជម្រះបទឧក្រិដ្ឋនានា ដើម្បីបញ្ចប់នូវនិទណ្ឌភាព និងការកសាងសមត្ថភាពដោយចេរភាពមួយ ដើម្បីលើកឡើងជាដំណោះស្រាយចំពោះបទឧក្រិដ្ឋបែបនោះ នាពេលអនាគត។ លើសពីនេះទៀត តួយ៉ាងដូចជា ការកសាងសមត្ថភាពក៏ជាផ្នែកមួយចាំបាច់ផងដែរ នៃវិធីសាស្ត្រដ៏មានប្រសិទ្ធភាពចំពោះការកាត់ទោស ដែលជាបញ្ហាសំខាន់ និងត្រូវពឹងផ្អែកទៅលើអ្នកស៊ើបអង្កេតក្នុងស្រុក និងអ្នកបកប្រែជាដើម។ ជាលទ្ធផល កេរ្តិ៍ដំណែលត្រូវកំណត់អាណត្តិឲ្យបានច្បាស់លាស់ និងទទួលបានកិច្ចគាំពារពីថវិកាស្នូល។ ការដាក់សម្ពាធគឺដើម្បីកំណត់ពេលវេលា ដែលមិនប្រាកដនិយមក៏ត្រូវចៀសវាងផងដែរ។

## ១. ផែនការ

តាមរយៈ នៃផែនការស្តីពីការបង្កើតតុលាការកូនកាត់ គឺមានសារសំខាន់ ចំពោះការប្រើប្រាស់សមត្ថភាពច្បាប់អន្តរជាតិដ៏មានប្រសិទ្ធភាពនៅថ្នាក់ជាតិ។ ប្រការនេះត្រូវរាប់បញ្ចូលទាំងការវាយតម្លៃមួយច្បាស់លាស់អំពីសមត្ថភាពជាតិ ដោយមានការចូលរួមពីអ្នកជំនាញធនធានមនុស្ស។ ប្រសិនបើគ្មានផែនការបែបនោះទេ អ្នកធ្វើសេចក្តីសម្រេចអាចធ្វើការសន្និដ្ឋានដោយមិនសុក្រឹត្យ ចំពោះសមត្ថភាពក្នុងស្រុក និងលក្ខ័ណ្ឌផ្សេងៗទៀត។

ជាបន្តបន្ទាប់ ការសន្និដ្ឋានណាមួយដោយមិនសុក្រឹត្យ ព្រមទាំងសញ្ញាណនៃបញ្ហាអាចនាំមកនូវយុទ្ធសាស្ត្រ ដែលមិនមានប្រសិទ្ធភាព និងធ្វើឲ្យច្របូកច្របល់ដល់ដៃគូការងារជាតិ។ នៅពេលជាមួយគ្នានេះ ការវាយតម្លៃបែបនោះ ជាញឹកញាប់ត្រូវបានធ្វើឡើងដោយសង្ខេប និងទទួលបានការចាប់អារម្មណ៍មានកំរិត កំឡុងពេលបេសកកម្មផែនការ។ ដើម្បីធានានូវផលប្រយោជន៍អតិបរមានៃអន្តរាគមន៍អន្តរជាតិ និងតាក់តែងយុទ្ធសាស្ត្រដ៏មានប្រសិទ្ធភាពមួយសម្រាប់កេរ្តិ៍ដំណែល គឺត្រូវការជាចាំបាច់នូវផែនការជាច្រើនទៀត លើផែនការដែលមានសព្វថ្ងៃនេះ លិខិតុបករណ៍ផ្សេងៗ ដូចជារបាយ-ការណ៍ នៃយន្តការសិទ្ធិមនុស្សសហប្រជាជាតិ (ឧ. អ្នកជំនាញឯករាជ្យ អ្នក-រាយការណ៍ពិសេស) របាយការណ៍បេសកកម្មរក្សាសន្តិភាពជូនក្រុមប្រឹក្សាសន្តិសុខសហប្រជាជាតិ ការស្ទង់មតិវិស័យយុត្តិធម៌ ដែលរៀបចំជាប្រចាំដោយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ឬក៏អង្គការក្រៅរដ្ឋាភិបាលការរៀបចំផែនទីស្តីពីការរំលោភសិទ្ធិមនុស្ស ឬរបាយការណ៍នៃការឃ្លាំមើលតុលាការ ដែលត្រូវបានបំពេញបន្ថែម ចំពោះការវាយតម្លៃទាំងនេះ។

សមាសភាពនៃក្រុមវាយតម្លៃមានសារប្រយោជន៍ ហើយក្រុមទាំងនេះមិនត្រឹមតែដឹកនាំដោយតួអង្គសហប្រជាជាតិ ដែលមានចំណេះដឹងពិស្តារអំពីប្រទេសនោះប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវដាក់បញ្ចូលតួអង្គច្បាប់ជាតិផងដែរ។ នៅទីណាដែលមានប្រតិបត្តិការរក្សាសន្តិភាព ជាមូលដ្ឋានគឺត្រូវមានការផ្តល់ជំនួយចំពោះបេសកកម្មផែនការ និងគួរធ្វើការវាយតម្លៃពិតប្រាកដរួចស្រេច។ ពិសេសជាងនេះទៀត បេសកកម្មវាយតម្លៃវិស័យយុត្តិធម៌នេះត្រូវរៀបចំដំណើរការនូវទស្សនៈរួមមួយដ៏ទូលំទូលាយ នៃវិស័យយុត្តិធម៌ផ្នែកព្រហ្មទណ្ឌ និងគម្រោងច្បាប់ជាតិ ដែលជាញឹកញាប់បំរុងពេលទុកច្រើនជាង២-៣សប្តាហ៍ សម្រាប់គោលបំណងនេះ។ បេសកកម្មផែនការកម្មត្រូវខិតខំកៀងគរឲ្យមានការចូលរួមពីតួអង្គផ្សេងៗ ដ៏ទូលំទូលាយ រាប់បញ្ចូល

ទាំងសង្គមស៊ីវិល ហើយត្រូវបង្កើតបញ្ជីផ្ទៀងផ្ទាត់ ដើម្បីឲ្យសម្រេចបាននូវគោលបំណងនេះ។

## គ. ភាពម្ចាស់ការ

តាមនិយមន័យ វិធីសាស្ត្រចម្រុះទាមទារឲ្យមានការវិនិយោគទាំងពីអង្គការជាតិ និងអង្គការ អន្តរជាតិ រដ្ឋាភិបាល អង្គការជនរងគ្រោះ សហគមន៍ច្បាប់នានា និងសង្គមស៊ីវិល។ អ្វីៗដែលកាន់តែប្រសើរ គឺដៃគូការងារពាក់ព័ន្ធទាំងអស់នោះគួរតែចូលរួម ក្នុងដំណើរការនេះ។ តាមបទពិសោធន៍បានបង្ហាញថា កម្រិតនៃភាពម្ចាស់ការ ដ៏សមស្របពិបាកនឹងសម្រេចបានណាស់ ហើយវាត្រូវបានផ្សារភ្ជាប់យ៉ាងជិតស្និទ្ធនឹងឆន្ទៈនយោបាយ ។

ដោយសារតែការបង្កើតអង្គជំនុំជម្រះឧក្រិដ្ឋកម្មសង្គ្រាម នៅបូស្នៀ (Bosnia) និងហឺហ្សេហ្គូវីណា (Herzegovina) ពាក់ព័ន្ធនឹងយុទ្ធសាស្ត្របញ្ចប់សាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិ សម្រាប់អតីតប្រទេសយូហ្គូស្លាវីនោះ (Yugoslavia) និងសេចក្តីសម្រេចរបស់ខ្លួន ដើម្បីផ្ទេរសំណុំរឿងជូនទៅយុត្តាធិការជាតិវិញ ហើយយុត្តិសាស្ត្រនេះផ្តល់ជូននូវគំរូថ្មី ដែលនឹងនាំមកនូវជោគជ័យពីទស្សនៈស៊ីជំរៅនៃភាពម្ចាស់ការ។ អង្គជំនុំជម្រះបង្កើតបានជាផ្នែកមួយនៃអង្គភាពផ្នែកព្រហ្មទណ្ឌ នៃតុលាការរដ្ឋជាអចិន្ត្រៃយ៍ថ្មីសម្រាប់បូស្នៀ (Bosnia) និងហឺហ្សេហ្គូវីណា (Herzegovina)។ បច្ចុប្បន្ននេះ ទោះបីជាមានព្រះរាជអាជ្ញា ចៅក្រម និងតួអង្គផ្សេងៗទៀតក្នុងអង្គជំនុំជម្រះក៏ដោយក៏វាគឺជាតុលាការជាតិ និងការចូលរួមពីភាគីអន្តរជាតិនឹងត្រូវបញ្ចប់ម្តងបន្តិចៗក្នុងរង្វង់រយៈពេលប្រហែលជា៥ឆ្នាំ។ អង្គជំនុំជំរះត្រូវចាត់វិធានការណ៍ជាជំហានវិជ្ជមានពីដើមដំបូង ដើម្បីពង្រឹងឲ្យបានច្បាស់លាស់នូវស្ថានភាពក្នុងស្រុករបស់ខ្លួន។ ឧទាហរណ៍ ចៅក្រមក្នុងស្រុកដឹកនាំដំណើរការជំនុំជម្រះទោះបីជាចៅក្រម២នាក់ទៀត ក្នុងគណៈវិនិច្ឆ័យជាអន្តរជាតិក៏ដោយ។ ភាគច្រើននៃបុគ្គលិកជាតិគឺជាផ្នែកមួយនៃប្រព័ន្ធតុលាការជាតិ។ ទោះបីជា សា-

ធារណរដ្ឋសៀប (Republika Srpska) នៅតែមានតំណាងមិនទាន់គ្រប់គ្រាន់ក៏ដោយ ក៏អង្គជំនុំជម្រះនេះទទួលបាននូវការគាំទ្រ ផ្នែកនយោបាយពីតំណែងប្រធានពីសមាជិកទាំង៣របស់បូស្នៀ (Bosnia) និងហឺហ្សេហ្គូវីណា (Herzegovina) និងបុគ្គលិកតំណាងក្រុមជាតិពន្ធសំខាន់ៗទាំង៣។ ប្រធានមកពីភាគីជាតិ ត្រូវទទួលខុសត្រូវក្នុងការដឹកនាំអង្គជំនុំជម្រះរួម ទោះបីជាភាគីអន្តរជាតិ នៅតែដើរតួនាទីដ៏សំខាន់ក្នុងការគ្រប់គ្រង និងតាក់តែងគោលនយោបាយក៏ដោយ។ វត្តមានរបស់ភាគីអន្តរជាតិត្រូវបង្កើតឡើង ដើម្បីផ្សារភ្ជាប់វិធានការ នៃទំនុកចិត្ត បើមិនដូច្នោះទេ នឹងអាចជួបការពិបាកក្នុងការបង្កើតក្របខ័ណ្ឌនៃការមិនទុកចិត្តគ្នា និងភាពតានតឹងផ្នែកជាតិពន្ធដែលមានជាយូរមកហើយក្នុងប្រទេសនេះ។

ទាំងនៅកូសូវ៉ូ និងទីម័រខាងកើត ភាពម្ចាស់ការមានលក្ខណៈស្មុក-ស្មាញដោយសារការពិតថា ប្រទេសទាំង២នេះស្ថិតក្រោមរដ្ឋបាលប្រតិបត្តិរបស់សហប្រជាជាតិ នៅពេលដែលនិយ័តកម្មនានា បង្កើតតុលាការកូនកាត់របស់គេ ឬដំណើរការនានាត្រូវបានអនុម័ត។ ក្នុងករណីទាំង២នោះ តាមពិតទៅគ្មានការពិគ្រោះយោបល់ជាមួយដៃគូច្បាប់ក្នុងស្រុក ឬសាធារណៈ នាំមុខសេចក្តីសម្រេច ស្តីពីការបញ្ចូលឡើយដៃគូការងារអន្តរជាតិ ទៅក្នុងប្រព័ន្ធច្បាប់ក្នុងស្រុកឡើយ ដែលឆ្លុះបញ្ចាំងតាមរយៈនិយ័តកម្ម UNMIK លេខ ២០០០/៦៤ និងនិយ័តកម្ម UNTAET លេខ ២០០០/១៥។ កង្វះការ-ពិគ្រោះយោបល់ប្រកបដោយអត្ថន័យណាមួយ ចំពោះតុលាការកូនកាត់បានបង្ហាញអំពីការបរាជ័យយ៉ាងធំធេង ដើម្បីនឹងពិគ្រោះយោបល់ជាមួយដៃគូការងារ និងសាធារណៈស្តីពីកិច្ចប្រឹងប្រែងខាងកំណែ ទម្រង់ប្រព័ន្ធច្បាប់ដ៏រឹងមាំជាច្រើនអនុវត្តនៅកូសូវ៉ូ និងទីម័រខាងកើតចាប់តាំងពីឆ្នាំ១៩៩៩។ ទាំងនៅកូសូវ៉ូ និងនៅទីម័រខាងកើតមិនមានប្រព័ន្ធច្បាប់ ដែលដំណើរការនៅពេលនោះទេ ប៉ុន្តែមិនបានរាប់បញ្ចូលទាំងដៃគូការងារក្នុងស្រុក នៅក្នុង

ដំណើរការនៃការធ្វើសេចក្តីចិត្តពីដើមដំបូង ដែលផ្តល់ផលប៉ះពាល់មិនល្អលើភាពម្ចាស់ការក្នុងស្រុក។ ឧទាហរណ៍ អ្នកប្រកបវិជ្ជាជីវៈច្បាប់ក្នុងស្រុកដើរ តួនាទីតិចតួច ឬគ្មានក្នុងការតាក់តែងគោលនយោបាយច្បាប់នៅកូសូវ៉ូដែលនៅតែជាកម្មសិទ្ធិតែ មួយគត់នៃនាយកដ្ឋានកិច្ចការតុលាការរបស់UNMK។ លើសពីនេះទៀត ផែនការភាគច្រើនត្រូវបង្កើតក្រសួងយុត្តិធម៌ សម្រាប់កូសូវ៉ូត្រូវបានបង្កើតឡើង ដោយអ្នកតាក់តែងគោលនោបាយអន្តរជាតិ ។

វិសាលភាពសម្រាប់ភាពជាម្ចាស់ការ នៃប្រទេសនោះអាចមានលក្ខណៈធំធេង ប៉ុន្តែមានភាពស្មុកស្មាញច្រើន ដោយសារតែស្ថានភាពផ្សេងៗអាចកើតមានឡើង នៅទីណាតុលាការកូនកាត់ត្រូវ បានបង្កើតឡើងតាមរយៈការចរចារ ជាមួយរដ្ឋាភិបាលដែលមានអធិបតេយ្យភាព។ តួនាទីរបស់ប្រជាពលរដ្ឋសេរ៉ាឡេអូន ក្នុងរចនាសម្ព័ន្ធតុលាការពិសេសត្រូវបានជះឥទ្ធិពល ដោយសារតែមាន សេចក្តីសម្រេចរបស់រដ្ឋាភិបាល ក្នុងការតែងតាំងបុគ្គលិកអន្តរជាតិចូលបំរើក្នុងតំណែងសំខាន់ៗមួយចំនួន ដែលគួរតែត្រូវបំពេញដោយជនជាតិសេរ៉ាឡេអូន។ កត្តានេះ និងកត្តាផ្សេងៗទៀតបានចូលរួមចំណែកចំពោះទស្សនៈថា កត្តាសំខាន់តុលាការកូនកាត់គឺជាស្ថាប័នអន្តរជាតិមួយ។ ភាពជាម្ចាស់ការត្រូវពិចារណាទាំងចំណុច ក្នុងការបង្កើត និង នៅពេលណាក៏ដោយសេចក្តីសម្រេចចិត្តសំខាន់ណាមួយ ត្រូវបានធ្វើឡើងតាមរយៈអត្ថិភាពរបស់សាលាក្តី ការដាក់បញ្ចូលឲ្យមានការពាក់ព័ន្ធរបស់តួអង្គផ្សេងៗគ្នា ដោយរាប់បញ្ចូលទាំងសង្គមស៊ីវិលផងដែរ។

## ឃ. ដៃគូការងារ

ការកំណត់ដៃគូការងារនានាទាក់ទងគ្នា យ៉ាងខ្លាំងជាមួយបញ្ហាអំពីភាពម្ចាស់ការ។ គឺជាដៃគូការងារទាំងឡាយណា ដែលសហគមន៍អន្តរជាតិបានដាក់ឲ្យពាក់ព័ន្ធ កំឡុងពេលការចរចារ ស្តីពីការបង្កើតតុលាការកូនកាត់

នោះ ដោយដើរតួនាទីយ៉ាងសំខាន់ ក្នុងការធានាឲ្យមានកិច្ចគាំពារពីដៃគូការងារនានាក្នុងចំណោមសង្គមស៊ីវិល និងសហគមន៍ច្បាប់។ ជាលទ្ធផល វិសាល-ភាពនេះត្រូវមានលក្ខណៈទូលំទូលាយ និងបញ្ចូលដៃគូការងារសំខាន់ៗ។

តាមនិយមន័យ ដោយសារតែការចរចារបង្កើតតុលាការត្រូវតែមានកំណត់ ចំពោះតំណាងសហប្រជាជាតិ និងរដ្ឋាភិបាលពាក់ព័ន្ធ បញ្ហានេះភាគីទាំង២អាចមានលទ្ធភាពធ្វើការពិគ្រោះយោបល់ឲ្យបានជាក់លាក់ ដោយមានការចូលរួមពីតួអង្គផ្សេងៗឲ្យបានទូលំទូលាយ នៅពេលដែលដំណើរការនេះនៅតែបន្តធ្វើ។ ក្នុងបរិបទ នៃប្រទេសប៊ូរុនឌី គេបានផ្ដល់អនុសាសន៍ថាស្របតាមដំណើរការចរចារគួរតែមាន ដំណើរការពិគ្រោះយោបល់មួយផ្អែកលើភាពប្រាកដនិយម និងតម្លាភាពយ៉ាងទូលំទូលាយ ដោយមានការចូលរួមភាគច្រើនពីតួអង្គជាតិ និងសង្គមស៊ីវិល ដើម្បីធានាថា ក្នុងក្របខ័ណ្ឌច្បាប់ទូទៅសម្រាប់ការបង្កើតយន្តការគណនេយ្យភាពតាមប្រព័ន្ធ និងក្រៅប្រព័ន្ធតុលាការអាចទទួលយកបាន ចំពោះអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលនូវទស្សនៈនិងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋប៊ូរុនឌីត្រូវបានគេធ្វើការពិចារណា។

ទោះបីជាយ៉ាងណាក៏ដោយ ក៏ទំលាប់ក្នុងការអនុវត្តន៍កាលពីអតីត-កាលបង្ហាញថា ព្រំដែនដៃគូការងារ ជាញឹកញាប់មានលក្ខណៈតូចចង្អៀតហើយមិនត្រូវបានបញ្ចូលដៃគូការងារសំខាន់ទាំងអស់ឡើយ ដូចជាតំណាងជនរងគ្រោះ។ ឧទាហរណ៍ ការចរចារដើម្បីបង្កើតតុលាការពិសេសសម្រាប់ប្រទេសសេរាឡេអូនត្រូវបានរៀបចំឡើងតែក្រុមតូចមួយប៉ុណ្ណោះ ដែលច្រើនតែតួអង្គរដ្ឋាភិបាល ជារួមមានអគ្គមេធាវី និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌សេរាឡេ-អូន ដែលដឹកនាំគណៈប្រតិភូ។ កង្វះការចូលពាក់ព័ន្ធរបស់អ្នកជំនាញវិជ្ជាជីវៈផ្នែកច្បាប់កាន់តែខ្លាំងរបស់សេរាឡេអូន និងភាពបរាជ័យ ដើម្បីជូនដំណឹងពួកគេឲ្យបានគ្រប់គ្រាន់អំពីវឌ្ឍនភាព មានន័យថា ជាបឋម មេធាវីយល់ថាពួកគេត្រូវបានផាត់ចេញពីដំណើរការ ហើយទី២ កង្វះព័ត៌មាននាំឲ្យបាត់បង់

ក្ដីសង្ឃឹម និងរំពឹងទុក។ ការកើតចេញជាលទ្ធផលនៃការយល់ខុស និងការ-អាក់អន់ចិត្តណាមួយបែបនោះ អាចរារាំងបានយ៉ាងងាយ ប្រសិនបើមានកិច្ចពិគ្រោះយោបល់ថែមទៀតពីដំបូង។ ជាបឋម ការអាក់អន់ចិត្តស្រដៀងគ្នានេះដែរ ក៏ទំនងជាលេចចេញជារូបរាងជុំវិញសេចក្ដីសម្រេច ដើម្បីបញ្ជូនឆាល ថេល្ល័រ អតីតប្រធានាធិបតីនៃប្រទេសឡាយបេរីរៀ ទៅកាន់ទីក្រុងហេក (ប្រទេសហូឡង់) សម្រាប់ធ្វើការជំនុំជម្រះ ដែលជាសេចក្ដីសម្រេចមួយដែលសង្គមស៊ីវិលត្រូវផាត់ចេញ។

# ង. រចនាសម្ព័ន្ធ

## *១. ទំនាក់ទំនងជាមួយប្រព័ន្ធច្បាប់ក្នុងស្រុក*

តុលាការកូនកាត់នឹងខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីកសាងសម-ត្ថភាពស្ថាប័នក្នុងស្រុកមានស្រាប់ ប្រសិន បើនិន្នាការបច្ចុប្បន្ន ចំពោះការ-កសាងសមត្ថភាពជំនាញ ដោយចេរភាពនៅតែមានបន្ត។ ទំនាក់ទំនងកាន់តែជិតស្និទ្ធជាមួយប្រព័ន្ធច្បាប់ក្នុងស្រុក ដែលមិនអាចអត់បានមានន័យថានឹងមានការគូសបញ្ជាក់យ៉ាងសំខាន់ស្ដីពីការអនុវត្តន៍ច្បាប់ក្នុងស្រុក។ ដោយ-សារតែបញ្ហានេះត្រូវបានគេមើលឃើញថា ជាអ្វីដែលគេចង់បានស្របតាមទស្សនៈនានានៃធម្មានរូប និងភាពប្រាកដប្រជាផ្នែកច្បាប់ ច្បាប់អាចមានភាពខ្វះចន្លោះក្នុងវិស័យមួយចំនួន ឬភាពចាំបាច់ឲ្យមានកំណែទម្រង់។ ការតាក់តែងរួមគឺមានគោលដៅ ដែលច្បាប់អាចអនុវត្តទៅបាន នាពេលបច្ចុប្បន្ននេះដែលត្រូវអនុវត្តនោះ លើកលែងតែក្នុងករណី ដែលច្បាប់មិនស្របតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិតែប៉ុណ្ណោះ។ ទោះបីជាយ៉ាងណា ក៏ដោយជាការចាំបាច់ណាស់ដែលត្រូវវាយតម្លៃជាបន្ទាន់ ចំពោះច្បាប់មានស្រាប់ក្នុងករណីណា ដែលវិធីសាស្ត្របែបនោះត្រូវបានចាត់ឡើង ដើម្បីនឹងកំណត់អំពីការកើតមាននៃភាពមិនស្របគ្នានោះ។

ប្រការសំខាន់ផងដែរ ត្រូវបញ្ជាក់ឲ្យច្បាស់ពីដំបូងថា តើច្បាប់ក្នុងស្រុកណាមួយអាចអនុវត្តបាន។ លើសពីនេះទៀត ក្នុងករណីខ្លះ សេចក្តីត្រូវ-ការដើម្បីធ្វើវិសោធនកម្មច្បាប់ក្នុងស្រុកណា ដែលផ្ទុយពីបទដ្ឋានអន្តរជាតិ ដែលអាចបង្កើតបានជាផ្នែកមួយ នៃកិច្ចចរចារយ៉ាងមានប្រយោជន៍ស្តីពីការបង្កើតតុលាការពិសេស។ ឧទាហរណ៍ កំណែទម្រង់ជាមុននៃក្រមនីតិវិធីព្រហ្ម-ទណ្ឌ និងច្បាប់ស្តីពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលនឹងបានជួយយ៉ាងធំធេងដល់អង្គជំនុំជម្រះវិសាមញ្ញនៅប្រទេស កម្ពុជា។

អាចមានកាលៈទេសៈជាច្រើន ដែលការពឹងផ្អែកលើច្បាប់ក្នុងស្រុកមានស្រាប់នោះមិនមានលក្ខណៈសមស្រប។ គួយ៉ាងដូចជា តុលាការពិសេសសម្រាប់ប្រទេសសេរាឡេអូនមិនអាចជាផ្នែក មួយប្រព័ន្ធច្បាប់ក្នុងស្រុកបានទេ ប្រសិនបើមិនបានលើកឡើងអំពីបញ្ហាស្មុកស្មាញមួយចំនួន ដែលទាក់ទងនឹងច្បាប់និទោសកម្មជាមុន និងអភ័យឯកសិទ្ធិ ផ្នែកអធិបតេយ្យភាពរបស់ឆាល ថេលឿ។ ម្យ៉ាងទៀត តុលាការក្នុងស្រុកក៏អាចរារាំងដោយការកំរិតចំពោះបត្យាប័ន និងមុខងារក្រៅដែនដីផ្សេងៗទៀត។

មានការលើកឡើងអំពីទឡ្ហីករណ៍ដ៏រឹងមាំ ទាក់ទងនឹងការតាក់តែងវិធាននៃនីតិវិធីពិសេស សម្រាប់តុលាការកូនកាត់ក្នុងការបំពេញតាមលក្ខណៈពិសេស នៃការជំនុំជម្រះសំណុំរឿងឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ជារួមមានឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម។ ដោយសារតែឧក្រិដ្ឋកម្មទាំងនេះត្រូវបានគេមើលឃើញថា ជាការកំរិតសក្តា-នុពលដោយផ្ទាល់ នៃកេរ្តិ៍ដំណែលវិធានបែបនោះគឺជាវិធានចាំបាច់ សម្រាប់ការផ្តន្ទាទោសដោយប្រសិទ្ធភាព និងយុត្តិធម៌នៃឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរទាំងនេះ និងនៅតែមានសន្ទុះសម្រាប់កំណែទម្រង់នាពេលក្រោយ ។

## *៦. ទីតាំង: វិធីសាស្ត្របែបមជ្ឈការ ទល់នឹងបែបវិមជ្ឈការ*

បញ្ហានេះអាចពិគ្រោះយោបល់បានថា តើគេរំដំណែលត្រូវបានគេលើកកម្ពស់កាន់តែប្រសើរ ឡើងបានតាមរយៈការដាក់ពង្រាយបុគ្គលិកអន្តរ-ជាតិទូទាំងប្រព័ន្ធច្បាប់ជាតិ (បញ្ចូលបុគ្គលិកអន្តរជាតិទៅក្នុងតុលាការជាតិនៅតាមបណ្តាខេត្តនានា) ឬតាមរយៈការបង្កើតសមត្ថភាពបែបមជ្ឈការ និងជំនាញ តូយ៉ាងដូចជានៅរដ្ឋធានី។ នាបច្ចុប្បន្ននេះ គំរូបែបមជ្ឈការទំនងជាគំរូសកល ហើយត្រូវបានប្រើប្រាស់ក្នុងប្រទេសសេរាឡេអូន បូស្នៀ និងហឺ-ហ្សីហ្គូវីណា និងកម្ពុជា។ នាពេលថ្មីៗនេះ កិច្ចពិភាក្សាស្តីពីការផ្តោតលើសមត្ថ-ភាពអន្តរជាតិក៏ប្រាកដឡើងផងដែរនៅកូសូវ៉ូ។ គុណប្រយោជន៍ ដ៏ច្បាស់លាស់នៃគំរូបែបមជ្ឈការគឺថា មានលក្ខណៈងាយស្រួលចាត់ចែង និងគ្រប់គ្រងជាងដែលទាក់ទងនឹងការការពារទល់នឹងឥទ្ធិពល នៃបញ្ហាជាប្រព័ន្ធនានា ដែលធ្វើឲ្យសៅហ្មងដល់ប្រព័ន្ធច្បាប់ក្នុងស្រុក។ ប្រការនេះអាចធ្វើឲ្យគេសម្រេចបាននូវវឌ្ឍនភាពក្នុងរយៈពេលខ្លី និងរក្សាឲ្យបាននូវបរិយាកាសនៃការសម្រេចបាន និងជោគជ័យដោយមានបទដ្ឋានវាយតម្លៃច្បាស់លាស់។ ប្រទេសសេ-រាឡេអូន បូស្នៀ និងហឺហ្សីហ្គូវីណា រចនាសម្ព័ន្ធនៅជុំវិញតុលាការត្រូវបានស្ថាបនាយ៉ាងឆាប់រហ័ស។ បច្ចេកវិទ្យាជាន់ខ្ពស់ និងបរិវេណគួរឲ្យចាប់អារម្ម-ណ៍នៃស្ថាប័នទាំងនេះបានបំរើជាប្រភពមួយ នៃមោទនភាព និងបានបង្ហាញអំពីភាពជោគជ័យជាក់ស្តែងពិតប្រាកដ ផ្ទុយពីតុលាការក្នុងស្រុក ដែលមានកន្លែងបំពេញការងារចាស់ លើសពីនេះទៀត សមត្ថភាពបែបមជ្ឈការផ្តល់ឱកាសយ៉ាងច្រើនសម្រាប់ការបណ្តុះបណ្តាល ការរៀបចំ និងអភិវឌ្ឍជំនាញឯកទេសដល់ដៃគូជាតិ ដែលបានជ្រើសរើសជាមុន (និងអន្តរជាតិ)។ សំខាន់ជាងនេះទៀត ដោយសារតែឧក្រិដ្ឋកម្មនានា និងជនសង្ស័យទាំងនោះកំពុងត្រូវបានជំនុំជម្រះនោះ តុលាការនេះក៏ជួយសម្របសម្រួលដល់នីតិវិធីក្នុងការពង្រឹងសន្តិសុខផងដែរ។

ការលើកឡើងជាទឡ្ហីករណ៍ប្រឆាំងនឹងរចនាសម្ព័ន្ធ បែបមជ្ឈការគឺថា គេបានបង្កើតប្រព័ន្ធយុត្តិធម៌មួយមាន២ថ្នាក់ ដោយហេតុថា មានភាពខុសគ្នាជាមួយនឹងប្រព័ន្ធច្បាប់ក្នុងស្រុកទាំងមូល។ ដោយសារតែជំហានៃបុព្វសិទ្ធិបែបនោះ អាចជាបញ្ហាពិបាកខ្លាំង ក្នុងការជះឥទ្ធិពលទៅលើប្រព័ន្ធច្បាប់ទាំងមូល ហើយអាចធ្វើឲ្យកើតជាវាទបដិវាទ ជាមួយនឹងអ្នកប្រកបវិជ្ជាជីវៈច្បាប់ជាតិ ដែលមិនបានចូលពាក់ព័ន្ធដោយផ្ទាល់។ នៅបូស្នៀ និងហឺហ្ស៊ី-ហ្គូវីណាមានគម្លាតយ៉ាងធំកើតមានឡើង រវាងទស្សនៈនៃតុលាការរដ្ឋបូ-ស្នៀ ដែលត្រូវបានគេពិពណ៌នាថា "មានលក្ខណៈទំនើបអស្ចារ្យ" បើប្រៀប-ធៀបនឹងតុលាការក្នុងស្រុក និងតំបន់។ ប្រការនេះអាចប្រៀបធៀបបានជាមួយនឹងគម្លាតកើតមានឡើងរវាងអង្គជំនុំជម្រះឧក្រិដ្ឋកម្មសង្គ្រាមនៅបូស្នៀ និងហឺហ្ស៊ីហ្គូវីណា និងនៅសាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិ សម្រាប់អតីតប្រទេសយូហ្គោស្លាវី។ ដូច្នេះ អង្គជំនុំជម្រះអាចធ្វើការគូសបញ្ជាក់អំពីចំណុចខ្វះខាតរបស់តុលាការក្នុងស្រុក ដែលមិនមានតួនាទីច្បាស់លាស់ក្នុងការពុះពារលើបញ្ហាទាំងនេះ។ ដូច្នេះហើយ ទើបមានជនជាប់ចោទ ដែលត្រូវចោទពីបទ-ល្មើសព្រហ្មទណ្ឌជាច្រើននាក់ ចង់ទទួលបានការកាត់ក្តីនៅចំពោះមុខអង្គជំនុំជម្រះ ឬក៏ប្តឹងឧទ្ធរណ៍ទៅថៅក្រមអន្តរជាតិទាំងនោះ។ បញ្ហាដូចគ្នានេះដែរគឺកើតមានពិតប្រាកដ សម្រាប់តុលាការពិសេសនៅប្រទេសសេរាឡេអូន។ ទាំងនៅទីម៉័ខាងកើត និងកម្ពុជា ភាពខុសគ្នារវាងតុលាការក្នុងស្រុក និងតុលាការកូនកាត់មានភាពស្រដៀងគ្នា ដោយសារតែគណៈវិនិច្ឆ័យពិសេស និងអង្គជំនុំ-ជម្រះវិសាមញ្ញ ដំណើរការនៅក្នុងបន្ទប់សវនាការដែលតុបតែងថ្មី ដោយមានបន្ទប់សម្រាប់ចតផ្សេងៗ និងសម្ភារៈគួរជាទីគាប់ចិត្តដ៏ទំនើបផ្សេងៗទៀតដែលតុលាការធម្មតាមិនមាន។ ឧទាហរណ៍ច្រើនទាំងនេះ បង្ហាញពីសេចក្តីត្រូវការឲ្យមានសាលសវនាការ ឬបរិវេណដ៏សមស្រប ដែលមានន័យថា ការដាក់ទី-តាំងតុលាការកូនកាត់ ក្នុងទីបរិវេណដាច់ដោយឡែកពីតុលាការក្នុងស្រុក

នោះ ដែលអាចធ្វើឲ្យអន់ថយថែមទៀត ដល់សក្តានុពលសម្រាប់កេរ្តិ៍ដំណែល ដោយការកំរិតអំពីអន្តរកម្មជាមួយនឹងបុគ្គលិកតុលាការក្នុងស្រុក។

មកដល់ពេលនេះ ឧទាហរណ៍តែមួយគត់ នៃគំរូបែបវិមជ្ឈការពិតប្រាកដគឺនៅកូសូវ៉ូ ដែលនៅទីនោះចៅក្រម និងព្រះរាជអាជ្ញាអន្តរជាតិត្រូវបានដាក់ឲ្យបំរើការងារយ៉ាងច្រើន ក្នុងតុលាការតាមតំបន់តាមបណ្តាស្រុកទាំងឡាយ។ ចៅក្រម និងព្រះរាជអាជ្ញាអន្តរជាតិមួយចំនួនបានតវ៉ាអំពីភាព-ឯកោ និងផលប៉ះពាល់លើសីលធម៌របស់គេ តែតាមពិតទៅ គំរូនៅកូសូវ៉ូអាចផ្តល់ជាវិភាគទានយ៉ាង ទូលំទូលាយថែមទៀត ចំពោះអន្តរកម្មតាមតំបន់រវាងបុគ្គលិកជាតិ និងអន្តរជាតិ។ ក្នុងករណីខ្លះ វិធីសាស្រ្តបែបនេះហាក់ដូចជាមានលទ្ធផល ហើយនិងបុគ្គលិកអន្តរជាតិមួយចំនួនបាននិយាយយ៉ាងពេញចិត្តអំពីបទពិសោធន៍ទាំងនេះ។ប៉ុន្តែក្នុងក្របខ័ណ្ឌទូទៅ ការដាក់បុគ្គលិកឲ្យបំរើការបែបនោះមិនមានលក្ខណៈតាមយុទ្ធសាស្រ្ត ហើយនិងឱកាសសម្រាប់ការបញ្ចូលរួមគ្នា ដែលត្រូវរារាំងដោយកត្តាជាច្រើន ជារួមមានការបោះបង់ចោលគណៈវិនិច្ឆ័យចំរុះឆាប់រហ័ស ដែលមានសមាសភាពបុគ្គលិកជាតិ និងអន្តរជាតិ កង្វះការបកប្រែភាសាមានគុណភាពខ្ពស់ និងកង្វះការចែករំលែកទីតាំងសម្រាប់បុគ្គលិកជាតិ និងអន្តរជាតិ។ ជាទូទៅ អ្នកជំនាញនានាបានសន្និដ្ឋានថា ផលប៉ះពាល់នៃចៅក្រម និងព្រះរាជអាជ្ញាអន្តរជាតិ លើប្រព័ន្ធច្បាប់នៅកូសូវ៉ូមានលក្ខណៈធ្វេសប្រហែសមកដល់បច្ចុប្បន្ននេះ។

នៅចុងឆ្នាំ២០០៥ ចៅក្រម និងព្រះរាជអាជ្ញាអន្តរជាតិទាំងអស់ត្រូវហៅត្រឡប់ទៅទីក្រុងព្រីស្ទីណា រដ្ឋធានីកូសូវ៉ូវិញ ហើយផែនការត្រូវបានដាក់ស្នើឡើង ដើម្បីបង្កើតសមត្ថភាពបែបមជ្ឈការ ក្នុងទម្រង់នៃអង្គជំនុំជម្រះ ឬតុលាការពិសេស ដើម្បីបង្កើតអង្គជំនុំជម្រះឧក្រិដ្ឋកម្មសង្គ្រាម។ ចៅក្រមអន្តរ-ជាតិបានជួយជ្រោមជ្រែង ក្នុងការផ្តល់ជាមតិយោបល់ចំពោះវិធីសាស្រ្តនេះ

ហើយភាគច្រើនក៏ហាក់ដូចជាពេញចិត្តដែរ។ ទោះបីជាយ៉ាងណាក៏ដោយ ចៅក្រមអន្តរជាតិ ដែលត្រូវបានហៅត្រឡប់ទៅកាន់ទីក្រុងព្រឹស្សីណាវិញនោះ និយាយថា កិច្ចសន្យាការងាររបស់គេជាមួយដៃគូ តាមតំបន់កាន់តែមានកំរិត ជាងពីមុនទៀត។

ប្រសិនបើ បុគ្គលិកអន្តរជាតិ ដែលនឹងត្រូវបានដាក់ឲ្យបំរើការងារ ដោយសារតែពួកគេស្ថិតនៅទីក្រុងកូសូវ៉ូ និងទទួលរងផលប៉ះពាល់ច្រើននា ពេលអនាគត នោះការដាក់ឲ្យបំរើការងាររបស់គេត្រូវតែធ្វើឡើងស្រមតាម យុទ្ធសាស្ត្រឲ្យបានច្រើន ព្រមទាំងអមដោយអាណត្តិនៃការកសាងសមត្ថភាព ដោយមានបទដ្ឋាន ដើម្បីវាយតម្លៃឲ្យបានច្បាស់លាស់សម្រាប់វឌ្ឍនភាព និងការប្រគល់ជូន។ ទោះបីជាដូច្នេះក៏ដោយ ប្រហែលជាវិធីសាស្ត្របែបវិម-ជ្ឈការត្រូវបានយល់ឃើញថា ជាផ្នែកមួយល្អប្រសើរនៃកម្មវិធីនីតិរដ្ឋដ៏ទូលំ-ទូលាយមួយ ជាងកេរ្តិ៍ដំណែលរបស់តុលាការកូនកាត់។ ដោយតែបញ្ហានេះ អាចត្រូវបាននិយមចូលចិត្ត ពីការផ្តល់ប្រសិទ្ធផលរួមគ្នា និងទស្សនៈកេរ្តិ៍-ដំណែល ដើម្បីអនុម័តរចនាសម្ព័ន្ធបែបមជ្ឈការ បញ្ហាទាំងនេះត្រូវតែមាន លទ្ធភាពធ្វើការបណ្តុះបណ្តាល ទាំងបុគ្គលិកខាងក្របខ័ណ្ឌជាតិប្រកបដោយ ប្រសិទ្ធភាព ដែលអាចដើរតួនាទី ដោយផ្ទាល់ជាគ្រូបណ្តុះបណ្តាលនាពេល អនាគត និងធានាឲ្យមានផលនិទស្សន៍ទូទាំងប្រទេស។

### *៣. រចនាសម្ព័ន្ធគ្រប់គ្រងបែបសមាហរណកម្ម ទល់នឹងរចនាម្ព័ន្ធ គ្រប់គ្រងខ្សែ បណ្តោយ*

ការអនុវត្តន៍ទាំងសមាហរណកម្មរដ្ឋបាលតុលាការ និងដំណើរការ រចនាសម្ព័ន្ធខ្សែបណ្តោយបានប្រែប្រួល។ ឧទាហរណ៍ អង្គជំនុំជម្រះវិសាមញ្ញ នៅប្រទេសកម្ពុជាបានអនុម័តរចនាសម្ព័ន្ធខុសគ្នា ពីតុលាការកូនកាត់ផ្សេងៗ ។ ទោះបីជា ឯកសារផែនការ សំដៅលើរចនាសម្ព័ន្ធ ដែលត្រូវបានធ្វើសមា-

ហារណកម្មទាំងសមាសភាពជាតិ និងអន្តរជាតិក៏ដោយ ក៏អគ្គលេខាធិការបានទទួលស្គាល់ថា លក្ខណៈពិសេស នៃកិច្ចព្រមព្រៀងរវាងសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាតំរូវឲ្យមានព្រំដែនដាច់ដោយឡែកពីគ្នា ក្នុងការទទួលខុសត្រូវសម្រាប់ទិដ្ឋភាពជាក់ស្តែងនៃរដ្ឋបាល ជារួមមានហិរញ្ញវត្ថុ លទ្ធកម្ម និងការជ្រើសរើសបុគ្គលិក។ ដូច្នេះ រចនាសម្ព័ន្ធខ្សែបណ្តោយ និងថវិកាដាច់ដោយឡែកត្រូវបានបង្កើតឡើងក្នុងវិស័យសំខាន់ៗទាំងឡាយ ដោយផ្អែកតាមការអនុវត្តន៍ជាក់ស្តែងបានឆ្លុះបញ្ចាំងឲ្យឃើញ អំពីការិយាល័យដ៏ពិតប្រាកដដាច់ដោយឡែកពីគ្នា សម្រាប់សមាសភាពរៀងៗខ្លួនគ្រប់អង្គភាពទាំងអស់ លើកលែងតែកម្មវិធីផ្សព្វផ្សាយដល់សហាគមន៍ និងកិច្ចការសាធារណៈចេញ។

មានសក្តានុពលសម្រាប់សមាហារណកម្ម ដ៏សំខាន់រវាងបុគ្គលិកជាតិ និងអន្តរជាតិ និងស្ថិតក្នុងរង្វង់រចនាសម្ព័ន្ធនៃអយ្យការ អង្គភាពការពារក្តី និងផ្នែកតុលាការរបស់អង្គជំនុំជម្រះវិសាមញ្ញ។ ទោះបីជាយ៉ាងណាក៏ដោយ វាអាស្រ័យទៅលើការិយាល័យរដ្ឋបាលដែលជាអង្គភាពទី១ ក្នុងការដាក់ចេញនូវរបៀបការងារនៃស្ថាបន័នោះ។ ជាទូទៅ នៅពេលណាក៏ដោយរចនាសម្ព័ន្ធសមាហារណកម្មរវាងបុគ្គលិកជាតិ និងអន្តរជាតិនេះត្រូវបានលើកទឹកចិត្តតាមដែលអាចធ្វើទៅបានក្នុងការបង្រួមឲ្យតូចបំផុត ចំពោះការញែកចេញនូវហានិភ័យស្តីពីសក្តានុពល សម្រាប់ការផ្ទេរជំនាញរវាងបុគ្គលិក និងដាក់បន្ទុកលើការិយាល័យនីមួយៗ និងបុគ្គលិកដើម្បីប្រតិបត្តិការក្នុងលក្ខណៈសមាហារណកម្មយ៉ាងពិតប្រាកដ។

## ច. ការចៀសវាងនូវកេរ្តិ៍ដំណែល "អវិជ្ជមាន"

មតិមួយចំនួនលើកឡើងថា តុលាការកូនកាត់អាចហុចលទ្ធផលកេរ្តិ៍ដំណែលអវិជ្ជមានបាន ប្រសិនបើខ្លួនប្រើប្រាស់នូវសមត្ថភាពជាតិឲ្យអស់លទ្ធភាព ក្នុងនាមជាអ្នកវិជ្ជាជីវៈក្នុងស្រុក ដើម្បីព្យាយាមពាំនាំយកទៅប្រើ-

ប្រាស់ក្នុងតុលាការកូនកាត់ ដោយបង្វែរការយកចិត្តទុកដាក់ពីការវិនិយោគ ក្នុងកំណែទម្រង់ច្បាប់ក្នុងស្រុកដ៏ចាំបាច់ ឬចូលរួមចំណែក ចំពោះទស្សនៈអវិជ្ជមាននៃប្រព័ន្ធច្បាប់ក្នុងស្រុក។

ក្តីកង្វល់ទាំងនេះមិនបានកើតមានឡើងជាចាំបាច់ ក្នុងស្ថានភាពជាក់-ស្តែង ដែលបានពិនិត្យមើលនៅទីនេះទេ។ តាមពិតទៅ ការប្រើប្រាស់ឲ្យអស់លទ្ធភាពនូវសមត្ថភាពក្នុងស្រុកពីប្រព័ន្ធក្នុងស្រុកសាមញ្ញ អាចជាបញ្ហាមួយក្នុងរយៈពេលខ្លី គឺជាបញ្ហាក្នុងកំឡុងពេលនៃអាយុកាលរបស់តុលាការកូន-កាត់តែប៉ុណ្ណោះ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏បញ្ហានេះអាចវិវត្តទៅជាក្តីកង្វល់ក្នុងរយៈពេលយូរអង្វែង ប្រសិនបើបុគ្គលិកប្រើប្រាស់នូវបទពិសោធន៍ទទួលបាន ដើម្បីរកការងារធ្វើនៅបរទេស ឬក្នុងវិស័យឯកជន ហើយនិងមិនត្រឡប់ចូលមកប្រព័ន្ធក្នុងស្រុកវិញទេ។ ជាជំរើស កេរ្តិ៍ដំណែលអវិជ្ជមានអាចនៅតែមាន ប្រសិនបើបុគ្គលិកជាតិវិលត្រឡប់ទៅកាន់ប្រព័ន្ធ ក្នុងស្រុកស្រុកវិញត្រឹមតែធ្វើឲ្យអាក់អន់ស្រពន់ចិត្ត ដោយសារតែកង្វះធនធាន និងកង្វះការរីកចំរើននោះ។

ការប្រកួតប្រជែងផ្នែកធនធានក្នុងចំណោមក្រសួង ឬស្ថាប័ននានាដ៏ក្មេងខ្ចីមានលក្ខណៈ ស្មុកស្មាញកាន់តែខ្លាំងត្រូវវិភាគ។ ការលើកឡើងទឡ្ហី-ករណ៍ដ៏ពេញនិយមនៅប្រទេសសេរ៉ាឡេអូន បានផ្តោតលើថវិកាចំនួន៨០លានដុល្លារអាមេរិច ដែលត្រូវបានចំណាយលើតុលាការពិសេសមកដល់បច្ចុប្បន្ននេះ ដែលមានមតិមួយចំនួនបានលើកឡើងថា ត្រូវចំណាយលើការលើកកម្ពស់ប្រព័ន្ធច្បាប់ក្នុងស្រុក។ ទស្សនៈស្រដៀងគ្នានេះដែរត្រូវបានលើកឡើងទាក់ទងនឹងអង្គជំនុំជម្រះផ្នែកឧក្រិដ្ឋកម្មសង្គ្រាម និងអង្គជំនុំជម្រះវិសាមញ្ញ។ ទោះបីជាយ៉ាងណាក៏ដោយ ជំហរនេះមិនគាំទ្រនូវជំហរដែល ថាថវិកាតិចតួចត្រូវចំណាយលើតុលាការកូនកាត់ ប៉ុន្តែបានតស៊ូមតិថា *ការ-*

*យកចិត្តទុកដាក់ និង ធនធានច្រើនថែមទៀត* ត្រូវកៀងគរទាំងមូលសម្រាប់ប្រព័ន្ធយុត្តិធម៌ក្នុងស្រុកក្រោយពេលសង្គ្រាម។ បញ្ហានេះគេអាចវែកញែកយ៉ាងច្បាស់ថា ក្នុងបរិបទក្រោយពេលសង្គ្រាមភ្លាមៗ ជាទូទៅក្នុងវិស័យ នេះមិនមានភាពច្បាស់លាស់ឡើយ។ មានតំរូវការយ៉ាងជាក់ស្តែង ចំពោះការវិនិយោគក្នុងពេលជាមួយគ្នានេះក្នុងតុលាការកូនកាត់ និងប្រព័ន្ធតុលាការក្នុងស្រុក ហើយជាញឹកញាប់ម្ចាស់ជំនួយនឹងផ្តល់ហិរញ្ញវត្ថុ ដល់ភាគីទាំងពីរពីប្រភពផ្តល់មូលនិធិផ្សេងៗ ដោយធ្វើការលុបបំបាត់អំពីភាពចាំបាច់ ដើម្បីជ្រើសរើសរវាងពួកគេទាំង២។

ជាគោលការណ៍ រដ្ឋាភិបាលនីមួយៗស្នើសុំនូវជំនួយពីអន្តរជាតិ ដែលត្រូវរៀបចំគំរោងក្នុងលក្ខណៈថា មិនត្រូវធ្វើឲ្យបាត់បង់នូវទំនុកចិត្តទាំងពីភាគីអន្តរជាតិ និងភាគីជាតិក្នុងប្រព័ន្ធច្បាប់ក្នុងស្រុក។ មានមធ្យោបាយសំខាន់ៗ ៣ ដែលនៅក្នុងនោះគេរំដំណៃលអវិជ្ជមានអាចត្រូវបានបង្ការៈ

ក. ការចៀសវាងការដាក់ជំនួសធនធានក្នុងស្រុកត្រង់ៗដោយធនធានអន្តរជាតិ ឬការបង្កើតប្រព័ន្ធខ្សែបណ្តោយ

ខ. ការធ្វើឲ្យបានសម្រេចនូវតុលាការកូនកាត់មួយក្នុងរង្វង់ក្របខ័ណ្ឌដែលតស៊ូមតិដោយធ្វើការពង្រឹងប្រព័ន្ធច្បាប់ក្នុងស្រុក និង

គ. ការបង្កើតផែនការហ្មត់ចត់ សម្រាប់ធ្វើការប្រគល់អង្គជំនុំជម្រះផ្នែកឧក្រិដ្ឋកម្មសង្គ្រាមបានអនុវត្តរបបតឹងរឹង សម្រាប់ធ្វើការប្រគល់ជូន។ មុខងារ នៃការិយាល័យកំណត់ហេតុនឹងត្រូវបានប្រគល់ជូនក្នុងកំឡុងពេល២ឆ្នាំ (ជាបឋមគឺត្រឹមឆ្នាំ២០០៦) ដោយសារតែចៅក្រម និងព្រះរាជអាជ្ញាត្រូវកំណត់ចាកចេញពីការិយាល័យក្នុងកំឡុងពេល៥ឆ្នាំ (គឺត្រឹមឆ្នាំ២០០៩។ វិធីសាស្ត្របែបនោះគឺជាវិធីសាស្ត្រជាក់លាក់តាមបរិបទ និងមិនអាចសមស្របបានគ្រប់កាលៈទេសៈទាំងអស់បានទេ ជាទូទៅក្នុងករណីខ្លះ គេនិយមនូវ

យុទ្ធសាស្ត្រប្រគល់ជូន ផ្អែកតាមលក្ខ័ណ្ឌជាជាងផ្អែកតាមកាលបរិច្ឆេទជាក់-លាក់។

## ឆ.ចំណាត់ចំណងវវាងកេរ្តិ៍ដំណែល និងយុទ្ធសាស្ត្របញ្ចប់

យុទ្ធសាស្ត្រកេរ្តិ៍ដំណែលដ៏មានប្រសិទ្ធភាពមួយ តំរូវឲ្យមានការរៀបចំផែនការពីដំបូង។ បញ្ហានេះនៅតែជាបញ្ហាប្រឈម ដើម្បីធ្វើការប្រមើលមើលអ្វីៗគ្រប់បែបយ៉ាងថា អាចកើតមានឡើងនាដំណាក់កាល នៃការបិទអនុភាគមន៍របស់អន្តរជាតិ ខណៈដែលអាទិភាពភ្លាមៗនោះ គឺការបង្កើតឲ្យមានតុលាការនេះ។ ទោះបីជា ការតាក់តែងយុទ្ធសាស្ត្របញ្ចប់នេះនាំមកនូវឱកាសផ្ទាល់សម្រាប់កេរ្តិ៍ដំណែលក៏ដោយ ក៏បទពិសោធន៍អន្តរជាតិបង្ហាញថាផលប៉ះពាល់ជាសក្តានុពលនោះគឺមានលក្ខណៈធំធេង ប្រសិនបើកេរ្តិ៍ដំណែលគឺជាផ្នែករួមមួយ នៃផែនការកម្មគោលនយោបាយ ដោយតាមទស្សនទានរបស់តុលាការកូនកាត់។ នៅពេលជាមួយគ្នានេះដែរ ការតាក់តែងយុទ្ធសាស្ត្របញ្ចប់អាចផ្តល់ឱកាសនានាសម្រាប់បង្កើនកម្មវិធី ក្នុងការកសាងសមត្ថភាព និងពិភាក្សាស្តីពីការពង្រឹងកេរ្តិ៍ដំណែល។

## III. ការអនុវត្តន៍កើតដំណោលៈ ការលើកកម្ពស់វប្បធម៌ នីតិរដ្ឋ និងសិទ្ធិមនុស្ស

### ក. "ផលនិទស្សន៍"៖ ផលប៉ះពាល់លើវប្បធម៌នីតិរដ្ឋ

ដោយមានកម្មវិធីផ្សព្វផ្សាយដល់សហគមន៍ ដែលទទួលបានជោគជ័យនោះ តុលាការកូនកាត់អាចបំរើជាមុខងារ លើសពីអាយុកាលរបស់ខ្លួនបាន ក្នុងការបង្កើតឲ្យមានបទដ្ឋានពិតប្រាកដ តាមរយៈផលនិទស្សន៍ ដែលធ្លាប់ប្រើប្រាស់ជាទូទៅ។ តុលាការកូនកាត់អាចរួមវិភាគទានចំពោះការផ្លាស់ប្តូរវប្បធម៌ និងតំរូវការឲ្យមានការផ្លាស់ប្តូរ ឬបង្កើននូវគណនេយ្យភាពតាមរយៈការលើកកម្ពស់សិទ្ធិកាន់តែទូលំទូលាយឡើង។ និទស្សន៍ *អំពីភាពជាធំ នៃច្បាប់* និងឯករាជភាពរបស់ខ្លួន ពីការពិចារណាផ្នែកនយោបាយនឹងដើរតួនាទីដ៏សំខាន់នៅក្នុងវិភាគទាននេះ។ សម្រាប់ហេតុផលនេះ បញ្ហាសំខាន់គឺថា ការផ្តួចផ្តើមគំនិតចំរុះ ដោយមានបំណងចង់បាននូវបទដ្ឋានខ្ពស់បំផុតនៃឯករាជភាព ភាពមិនលំអៀង និងការអនុវត្តន៍បទដ្ឋាននៃនីតិវិធីច្បាប់ និងសិទ្ធិ-មនុស្សអន្តរជាតិ។

តាមបទពិសោធន៍បង្ហាញថា ទម្រង់ប្រយោលនៃផលប៉ះពាល់នេះមិនត្រូវបានគេវិភាគឲ្យបានហ្មត់ចត់នោះទេ ប៉ុន្តែមានវិស័យជាច្រើន ឬតិច ជាក់-ស្តែង ដែលនៅក្នុងនោះផលប៉ះពាល់បែបនោះអាចត្រូវបានគេរំពឹងទុក។ អ្វីដែលសំខាន់នោះគឺថា តុលាការកូនកាត់ទំនងជាត្រូវបានគេពិនិត្យពិច័យយ៉ាងហ្មត់ចត់ ហើយត្រូវតែលើកកម្ពស់នូវបទដ្ឋានឲ្យបានខ្ពស់លើគ្រប់វិស័យទាំងអស់ នៃការអនុវត្តន៍ជាក់ស្តែង ដើម្បីបង្កើនឲ្យបានជាអតិបរមានូវផល-និទស្សន៍នេះ។ ជាសង្ខេប ខាងក្រោមនេះគឺជាឧទាហរណ៍មួយចំនួន៖

- *បទដ្ឋាននៃការជំនុំជម្រះក្តីដោយយុត្តិធម៌៖* វិធីសាស្ត្រដ៏រឹងមាំមួយចំពោះបញ្ហានានានៃការជំនុំជម្រះក្តីដោយយុត្តិធម៌ និងសមធម៌នៃសិទ្ធិអំណាចជាសក្តានុពល ដែលអាចនាំឲ្យមានការទទួលស្គាល់អំពីតួនាទីដ៏សំខាន់ ស្តីពីការការពារក្តី។ ការផ្លាស់ប្តូរវប្បធម៌ដោយផ្ទាល់នេះតំរូវឲ្យមានការផ្តល់ធនធានសមស្រប ដល់ការការពារក្តី ឧទាហរណ៍ លទ្ធភាពក្នុងការផ្តល់ឲ្យនូវជំនួយកាន់តែប្រសើរដល់ចុងចោទក្រីក្រក្នុងតុលាការជាតិ។
- *បទដ្ឋានផ្តន្ទាទោស៖* បទដ្ឋានផ្តន្ទាទោសទាក់ទងនឹងការជំនុំជម្រះ-ក្តីដោយយុត្តិធម៌ ដែលបានគូសបញ្ជាក់ដោយផ្នែកការពារក្តី ដោយរាប់បញ្ចូលទាំងការលាតត្រដាងភស្តុតាងដោះបន្ទុក ដោយមិនចាត់ការសំណុំរឿង ដែលខ្វះភស្តុតាងគ្រប់គ្រាន់ ការធានាថាជនរងគ្រោះយល់ដឹងពីសិទ្ធិរបស់គេ និងប្រព្រឹត្តទៅដោយលក្ខណៈមិនលំអៀង។
- *តម្លាភាពនៃស្ថាប័នសាធារណៈ និងកំរិតនៃវិជ្ជាជីវៈនិយម៖* ស្ថាប័នកូនកាត់ត្រូវតែបានគេយល់ថា ងាយស្រួលនឹងប្រាស្រ័យ និងមានតម្លាភាពសម្រាប់កត្តាជោគជ័យ។ មានភាពងាយស្រួលក្នុងការជួបជាមួយមន្ត្រីជាន់ខ្ពស់របស់តុលាការ និងទទួលបានព័ត៌មានច្បាស់-លាស់នឹងនាំមកនូវផលវិជ្ជមានអំពីវិធីសាស្ត្រ ដែលគេត្រូវតែស្វែងយល់ពីតុលាការ។ ការកំណត់ អំពីក្តីរំពឹងទុកដ៏ប្រាកដនិយមនូវអ្វីៗដែលតុលាការអាចសម្រេចបាន។ ភាពសមរម្យផ្នែកហិរញ្ញវត្ថុក៏ជាការពិចារណាដ៏មានសារសំខាន់ផងដែរ ដូចជាបទដ្ឋានក្រមវិជ្ជាជីវៈ និងក្រមសីលធម៌។
- *បទដ្ឋានសម្រាប់ការឃុំឃាំង និងដាក់ពន្ធនាគារ៖* វត្តមានរបស់តុ-លាការកូនកាត់អាចនាំមកនូវឱកាសនានា ដើម្បីបង្ហាញអំពីបទដ្ឋាន

អន្តរជាតិ ដែលទាក់ទងនឹងផ្នែកទទួលបន្ទុកក្នុងការឃុំឃាំង និងពន្ធនាគារ។ ពន្ធនាគារនៅតែមានលក្ខណៈធ្វេសប្រហែសដ៏ច្រើន នៅក្នុងកិច្ចប្រឹងប្រែងដើម្បីស្ថាបនាឡើងវិញ នូវប្រព័ន្ធព្រហ្មទណ្ឌក្នុងបរិបទក្រោយជម្លោះ។ បទដ្ឋានកាន់ខ្ពស់ ដែលមានប្រសិទ្ធភាពខ្ពស់ក្នុងកន្លែងឃុំខ្លួនអន្តរជាតិអាចនាំឲ្យមានការផ្លាស់ប្តូរនៅក្នុង វិស័យថ្នាក់ជាតិ ក៏ប៉ុន្តែក៏លើកឡើងអំពីបញ្ហាប្រឈម ស្តីពីទំនាក់ទំនងសាធារណៈ ដែលចាំបាច់ត្រូវគ្រប់គ្រងដោយប្រុងប្រយ័ត្ន។ ក្នុងស្ថានភាពក្រោយជម្លោះមួយចំនួន ការបង្កើតសាលាក្តី ដែលបានត្រូវស្នើឡើងណាមួយទាមទារឲ្យមានការពិភាក្សាគ្នា ស្តីពីការលុបបំបាត់ទោសប្រហារជីវិត។ ម្យ៉ាងវិញទៀត ការឃុំខ្លួនលើសនីតិវិធីនៅមុនដំណាក់កាលជំនុំជម្រះ ឬការឃុំខ្លួនបែបណាមួយ ដែលបញ្ហាដោយផ្នែកប្រតិបត្តិអាចអន្តរាយ ដល់ការគោរពសិទ្ធិមនុស្សទាំងនៅកូសូវ៉ូ និងទីម័ខាងកើត។

- *បញ្ហាយេនឌរ៖* ត្រូវមានគោលនយោបាយដ៏រឹងមាំមួយ ទាំងការផ្តន្ទាទោសលើឧក្រិដ្ឋកម្មនានា ដែលទាក់ទងនឹងយេនឌរ និងទាំងសមភាពផ្នែកយេនឌរ ក្នុងវិស័យការងារអាចនាំមកនូវវប្បធម៌ នៃការផ្លាស់ប្តូរក្នុងសង្គមនានា ដែលស្ត្រីអាចទទួលបានឋានៈសង្គមទាប។
- *ការលើកកម្ពស់កិច្ចសន្ទនាផ្នែកសិទ្ធិមនុស្ស៖* គឺជាការចូលរួមចំណែកដ៏មានសារសំខាន់ ដែលអាចលើកកម្ពស់វប្បធម៌ ដែលសិទ្ធិមនុស្សត្រូវបានគេការពារក្នុងវិស័យជាច្រើន ។ ក៏ប៉ុន្តែត្រូវចាត់វិធានការជាជំហានៗផងដែរ ដើម្បីបន្តកិច្ចសន្ទនាផ្នែកសិទ្ធិមនុស្ស នៅពេលអនាគត។ នៅប្រទេសសេរ៉ាឡេអូន តុលាការពិសេសបានចូលរួមក្នុងការបង្កើត *"វិទ្យុយុត្តិធម៌"* ជាកម្មវិធីវិទ្យុរៀបចំឡើងដោយប៊ីប៊ីស៊ី ដែលផ្តល់វេទិកាសម្រាប់កិច្ចពិភាក្សាផ្តោតលើយុត្តិធម៌ផ្សេងៗ។

- *ការមិនរើសអើង និងសមភាពក្នុងវិស័យការងារៈ* នៅប្រទេសសេរា-ឡេអូន គោលការណ៍ផ្នែកបុគ្គលិកត្រូវបានបង្កើតឡើង ដែលលើកកម្ពស់ដល់ការជួលបុគ្គលិកជាជនពិការ ដោយរាប់ទាំងជនពិការភ្នែកផងដែរ។

## ១. កម្មវិធីផ្សព្វផ្សាយដល់សហគមន៍ និងព័ត៌មានសាធារណៈ

កម្មវិធីផ្សព្វផ្សាយដល់សហគមន៍មានសារសំខាន់ ចំពោះជោគជ័យនៃផលនិទស្សន៍ ដែលត្រូវដាក់ក្នុងខ្វង់ថវិកាស្នូល នៃអនាគតរបស់តុលាការកូនកាត់។ ការស្រាវជ្រាវក្នុងបរិបទផ្សេងៗបាន បង្ហាញថា ភាពស្របច្បាប់ នៃសាលាក្តីអាចទាក់ទងគ្នា យ៉ាងជិតស្និទ្ធជាមួយនឹងទស្សនៈសាធារណៈ នៃការងាររបស់ខ្លួន។ លើសពីនេះទៀត ការស្ទង់មតិធ្វើឡើងនៅប្រទេសរ្វាន់ដា អូហ្គានដា និងសេរាឡេអូនបានបង្ហាញថា មានទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងការយល់ដឹងអំពីតុលាការ និងការគាំទ្រតុលាការ។ កម្មវិធីផ្សព្វផ្សាយដល់សហគមន៍ គឺជាមធ្យោបាយដ៏សំខាន់ ក្នុងការចូលពាក់ព័ន្ធរបស់ជនរងគ្រោះ និងដៃគូការងារផ្សេងៗ ដែលក្រៅពីនេះ មិនអាចចូលរួមជាផ្លូវការបានច្រើនក្នុងដំណើរការជំនុំជម្រះទេ។ តុលាការកូនកាត់ក៏អាចត្រូវបានគេមើលឃើញថា ជាតុលាការដែលមិនមានទំនាក់ទំនងនឹងគ្នាទាល់តែសោះ ប្រសិនបើតុលាការនេះមិនមានកម្មវិធីសហគមន៍ដ៏រឹងមាំ ដែលត្រូវជូនដំណឹងដល់សាធារណជនអំពីសកម្មភាពនានារបស់ខ្លួនទេនោះ។

កម្មវិធីផ្សព្វផ្សាយដល់សហគមន៍ ដែលជោគជ័យទាមទារឲ្យមានទាំងការទទួល និងការចែករំលែកព័ត៌មាន ព្យាយាមបញ្ចូលតុលាការនោះទៅក្នុងសង្គម។ ការផ្តល់ឲ្យនូវព័ត៌មានទាន់ហេតុការណ៍ និងសុក្រឹត្យ ដល់សាធារណៈគឺជាបញ្ហានៃគោលនយោបាយ និងតម្លាភាព ដែលជាបន្តបន្ទាប់ជួយពង្រឹងដល់ភាពស្របច្បាប់។ ទោះបីជាមានភាពមិនគ្រប់គ្រាន់ពីពេល

ដំបូងរបស់សាលាក្តីពិសេសក្នុងវិស័យនេះ ដែលគេដឹបានឮច្បាស់ហើយក៏ដោយ ក៏តុលាការកូនកាត់ទាំងនេះបានជួបប្រទះបញ្ហាប្រឈមស្រដៀងគ្នាដែរ។ ដោយអន្លើ បញ្ហានេះត្រូវបានជាប់ជំពាក់ ទៅនឹងភាពស្មាក់ស្មើរជាទូទៅ ដោយរាប់ទាំងជំនាញវិជ្ជាជីវៈច្បាប់ ក្នុងរង្វង់សាលាក្តីទាំងនោះ ដើម្បីពិនិត្យមើលពីដំណើរការជំនុំជម្រះក្តីរបស់តុលាការកូនកាត់ ជាមួយនឹងភាពខុសគ្នានៃដំណើរការក្តីព្រហ្មទណ្ឌនៅតុលាការជាតិ។ ការជំនុំជម្រះលើបទឧក្រិដ្ឋធ្ងន់ធ្ងរ និងមានសាំញ៉ាំស្មុកស្មាញ ដែលជារួមមានឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺទាមទារឲ្យមានកិច្ចសន្ទនា ជាមួយសាធារណៈដើម្បីអោយសាធារណៈជនយល់ដឹងពីនីតិវិធីរបស់វា។ ជាពិសេស នេះគឺជាករណី ដែលជាការបង្ហាញឲ្យឃើញជាសាធារណៈ ដល់ប្រព័ន្ធយុត្តិធម៌ផ្លូវការ ឬក៏សូម្បីតែកំរឹតបុគ្គលចេះអាន និងសរសេរថ្នាក់មូលដ្ឋាន ឬ ក៏អ្នកដែលមានកំរឹតអាចទាបជាងនេះក៏ដោយ។

ទោះបីជាបញ្ហានេះមិនមែនបញ្ហាចោទក៏ដោយ ក៏តុលាការកូនកាត់នឹងទាមទារឲ្យមានការពន្យល់ច្រើនជាងស្ថាប័នតុលាការ ដែលមានស្រាប់។ កិច្ចការ ដ៏មានសារសំខាន់នេះមិនត្រូវទម្លាក់លើសារព័ត៌មានជាតិ និងអន្តរជាតិ ដែលជាញឹកញាប់គ្មានលទ្ធភាពទទួលខុសត្រូវធ្វើការងារលើបញ្ហានេះឡើយ ហើយជារឿយៗទាមទារឲ្យ មានការកសាងសមត្ថភាពរបស់ខ្លួនផ្ទាល់ក្នុងតុលាការកូនកាត់នេះតែម្តង។ ខណៈដែលអង្គការក្រៅរដ្ឋាភិបាលអាចដើរតួនាទីដ៏ មានសារសំខាន់ក្នុងការពង្រឹងការលើកកម្ពស់ការយល់ដឹង និងលើកទឹកចិត្តឲ្យមានកិច្ចពិគ្រោះយោបល់អំពីតុលាការកូនកាត់ ជាបន្តបន្ទាប់ក៏ដោយ ក៏បញ្ហានេះមិនត្រូវធ្វើយុត្តិកម្ម ក្នុងការកាត់បន្ថយនូវការទទួលខុសត្រូវដោយផ្ទាល់ ក្នុងការងារធ្វើការផ្សព្វផ្សាយ ដល់សហគមន៍របស់តុលាការកូនកាត់នោះឡើយ។ សេចក្តីត្រូវការឲ្យមានកម្មវិធីផ្សព្វផ្សាយដល់សហគមន៍នឹងត្រូវបំពេញបន្ថែមដោយព័ត៌មានសាធារណៈ ហើយនិងដោយទីប្រឹក្សា

ផ្នែកព័ត៌មាន និងអ្នកនាំពាក្យ ដែលត្រូវគេបានបណ្តុះបណ្តាល។ ការិយាល័យមុខងារ សាធារណៈ របស់សាលាក្តីកូនកាត់អាចរួមចំណែកកសាងសមត្ថភាព និងចំណេះដឹងផ្នែកច្បាប់របស់សារព័ត៌មានក្នុងស្រុក ដោយរាប់ទាំងតាមរយៈធ្វើការងារជាមួយអង្គការក្រៅរដ្ឋាភិបាលផងដែរ។

***កម្មវិធីផ្សព្វផ្សាយដល់សហគមន៍ដែលមានប្រសិទ្ធភាពត្រូវពាក់ព័ន្ធ៖***

១. យុទ្ធសាស្ត្រដ៏សកម្មមួយជាមុន ដែលពុះពារកំណត់នូវក្រុមគោលដៅផ្សេងៗគ្នាក្នុងចំណោមប្រជាពលរដ្ឋ (មានក្រុមផ្នែកស្ត្រី សិស្សសាលាវិជ្ជាជីវៈច្បាប់ វិស័យឯកជន ពាណិជ្ជកម្មឯកជន។ល។)

២. វិធីសាស្ត្រទូលំទូលាយ ដែលផ្តោតលើ មិនត្រឹមតែលើព្រះរាជអាជ្ញាដែលជានិច្ចជាកាលទាក់ទាញការចាប់អារម្មណ៍ ពីសាធារណជនយ៉ាងខ្លាំង នៅដំណាក់កាលចាប់ផ្តើមដំណើរការក្តីប៉ុណ្ណោះទេ តែផ្តោតផងដែរទៅលើគ្រប់ផ្នែកទាំងអស់ នៃដំណើរការជំនុំជម្រះក្តី ដោយរាប់ទាំងសិទ្ធិទទួលការជំនុំជម្រះក្តី ដោយយុត្តិធម៌ និងមានអង្គភាពការពារក្តីដ៏មានសមត្ថភាព។ នេះរាប់ទាំងបទបញ្ញត្តិ និងការផ្សព្វផ្សាយអំពីព័ត៌មានមូលដ្ឋាន ជាបឋមឲ្យបានឆាប់តាមអាចធ្វើទៅបាន។

៣. បណ្តាញមួយ ដែលអាចផ្សព្វផ្សាយព័ត៌មានសុក្រឹត្យយ៉ាងឆាប់រហ័សគ្រប់ដណ្តប់លើតំបន់ភូមិសាស្ត្រដ៏ទូលំទូលាយ។

៤. តាមពិតទៅ ការប្រាស្រ័យទាក់ទងតាមមធ្យោបាយ២ ដែលពាក់ព័ន្ធនឹងកិច្ចសន្ទនា និងឱកាសនានាសម្រាប់ការផ្តល់មតិ ឬព័ត៌មានត្រឡប់។

បញ្ហានេះអាចមានប្រយោជន៍ផងដែរសម្រាប់តុលាការកូនកាត់ ឬអង្គការក្រៅរដ្ឋាភិបាល ដែលគាំទ្រពួកគេ ដើម្បីទទួលបានមតិ ឬព័ត៌មានត្រឡប់តាមរចនាសម្ព័ន្ធ ស្តីពីការយល់ដឹង តាមរយៈការប្រើប្រាស់ការស្ទង់មតិ ការស្ទង់មតិសាធារណៈ និងក្រុមដែលគេយកចិត្តទុកដាក់។ កាន់តែទូលំទូលាយជាងនេះ គឺយុទ្ធសាស្ត្រទាំងនេះបានឆ្លុះបញ្ចាំង ឲ្យឃើញអំពីការងាររបស់តុលាការពិសេស សម្រាប់ប្រទេសសេរាឡេអូន និងអង្គជំនុំជម្រះនៃឧក្រិដ្ឋកម្មសង្គ្រាម។

## គ. ការអភិវឌ្ឍន៍សង្គមស៊ីវិលក្នុងស្រុក

ដូចបានរៀបរាប់ខាងដើមរួចហើយ កំឡុងពេលអន្តរកាល វិធីសាស្ត្ររបស់ព្រះរាជអាជ្ញាក្នុងតុលាការកូនកាត់មានសមត្ថភាពតែមួយ ដើម្បីចូលរួមចំពោះការស្តារឡើងវិញ និងការកសាងលើវប្បធម៌មួយ ដែលគោរពនីតិរដ្ឋ និងសិទ្ធិមនុស្ស។ ភាពជាដៃគូជាមួយសង្គមស៊ីវិលគឺជាផ្នែកមួយ ដ៏មានសារសំខាន់ ក្នុងការអនុវត្តន៍កេរ្តិ៍ដំណែល។ តុលាការកូនកាត់អាចដើរតួនាទីដ៏សកម្មក្នុងការបញ្ជាក់ឲ្យបានច្បាស់អំពីតួនាទី ដ៏សំខាន់របស់សង្គមស៊ីវិលក្នុងស្រុក និងសម្រាប់ហេតុផលដ៏ពិតប្រាកដនេះ ត្រូវប្រឹងប្រែងក្នុងការដាក់សង្គមស៊ីវិលក្នុងស្រុកឲ្យពាក់ព័ន្ធដោយផ្ទាល់ ក្នុងការងាររបស់គេ។ ការពាក់ព័ន្ធបែបនោះ ក៏អាចនាំមកនូវផលប្រយោជន៍ដ៏សំខាន់ ដោយរាប់ទាំងអាចទទួលព័ត៌មាន និងភស្តុតាងដ៏មានតម្លៃអ្នកជំនាញបច្ចេកទេសបន្ថែម គាំពារផ្នែកនយោបាយ និងកម្មវិធីផ្សព្វផ្សាយដល់សហគមន៍មធ្យមបន្ថែម និងការចូលរួមរបស់សាធារណជន។ ដូចគ្នានេះដែរ លំហូរ នៃតួអង្គច្បាប់អន្តរជាតិដ៏ច្រើន ដែលតុលាការកូនកាត់អាចកៀងគរបានអាចផ្តល់ នូវផលប្រយោជន៍ដ៏មានសារសំខាន់បំផុត សម្រាប់សង្គមស៊ីវិលក្នុងក្របខ័ណ្ឌ សម្រាប់ការកសាងសមត្ថភាពបច្ចេកទេស និងបង្កើនជំហរនយោបាយ។ ក្នុងបរិយាកាសក្រោយជម្លោះ អង្គការក្រៅរដ្ឋភិបាលមាននិន្នាការកើនឡើងច្រើន ទោះបីជាអង្គការ

ទាំងនោះមិនអាចទុកចិត្ត ដោយខានមិនបានក៏ដោយ។ សម្រាប់ហេតុផលនេះនឹងមានសារសំខាន់សម្រាប់តុលាការ ក្នុងការរៀបចំផែនការស្ដីពីស្ថាន-ភាព ទូទៅរបស់សង្គមស៊ីវិល និងដើម្បីស្វែងយល់អំពីភាពស្ទាត់ជំនាញតាមទស្សនាទាន និងតាមរយៈអាណត្តិរបស់ខ្លួន។ ចំពោះបញ្ហានេះ វាមានសារ-សំខាន់ ក្នុងការបង្កើតសម្ព័ន្ធ នៃអង្គការក្រៅរដ្ឋាភិបាល ដែលស្ថិតនៅក្នុងតុលាការកូនកាត់ ដែលនឹងដើរតួនាទីជាវេទិកាប្រក្រតី សម្រាប់អន្តរកម្មរវាងតុលាការ និងសង្គមស៊ីវិល។

# IV. គន្លឹះដំណោះ៖ ការអភិវឌ្ឍន៍ធនធានមនុស្ស និងវិជ្ជាជីវៈ

ការអភិវឌ្ឍន៍សមត្ថភាពវិជ្ជាជីវៈ ក្នុងសាមីប្រទេសគឺមានការពិបាក ហើយត្រូវពឹងផ្អែកលើការលើកកម្ពស់ ដែលជោគជ័យ នៃទំនាក់ទំនងរវាងបុគ្គលិកជាតិ និងអន្តរជាតិពីដំបូង ដែលនាំមកនូវការផ្ទេរជំនាញ។ បញ្ហានេះអាចសម្រេចបាន ប្រសិនបើសាលាក្ដីកូនកាត់ (ក) ពាក់ព័ន្ធក្នុងផែនការគ្រប់-គ្រាន់ និងការវិភាគស៊ីជម្រៅអំពីបរិបទច្បាប់ជាតិ (ខ) មានដំណើរការអត្ត-សញ្ញាណកម្មហ្មត់ចត់ដើម្បី ស្វែងរកបុគ្គលិកជាតិ និងអន្តរជាតិក្នុងការចូលរួម និង(គ) ចូលរួមក្នុងកិច្ចពិគ្រោះយោបល់ជាមួយតួអង្គជាតិតាមរយៈដំណើរការនេះ។

ដំណើរការជ្រើសរើសបុគ្គលិកអន្តរជាតិ ត្រូវកំណត់បេក្ខជនទាំង-ឡាយ ដែលអាចបត់បែនបានទៅនឹងបរិយាកាសពិបាកនានា មានឆន្ទៈចាក-ចេញពីប្រព័ន្ធច្បាប់របស់ខ្លួន ប្រសិនបើចាំបាច់ និងរៀនសូត្រអំពីប្រព័ន្ធច្បាប់ក្នុងស្រុករបស់សាមីប្រទេស ហើយពេញចិត្តធ្វើការប្រកបដោយការស្ថាបនាជាមួយដៃគូក្នុងស្រុក។

## ក. ការជ្រើសរើសបុគ្គលិក

### *១. បុគ្គលិកជាតិ និងគោលនយោបាយបុគ្គលិក*

ផលវិបាកដោយផ្ទាល់ នៃជម្លោះគឺការបំផ្លិចបំផ្លាញ ការដួលរលំ ឬមហន្តរាយ នៃប្រព័ន្ធច្បាប់ និងយុត្តិធម៌។ ជាបន្តបន្ទាប់ ការជ្រើសរើសបុគ្គលិក

ជាតិឲ្យបានគ្រប់គ្រាន់ជួបប្រទះ នូវបញ្ហាប្រឈមពិតប្រាកដសម្រាប់តុលាការកូនកាត់ក្នុងបរិបទក្រោយជម្លោះ។ ភាពខុសគ្នាយ៉ាងខ្លាំង គឺថា តើការជ្រើស-រើសបុគ្គលិកនោះ សម្រាប់ឬក្នុងរង្វង់ប្រព័ន្ធតុលាការជាតិ ឬសម្រាប់តុលាការពិសេស។ គោលនយោបាយជ្រើសរើសបុគ្គលិក និងឱកាស ដើម្បីពិនិត្យមើលដោយប្រុងប្រយ័ត្ន អាចកើតមានឡើងទូទៅច្រើនទៀតនាពេលក្រោយ។ រដ្ឋបាលអន្តរកាលសហប្រជាជាតិនៅទីម័រខាងកើត នៃប្រទេសទីម័រខាងកើតបានកំពុងផ្តោតការយកចិត្តទុកដាក់បង្កើតតុលាការដំបូង ដែលមានប្រជាជនតែមួយភាគតូចប៉ុណ្ណោះត្រូវបានកំណត់ថា មានការបណ្តុះបណ្តាលផ្នែកច្បាប់ ហើយពួកគេភាគច្រើន ខ្វះបទពិសោធន៍អនុវត្តជាក់ស្តែង។ ដោយសារតែអ្នកវិជ្ជាជីវៈផ្នែកច្បាប់ ក៏ចេញមកពីដើមកំណើតនៃប្រទេសនេះផងដែរ ហើយពួកគេភាគច្រើនបានចូលកាន់តំណែងផ្សេងៗ ក្នុងភាពជាអ្នកដឹកនាំនយោបាយ។ កូសូវ៉ូបានប្រឈមនឹងបញ្ហាស្រដៀងគ្នានេះដែរ ដោយសារតែចៅក្រម និងព្រះរាជអាជ្ញាកូសូវ៉ូ ភាគច្រើនត្រូវបានបណ្តេញចេញ ពីមុខតំណែងដោយច្បាប់ ដែលមានលក្ខណៈរើសអើង។ មេធាវី ដែលជាប់កម្មសិក្សានៅសេស-សល់របស់កូសូវ៉ូ ភាគច្រើនគឺជាមេធាវីការពារក្តី។

ក្នុងស្ថានភាពបែបនោះ បន្ទាប់ពីការវាយតម្លៃបឋមរួចមក ជំហានចាំបាច់ដំបូងបំផុតគឺយុទ្ធនាការសកម្មជាមុន ដើម្បីផ្សព្វផ្សាយជ្រើសរើស និងកំណត់បេក្ខជនតំណាងថ្នាក់ជាតិ ដែលមានគុណសម្បត្តិ។ នៅទីម័រខាងកើត ខិតប័ណ្ណត្រូវចែកចាយទូទាំងប្រទេស ក្នុងកិច្ចខិតខំប្រឹងប្រែង ដើម្បីស្វែងរកបេក្ខជនមានសក្តានុពលទាំងឡាយ។ នៅប្រទេសសេរា ឡេអូន មុខតំណែងការងារត្រូវបាន ផ្សព្វផ្សាយយ៉ាងទូលំទូលាយលើទំព័រកាសែតជាតិនានា។ ជំ-រើសមួយគឺថា ត្រូវអនុវត្តនូវសកម្មភាពវិជ្ជមានចំពោះមុខតំណែងពិសេសៗ។ តុលាការពិសេសនេះរៀបចំបញ្ជីខ្លី ជាស្វ័យប្រវត្តិសម្រាប់បេក្ខជនជនជាតិសេ-រាឡេអូនសម្រាប់ធ្វើសម្ភាសន៍។ ជនជាតិសេរាឡេអូននឹងត្រូវបានតែងតាំង

ប្រសិន បើពួកគេមានគុណសម្បត្តិ តែប្រសិនបើមិនមានវិញ ព័ត៌មានត្រឡប់ពិស្តារត្រូវបានសន្និដ្ឋានថាផ្តល់ជូន ដើម្បីជួយជ្រោមជ្រែងដល់បេក្ខជនសម្រាប់ការផ្លាស់ប្តូរអាជីពការងារនាពេលអនាគត។

ក្នុងស្ថានភាពខ្លះ ចៅក្រម ឬបុគ្គលិកជាតិមិនមានគុណសម្បត្តិគ្រប់-គ្រាន់ ដើម្បីកាន់កាប់នូវការទទួលខុសត្រូវ ក្នុងការដំណើរការរឿងក្តីព្រហ្មទណ្ឌមានលក្ខណៈស្មុកស្មាញទេ។ នៅកូសូវ៉ូ នៅពេលដែលចៅក្រមបង្ហាញឲ្យឃើញដោយផ្ទាល់ថា មិនអាចដំណើរការសំណុំរឿងឧក្រិដ្ឋកម្មសង្គ្រាមបានភ្លាមៗ បេសកកម្មរដ្ឋបាលបណ្តោះអាសន្ន របស់សហប្រជាជាតិនៅកូសូវ៉ូបានដោះស្រាយបញ្ហានេះដោយការដាក់ជំនួសពួកគេដោយចៅក្រម និងព្រះរាជ-អាជ្ញាអន្តរជាតិ។ ដោយសារតែបញ្ហានេះជាបញ្ហាមានភាពចាំបាច់នាពេលនោះ ឱកាសក្នុងការកសាងប្រព័ន្ធប្រឹក្សាយោបល់ ឬការផ្ទេរសមត្ថភាពផ្សេងៗទៀត អាចត្រូវបានបាត់បង់ ដែលអាចត្រូវបានចូលរួមចំណែកយ៉ាងច្រើនដោយផ្ទាល់ ចំពោះការកសាងសមត្ថភាពក្នុងស្រុក។ លើសពីនេះទៀត ចរិតឯកតោភាគី នៃបទបញ្ជារបស់បេសកកម្មរដ្ឋបាលបណ្តោះអាសន្នរបស់សហ-ប្រជាជាតិនៅកូសូវ៉ូ និងបច្ចេកទេស ក្នុងការចាត់ចែងសំណុំរឿងឡើងវិញពីចៅក្រមជាតិ ទៅចៅក្រមអន្តរជាតិរឹតតែធ្វើឲ្យសមត្ថភាព ក្នុងស្រុកកាន់តែអន់ថយថែមទៀត ហើយបណ្តាឲ្យមានការខកចិត្តក្នុងចំណោមចៅក្រម និងមេធាវីក្នុងស្រុក។

នៅទីម័រខាងកើត ដំបូងឡើយ បំណងប្រាថ្នាគឺត្រូវពឹងផ្អែកផងដែរលើចៅក្រម និងព្រះរាជ អាជ្ញាជាតិ សម្រាប់ហេតុផលអនុវត្តន៍ជាក់ស្តែង ក៏ដូចជាហេតុជានិមិត្តរូប។ នៅពេលដែលក្តីមន្ទិលកាន់តែកើនឡើង ដែលទាក់ទងនឹងការត្រៀមខ្លួនជាស្រេចរបស់គេ ដើម្បីជំនុំជម្រះសំណុំរឿងមានលក្ខណៈស្មុកស្មាញ គណៈវិនិច្ឆ័យពិសេសត្រូវបានដាក់ឲ្យប្រើប្រាស់។ ជាថ្មីម្តងទៀត ដោយសារតែប្រព័ន្ធគណៈវិនិច្ឆ័យចម្រុះនេះ គឺបានចូលរួមចំណែក

ដោយផ្ទាល់យ៉ាងច្រើន ចំពោះការអភិវឌ្ឍន៍សមត្ថភាព ក្នុងចំណោមចៅក្រមទីម៉ខាងកើតទាំងជំនាញផ្នែកច្បាប់ និងភាសា ហើយចរិតឯកតោភាគី នៃសេចក្ដីសម្រេចបណ្ដាលឲ្យមានការអាក់អន់ចិត្ត និងត្រូវបានគេមើលឃើញថាជាការអត្ថាធិប្បាយទៅលើប្រព័ន្ធនៅទីម៉ខាងកើត។

នៅប្រទេសកម្ពុជា រចនាសម្ព័ន្ធទាំងមូលនៃអង្គជំនុំជម្រះវិសាមញ្ញឆ្លុះបញ្ចាំងឲ្យឃើញអំពីកង្វះទំនុកចិត្ត ពីសហគមន៍អន្តរជាតិមកលើប្រព័ន្ធច្បាប់កម្ពុជា។ បញ្ហានេះស្ដែងចេញជាភស្ដុតាងដោយយន្តការ "មតិភាគច្រើនដាច់ខាត" សម្រាប់សេចក្ដីសម្រេចរបស់តុលាការ ដែលនៅក្នុងនោះ យ៉ាង-ហោចណាស់ ក៏សំលេងរបស់ចៅក្រមអន្តរជាតិម្នាក់ត្រូវការចាំបាច់ផងដែរ។ ភស្ដុតាងជាក់ស្ដែងផងដែរ គឺថា ក្នុងសេចក្ដីសម្រេចមួយត្រូវទាមទារឲ្យមានសហព្រះរាជអាជ្ញាជាតិ និងអន្តរជាតិ សហចៅក្រមជាតិ និងអន្តរជាតិ (ដោយមានអង្គបុរេជំនុំជម្រះពិសេសដោះស្រាយជម្លោះណាមួយ)។ ទោះបីជា យន្ត-ការនេះទទួលបានជោគជ័យ ក្នុងការរារាំងការជ្រៀតជ្រែកផ្នែកនយោបាយក៏ដោយ ក៏រចនាសម្ព័ន្ធ ដែលទទើសទទែងនេះទំនងជាបណ្ដាលឲ្យមិនអាចសម្រេចផលបាន និងមានភាពស្មុកស្មាញ។

ជាទូទៅ សេចក្ដីសម្រេចទាំងឡាយ ចំពោះវិសាលភាព នៃការពាក់-ព័ន្ធរបស់អន្តរជាតិត្រូវធ្វើឡើងក្នុងវិធីនានា ដែលមិនធ្វើឲ្យបង្អន់នូវទំនុកចិត្តក្នុងចំណោមអ្នកវិជ្ជាជីវៈច្បាប់ក្នុងស្រុក ហើយត្រូវផ្ដោតលើការតាក់តែងយុទ្ធ-សាស្ត្រ ដើម្បីកសាងសមត្ថភាពក្នុងស្រុកពីដំបូង។ យុទ្ធសាស្ត្រទាំងនេះ រាប់-ទាំងការដាក់អ្នកវិជ្ជាជីវៈជាតិក្នុងតំណែងនានា ដែលពួកគេអាចប្រមែប្រមូលបទពិសោធន៍អនុវត្តន៍ជាក់ស្ដែង ដោយមិនទទួលយកនូវការទទួលខុសត្រូវពេញលេញឡើយ។

ដោយសារតែរាល់កិច្ចប្រឹងប្រែងត្រូវធ្វើឡើង ដើម្បីកំណត់បេក្ខជនជាតិ ដែលមានគុណសម្បត្តិ នោះកិច្ចប្រឹងប្រែងក៏ត្រូវសម្រេចផងដែរ ដើម្បី

ជំរុះចោល ឬពិនិត្យមើលដោយប្រុងប្រយ័ត្ននូវបេក្ខជនទាំងឡាយ ដែលមិនសមរម្យ ដោយត្រូវចងចាំក្នុងចិត្ត អំពីសេចក្ដីត្រូវការក្នុងការធានាឲ្យមានឯក-រាជភាពផ្នែកតុលាការ។ តុលាការនឹងអាចនឹងជំរុះចោលបេក្ខជនបែបនោះតាមរយៈដំណើរការនៃការជ្រើសរើសបុគ្គលិក ក្នុងស្ថានភាពដែលតុលាការជ្រើសរើសបុគ្គលិកដោយផ្ទាល់ ប៉ុន្តែបញ្ហានេះ មានការពិបាកច្រើនក្នុងការ-ពិនិត្យដោយប្រុងប្រយ័ត្ននូវបេក្ខជនទាំងឡាយ ដែលបានដាក់ស្នើដោយអាជ្ញាធរក្នុងស្រុក។ តួយ៉ាងដូចជា នៅប្រទេសកម្ពុជា ឧត្តមក្រុមប្រឹក្សាជាតិនៃអង្គចៅក្រមទទួលខុសត្រូវ ក្នុងការតែងតាំងទាំងបេក្ខជនអន្តរជាតិ ស្នើសុំដោយសហប្រជាជាតិ ក៏ដូចជាបេក្ខជនជាតិពីរដ្ឋាភិបាល នៃប្រទេសកម្ពុជា។ សហប្រជាជាតិរៀបចំបញ្ជីតែងតាំងបេក្ខជនអន្តរជាតិ ដែលអាចដឹងបានជាមុនជាសាធារណៈ ដូច្នេះហើយអាចឲ្យសាធារណជនធ្វើការពិនិត្យពិច័យអំពីបេក្ខជនទាំងនោះ ប៉ុន្តែបញ្ជីតែងតាំងបេក្ខជនកម្ពុជាមិនបញ្ចេញជាសាធារណៈបានស្រដៀងគ្នាឡើយ។

### *២. បញ្ហាប្រឈមនានាចំពោះការជ្រើសរើសបុគ្គលិក*

ជាក់ស្ដែង ដោយសារតែការជ្រើសរើសបុគ្គលិក ផ្នែកអន្តរជាតិមិនអាចជាក្ដីកង្វល់ច្រើនផ្នែកកេរ្ដិ៍ដំណែល ដូចការការជ្រើសរើសបុគ្គលិកជាតិ តែក៏បញ្ហានេះនៅតែមានសារសំខាន់។ សក្ដានុពល សម្រាប់ផលប៉ះពាល់ទាំង-មូល និងកេរ្ដិ៍ដំណែលនឹងត្រូវកាត់បន្ថយ ប្រសិន បើការជ្រើសរើសបុគ្គលិកអន្តរជាតិបរាជ័យក្នុងការកំណត់បេក្ខជនបានល្អៗទាន់ពេលវេលា។

ការជ្រើសរើសបុគ្គលិកអន្តរជាតិ គឺជាបញ្ហាប្រឈមដ៏ជាក់ស្ដែងមួយសម្រាប់តុលាការកូនកាត់ ទាំងក្នុនៅងក្របខ័ណ្ឌស្វែងរកបេក្ខជន ដែលមានគុណសម្បត្តិ និងការដាក់ឲ្យដំណើរការនូវរចនាសម្ព័ន្ធ ក្នុងការជ្រើសរើសបុគ្គលិកដ៏មានសមត្ថភាព ហើយមតិមួយចំនួនបានសំដៅដល់ភាពបរាជ័យ

ជាប្រព័ន្ធក្នុងវិស័យនេះ។ ការជ្រើសរើសបុគ្គលិកអន្តរជាតិក្រោមកិច្ចឧបត្ថម្ភរបស់លេខាធិការដ្ឋានរបស់សហប្រជាជាតិ ភាគច្រើនបំផុតអនុវត្តចំពោះការតែងតាំងបុគ្គលិកជាន់ខ្ពស់ ដោយរាប់ទាំងចៅក្រមសម្រាប់តុលាការពិសេស និងអង្គជំនុំជម្រះវិសាមញ្ញ ដែលជាញឹកញាប់មានលក្ខណៈយឺតយ៉ាវ និងពឹងផ្អែកលើរដ្ឋសមាជិកដាក់ស្នើបេក្ខជន ដែលមានគុណសម្បត្តិ។ ការជ្រើស-រើសបុគ្គលិកត្រូវបានធ្វើឡើង ក្រោមការទទួលខុសត្រូវផ្ទាល់ នៃបេសកកម្មរក្សាសន្តិភាពនៅកូសូវ៉ូ និងទីម៉ខាងកើត។ ទោះបីជាយ៉ាងណាក៏ដោយ ដំណើរ-ការទាំងនេះមិនតែងតែទទួលបានលទ្ធផលនូវបេក្ខជនណា ដែលមានគុណ-សម្បត្តិគួរជាទីពេញចិត្តបំផុតនោះទេ។ ចំណែកឯការផ្សព្វផ្សាយជ្រើសរើសបុគ្គលិក សម្រាប់តំណែងនៅទំនេរវិញ តុលាការពិសេសសម្រាប់ប្រទេសសេ-រ៉ាឡេអូនបានប្រកាន់ខ្ជាប់ នូវការរៀបចំបញ្ជីឈ្មោះដាក់លើវ៉េបសាយផ្ទាល់របស់ខ្លួន ដោយមិនស្ថិតក្រោមកម្មវត្ថុនៃនិយតកម្មបុគ្គលិករបស់សហប្រជាជាតិ ដែលធ្វើឲ្យដំណើរការជ្រើសរើសបុគ្គលិករបស់ខ្លួន មានលក្ខណៈអាចបត់-បែនបានកាន់តែច្រើនថែមទៀត។

ទោះបីជាយ៉ាងណាក៏ដោយ ការកំណត់យកកន្លែងផ្សព្វផ្សាយជ្រើស-រើសបុគ្គលិកដ៏មានប្រសិទ្ធភាព ការទទួលបានពាក្យសុំធ្វើការពីបេក្ខជន ដែលមានបទពិសោធន៍សមស្រប និងការទទួលបានតុល្យភាពផ្អែកយេនឌរ គឺជាបញ្ហាប្រឈមសម្រាប់សាលាក្តីកូនកាត់ទាំងអស់។ កត្តាទាំងអស់នេះ គឺជាផលប៉ះពាល់ដ៏ធំធេងលើគុណភាព នៃយុទ្ធសាស្ត្រ និងដំណើរការនីតិវិធីនៅក្នុងតុលាការកូនកាត់ ជាញឹកញាប់គឺការផ្តល់ផលវិបាកអវិជ្ជមាន ដូចជាការបដិសេធន៍ចោលសាលក្រម។ លើសពីនេះទៀត ភាពមិនលំអៀងនៃបុគ្គលិកអន្តរជាតិមិនត្រូវគេសន្មត់ជាមុនឡើយ ហើយប្រវត្តិរបស់បុគ្គល ម្នាក់ៗក៏ត្រូវតែពិនិត្យ។ ការពិនិត្យលើបេក្ខជនកំឡុងពេលនៃការជ្រើសរើសបែបនោះនឹងទាមទារឲ្យមានការវាយតម្លៃក្នុងកំរិតមួយ ទាំងដោយបុគ្គលមានឋានៈស្មើគ្នា

ឬស្ថាប័នវិជ្ជាជីវៈ  តួយ៉ាងដូចជា  ត្រូវមានវត្តមានចៅក្រម  និងព្រះរាជអាជ្ញា ក្នុងសមាសភាពគណៈកម្មការសម្ភាសន៍ នៅពេលធ្វើការជ្រើសរើសចៅក្រម និងព្រះរាជអាជ្ញា។ បញ្ហាមួយទៀត ដែលទាក់ទងនឹងបុគ្គលិកអន្តរជាតិគឺការ បំរើ សេវាកម្មរយៈពេលខ្លី និងការផ្លាស់ប្តូរភ្លាមៗក្នុងកំរឹតមួយខ្ពស់។ ចៅក្រម អន្តរជាតិអះអាងថា ការកាន់ កាប់តំណែងរយៈពេលខ្លី ផ្តល់ឱកាសចូលរួមក្នុង ការកសាងសមត្ថភាពតែឯង គឺជាការគំរាមគំហែង ចំពោះឯករាជភាពរបស់គេ និងបង្អាក់សមត្ថភាពរបស់គេ  ដែលផ្តោតលើការងារក្នុងដៃ  ។ កិច្ចសន្យាត្រូវ ផ្តល់ឲ្យយ៉ាងហោចណាស់ក៏រយៈពេល១ឆ្នាំ និងអាចបន្តទៀតដោយផ្អែកលើ សកម្មភាពការងារ ស្របតាមការវាយតម្លៃការងារជាប្រចាំ ដោយយោងលើការ អនុវត្តសកម្មភាពការងាររបស់ចៅក្រម។

សហប្រជាជាតិកំពុងតែពិចារណាធ្វើការតាក់តែងនូវបញ្ជីឈ្មោះមួយ នៃបេក្ខជន  ដែលមានសក្តានុពលសម្រាប់តំណែងនីតិរដ្ឋ។  បញ្ជីឈ្មោះនោះ អាចត្រូវបានពង្រីក   ដើម្បីបញ្ចូលតំណែងផ្នែក   តុលាការក្នុងតុលាការអន្តរ-ជាតិ  ឬតុលាការកូនកាត់។ មតិមួយចំនួនលើកឡើងថា  បុគ្គលិកអន្តរជាតិ មួយក្រុមជាអចិន្ត្រៃយ៍គួរត្រូវបង្កើតឡើង  ជាឧបាស្រ័យទីមួយសម្រាប់ស្ថាន-ភាពថ្មី។   ទោះបីជាយ៉ាងណាក៏ដោយ   ទោះបីជាមានបញ្ជីឈ្មោះរួចហើយក្តី ក៏នៅតែពិបាកធ្វើអោយប្រសើរឡើង នូវប្រព័ន្ធបន្ថែមមួយ ដែលល្អប្រសើរ សម្រាប់ការជ្រើសរើសចៅក្រម   ព្រះរាជអាជ្ញា   និងមន្ត្រីរដ្ឋបាលជាន់ខ្ពស់អន្តរ-ជាតិ ដែលត្រូវបានផ្គត់ផ្គង់ធនធានឲ្យបានសមស្រប ដោយមិនប្រើប្រាស់វិធី-សាស្រ្តទាក់ទងគ្នាច្រើនថែមទៀតឡើយ។ ប្រព័ន្ធនោះនឹងទាមទារឲ្យមាន កំរិតនៃភាពបត់បែនមួយ   ដែលធម្មតាមិនអាចរកបានក្នុងក្របខ័ណ្ឌបទបញ្ជា បុគ្គលិកសហប្រជាជាតិ។ ដំណោះស្រាយមួយអាចជាសមត្ថភាពថ្មី និងដាច់ ដោយឡែកមួយក្នុងរង្វង់   ឬអមលេខាធិការដ្ឋានសហប្រជាជាតិ   ដែលនឹង ត្រូវតាក់តែងប្រព័ន្ធពាក្យស្នើសុំ  ដែលស៊ីសង្វាក់គ្នាមួយ  ដែលត្រូវបានគេ

ស្វែងរកដោយសកម្មជាមុននូវបេក្ខជនទាំងឡាយ និងប្រតិបត្តិនូវកំរឹតប្រៀប-ធៀបនៃគុណវុឌ្ឍិ។ បញ្ហានេះត្រូវបង្កើតនូវអង្គភាពជំនាញផ្សេងៗ ដូចជាគណៈកម្មការតុលាការអន្តរជាតិសម្រាប់ការតែងតាំង (ហើយក៏អាចជាបញ្ហាវិន័យ)។ ដំណោះស្រាយមួយទៀត ចំពោះទ្វេគ្រោះនេះគឺអាចជាការពង្រីក និងការសម្របសម្រួល នៃសមត្ថភាពឆ្លើយតបឆាប់រហ័ស ផ្នែកតុលាការជាឧបតោភាគី ដែលត្រូវបានបង្កើតឡើងតាមបណ្តារដ្ឋនានា ដូចជាណរវ៉េ។

ទិដ្ឋភាពសំខាន់ៗ២ផ្សេងទៀត នៃផលនិទស្សន៍ ក្នុងការជ្រើសរើសបុគ្គលិកផ្នែកតុលាការអន្តរជាតិ គឺតម្លាភាព និងភាពមិនលំអៀងរបស់ខ្លួន។ នេះគឺជាសារសំខាន់ដ៏ពិសេស ដែលទាក់ទងនឹងកង្វះទំនុកចិត្តពីសាធារណៈ-ជន ក្នុងដំណើរការតែងតាំងបុគ្គលិករបស់តុលាការក្នុងស្រុក។ ប្រព័ន្ធមួយសម្រាប់ការកំណត់គុណវុឌ្ឍិ ដែលខានមិនបានត្រូវបញ្ចូលកិច្ចពិគ្រោះយោ-បល់ជាមួយដៃគូជាតិនានា។ អាចនឹងមានតួនាទីសម្រាប់សង្គមស៊ីវិលក្នុងការអត្ថាធិប្បាយលើបញ្ជីបេក្ខជន ដែលត្រូវបានតែងតាំង។

កង្វះគណនេយ្យភាព ដែលបានគេសង្កេតឃើញកកំឡុងពេលកាន់-កាប់មុខតំណែងរបស់បុគ្គលិកអន្តរជាតិ គឺប្រហែលជាផ្តល់ផលប៉ះពាល់ជាអវិជ្ជមានលើកេរ្តិ៍ដំណែល។ ទោះបីជាក្នុងដំណើរការជ្រើសរើសបុគ្គលិកគឺជាប្រពៃណី ដែលយ៉ាងហោចណាស់ក៏ត្រូវពិគ្រោះយោបល់ជាមួយដៃគូការងារក្នុងស្រុកមុនពេលនៃការតែងតាំងក៏ដោយ ក៏ជាទូទៅបុគ្គលិកអន្តរជាតិមិនស្ថិតក្រោមកម្មវត្ថុនៃស្ថាប័ននានាក្នុងស្រុក ដូចជាក្រុមប្រឹក្សាតុលាការជាន់-ខ្ពស់ ឬគណៈមេធាវីរបស់សាមីប្រទេសនោះឡើយ។ បញ្ហានេះ ក៏មានការលំបាក ដែលត្រូវដាក់បុគ្គលិកផ្នែកច្បាប់អន្តរជាតិ ក្រោមស្ថាប័នជាតិបែបនោះសម្រាប់ការជ្រើសរើសបុគ្គលិក ឬវិន័យ ទោះបីជាយ៉ាងណាក៏ដោយអំឡុងពេលអវត្តមាននៃសមមូលអន្តរជាតិ ជំរើសផ្សេងៗ ដែលពេញចិត្តនោះអាចយកមកប្រើប្រាស់ជាសំអាង ក្នុងទម្រង់ នៃក្រមសីលធម៌ ហើយមាន

ឧទាហរណ៍ជាច្រើនអាចរកបាននៅក្នុងសាលាក្តីពិសេសនានា។ ក្រមសីលធម៌ស្រដៀងគ្នាដែរត្រូវបានដាក់បញ្ចូលក្នុងអាណត្តិ ជាផ្នែកមួយ នៃលក្ខ័ណ្ឌសេវាកម្មអន្តរជាតិ ដោយរាប់បញ្ចូលទាំងចៅក្រមផងដែរ។ បញ្ហាក្នុងការធានាឲ្យមានកំរឹត នៃការទទួលខុសត្រូវ និងភាពស៊ីសង្វាក់គ្នាខ្ពស់រវាងស្ថាប័ននានា ជាពិសេសស្ថាប័នទាំងឡាយ ដែលមានការពាក់ព័ន្ធជាមួយសហប្រជាជាតិ ចាំបាច់ត្រូវលើកឡើងដំណោះស្រាយ កំឡុងពេលនៃអវត្តមានរបស់ស្ថាប័នវិន័យអន្តរជាតិ។ ការវាយតម្លៃ នៃការជ្រើសរើសបុគ្គលិកត្រូវស្វែងរកបេក្ខជនទាំងឡាយ ដែលអាចបង្ហាញថា ពួកគេអាចបំពេញការងារក្នុងបរិយាកាសពហុវប្បធម៌បាន និងអត់ធ្មត់បានទៅនឹងបញ្ហាប្រឈមនានាក្នុងការបំពេញការងារជាមួយបុគ្គលទាំងឡាយពីសញ្ជាតិ និងសាវតារផ្សេងៗ តាមអ្វីៗដែលទាមទារដោយចរិតការងារបែបនោះ។

## *៣. លក្ខ័ណ្ឌនានានៃការតែងតាំង សេវាកម្ម និងលាភការ*

ប្រភពនៃភាពតានតឹងក្នុងតុលាការកូនកាត់ គឺលក្ខ័ណ្ឌការងារខុសគ្នាយ៉ាងធំធេងរវាងបុគ្គលិកអន្តរជាតិ និងជាតិ។ បញ្ហានេះ អ្វីជានិទ្នាការជាក់លាក់បំផុតនោះគឺកម្រិតប្រាក់ខែ។

នៅប្រទេសកម្ពុជា រដ្ឋាភិបាលបានធ្វើការប្តេជ្ញាចិត្តថា បុគ្គលិកជាតិ នៃអង្គជំនុំជម្រះវិសាមញ្ញ ដែលត្រូវទទួលបានប្រាក់ខែពាក់កណ្តាលនៃប្រាក់ខែ ដែលដៃគូអន្តរជាតិរបស់គេទទួលបាន ដោយទទួលបានច្រើនជាងដៃគូការងារក្នុងស្រុកយ៉ាងធំធេង។ ទោះបីជាយ៉ាងណាក៏ដោយ មុខតំណែងរបស់មេធាវីការពារក្តីនៅតែមិនច្បាស់លាស់។

នៅប្រទេសសេរាឡេអូន មុខតំណែងត្រូវបានចាត់ជាថ្នាក់ ហើយមិនមែនបុគ្គលទេ ទាំងមុខតំណែងជាតិ និងអន្តរជាតិ ឧទាហរណ៍ មេធាវីចូលរួមក្នុងការជំនុំជម្រះក្តីនៅក្នុងការិយាល័យព្រះរាជ អាជ្ញាត្រូវបានចាត់ជាថ្នាក់

ជាមុខតំណែងអន្តរជាតិ ទោះបីគាត់ជាជនជាតិសេរ៉ាឡេអូនក៏ដោយ។ ដូច-គ្នានេះដែរ ក៏អនុវត្តចំពោះមុខតំណែងកំរិតខ្ពស់ជាច្រើនទៀតផងដែរនៅក្នុងការិយាល័យបញ្ជិកា ដូច ជាប្រធានផ្នែក ហើយចៅក្រមទាំងអស់ត្រូវបានផ្តល់បៀវត្សរ៍ដូចគ្នា។ ជាញឹកញាប់ ប្រាក់លើកទឹក ចិត្តត្រូវបានប្រើប្រាស់ផងដែរដើម្បីបំពេញនូវភាពចន្លោះប្រហោងក្នុងភាព ខុសគ្នានៃប្រាក់បៀវត្សរ៍។ ដោយសារតែវិធីសាស្ត្រនេះនាំមកនូវទំនាក់ទំនងល្អប្រសើររវាងជាតិ និងអន្តរជាតិក្នុងតុលាការ ពិសេស បញ្ហានេះនៅតែបង្កើតឲ្យមានអសមត្ថភាពជាមួយអ្នកវិជ្ជាជីវៈ នៅក្នុងប្រព័ន្ធច្បាប់ក្នុងស្រុក ដោយសារប្រាក់បៀវត្សរ៍សម្រាប់ចៅ-ក្រមតុលាការខុសគ្នា១២ដងនៃចៅក្រមជាតិ។

## ១. ការអភិវឌ្ឍន៍វិជ្ជាជីវៈ

ជាធម្មតា ការអភិវឌ្ឍន៍វិជ្ជាជីវៈត្រូវបានគេកំរិត ចំពោះបុគ្គលទាំង-ឡាយណា ដែលបំរើការងារ ដោយផ្ទាល់ក្នុងរចនាសម្ព័ន្ធកូនកាត់ ទោះបីជាមានគំរូវិជ្ជមានមួយចំនួនអំពីការបណ្តុះបណ្តាលយ៉ាងទូលំទូលាយ ឬបំណងប្រាថ្នាដើម្បីពង្រីកការផ្តួចផ្តើមគំនិត ចំពោះដៃគូការងារក្នុងស្រុកក៏ដោយ។ នៅគ្រប់ស្ថានភាព ការផ្តួចផ្តើមគំនិតអំពីកេរ្តិ៍ដំណែល ទំនងជាទទួលជោគជ័យតិចតួច ប្រសិន បើមិនមានការប្តេជ្ញាចិត្តផ្នែករដ្ឋបាលដ៏រឹងមាំ ឬមិនមានបុគ្គលិកធ្វើពលិកម្ម ដើម្បីបំរើការងារជាជនបង្គោលដែលមានចំណេះដឹងអំពីប្រព័ន្ធច្បាប់ក្នុងស្រុក ដើម្បីផ្តល់ការប្រឹក្សាយោបល់ និងរៀបចំការផ្តួចផ្តើមគំនិត។ នៅប្រទេសសេរ៉ាឡេអូន ជនបង្គោលសម្រាប់កេរ្តិ៍ដំណែលត្រូវបានតែងតាំងឡើង ហើយរបាយការណ៍រដ្ឋាភិបាលត្រូវបានព្រាងឡើង ក៏ប៉ុន្តែមិនមែនរហូតដល់ឆ្នាំ២០០៤-២០០៥ទេ។ ក្រុមការងារស្តីពីកេរ្តិ៍ដំណែលត្រូវបានកោះមកប្រជុំផងដែរ។ ក្រុមការងារនេះមានសមាជិកពីផ្នែកផ្សេងៗ របស់តុលាការពិសេស រាប់បញ្ចូលទាំងព្រះរាជអាជ្ញា ក្រុមការពារក្តី ការិយាល័យបញ្ជិកា និងអង្គជំនុំជម្រះ ព្រមទាំងសមាជិកបុគ្គលិកជាតិរបស់តុលាការពិសេស។

*១. ក្រុម ឬគណៈវិនិច្ឆ័យចម្រុះ*

មានមតិព្រមព្រាងគ្នាជាទូទៅមួយ ដែលបានមកពីបទពិសោធន៍ក្នុងប្រទេសផ្សេងៗគ្នា ដែលជាការតាំងនៅនៃអង្គភាពជាច្រើននៅកន្លែងមួយ និងឱកាសបំពេញការងារក្នុងក្រុម ឬគណៈវិនិច្ឆ័យចម្រុះជួយលើកទឹកចិត្តដល់គេក្តីដំណែល។ ទោះបីជាយ៉ាងណាក៏ដោយ ដោយសារតែអន្តរកម្មជាមួយដៃគូការងារ (ទាំងជាតិ និងអន្តរជាតិ) អាចផ្តល់នូវឱកាសដ៏មានតម្លៃសម្រាប់ការអភិវឌ្ឍន៍វិជ្ជាជីវៈ តាមបទពិសោធន៍ បង្ហាញថា យ៉ាងហោចណាស់ អន្តរ-កម្មបែបនោះគឺជាអន្តរកម្មពិសេស ហើយចាំបាច់ត្រូវគ្រប់គ្រងដោយប្រុងប្រយ័ត្នដើម្បីទទួលបានផលប្រយោជន៍។

បំពេញការងារក្នុងក្រុម ឬគណៈវិនិច្ឆ័យចម្រុះ ហើយនិងការចែករំលែកទីតាំងការិយាល័យអាចផ្តល់ឲ្យនូវឱកាសជាច្រើន ក៏ប៉ុន្តែក៏បង្កើតឲ្យមានបញ្ហាប្រឈមជាច្រើនផងដែរ ដោយរាប់បញ្ចូលទាំងឧបសគ្គផ្នែកភាសា។ បញ្ហានេះគឺជាបញ្ហាពិបាកសម្រេចបាននូវកំរិតសមស្របមួយ នៃសមាហរ-ណកម្ម និងទាមទារឲ្យមានយុទ្ធសាស្រ្តពិសេសៗ។ ឧទាហរណ៍ រចនាសម្ព័ន្ធរដ្ឋបាលស្របគ្នា ជាជាងរចនាសម្ព័ន្ធរដ្ឋបាលបែបសមាហរណកម្ម ដែលប្រហែលជាឧបសគ្គ។ ជាពិសេសទៀត ក្នុងរចនាសម្ព័ន្ធតុលាការកូនកាត់ដូចជា អង្គជំនុំជម្រះឧក្រិដ្ឋកម្មសង្រ្គាម ឬក្នុងករណីនៅកូសូវ៉ូ លទ្ធភាពមិនគ្រប់-គ្រាន់ ចំពោះការបកស្រាយផ្នែកច្បាប់ធ្វើឲ្យសេចក្តីសម្រេចទាំងឡាយ និងការផ្លាស់ប្តូរយ៉ាងទូលំទូលាយ មានលក្ខណៈកាន់តែពិបាកច្រើនគួរឲ្យកត់សំគាល់។ នៅកូសូវ៉ូ ដោយមានក្តីរំពឹងខ្លះៗ ដូចជានៅតុលាការស្រុកនៅមីត្រូកា និងតុលាការកំពូល ការិយាល័យថៅក្រម និងព្រះរាជអាជ្ញាអន្តរជាតិ ស្ថិតនៅក្នុងអគារដាច់ដោយឡែកពីគ្នាពីថៅក្រមជាតិ។ បុគ្គលិកជាតិមួយចំនួននិយាយថា ពួកគេស្វាគមន៍ឲ្យមានអន្តរកម្មច្រើនថែមទៀត។ នៅទីម៉ខាងកើត ការិយា-

ល័យទាំងឡាយប្រើរួមគ្នាបានលើកទឹកចិត្ត ឲ្យមានការផ្លាស់ប្តូរក្រៅផ្លូវការ។ កិច្ចប្រជុំជាប្រក្រតី និងអ្នកបកប្រែ ដែលបានធ្វើពលិកម្ម ចំពោះអង្គជំនុំជម្រះតុលាការបានបង្ហាញឲ្យឃើញអំពីផលប្រយោជន៍ដ៏ធំធេង។

នៅក្នុងតុលាការកូនកាត់ភាគច្រើន ការផ្តល់នូវការប្រឹក្សាយោបល់អំពីបុគ្គលិកក្នុងស្រុកមិន ត្រូវបានពិចារណាថា ជាផ្នែកមួយនៃការងាររបស់បុគ្គលិកអន្តរជាតិនោះទេ ហើយពួកគេអះអាងថា ពួកគេមិនមានពេលវេលាគ្រប់គ្រាន់សម្រាប់ការងារបន្ថែមនេះទេ។ ដូច្នេះ ការងារបន្ថែមបែបនេះនឹងបរាជ័យចំពោះបុគ្គល និងពឹងផ្អែកភាគច្រើនលើបុគ្គលិកលក្ខណៈ។ ជាមួយនឹងសារប្រយោជន៍ ដែលអាចទទួលបានពីកម្មវិធីប្រឹក្សាយោបល់ គេបានផ្តល់ជាគំនិតថា ត្រូវបង្កើតកម្មវិធីប្រឹក្សាយោបល់ឲ្យបានច្រើន ជាផ្នែកមួយនៃកេរ្តិ៍-ដំណែលកំពុងបន្តធ្វើ ដែលត្រូវជ្រើសរើសអ្នកប្រឹក្សាយោបល់ពីបុគ្គលិកអន្តរ-ជាតិ ដែលត្រូវបានជ្រើសរើសមកបំរើការងារនៅតុលាការកូនកាត់ លើវិស័យជាក់លាក់មួយចំនួន ដែលផ្សារភ្ជាប់ទៅនឹងប្រព័ន្ធត្រួតពិនិត្យគួរទុកចិត្តបាន និងមានបទដ្ឋានវាយតម្លៃច្បាស់លាស់។

### *២. កម្មវិធីបណ្តុះបណ្តាល*

ការតវ៉ាជារួមនៅក្នុងតុលាការកូនកាត់ទាំងឡាយ គឺអវត្តមាននៃវិធី-សាស្រ្តដែលទាក់ទងគ្នា ចំពោះការបណ្តុះបណ្តាល ទាំងសម្រាប់ថៅក្រមជាតិ និងអន្តរជាតិ។ ដំបូងឡើយ ការផ្តោតយកចិត្តទុកដាក់ជាបឋមលើកម្មវិធីបណ្តុះបណ្តាល នៅក្នុងតុលាការកូនកាត់មកដល់បច្ចុប្បន្ននេះ គឺជាកម្មវិធីសម្រាប់តែបុគ្គលិកជាតិប៉ុណ្ណោះ។ ដើម្បីឲ្យមានប្រសិទ្ធភាព ការ-កសាងសមត្ថភាពក្នុងក្របខ័ណ្ឌ នៃការបណ្តុះបណ្តាលត្រូវតែផ្អែកលើការផ្លាស់ប្តូរយោបល់គ្នាទៅវិញទៅមក។ គោលការណ៍នេះត្រូវ បញ្ជាក់ជាថ្មីអំពីចំណុចសំខាន់ៗជាគន្លឹះ ដូចជាការតាក់តែងដំណាក់កាលនៃកម្មវិធីបណ្តុះ-

បណ្តាល ។ ខាងក្រោមនេះគឺជាចំណុចទាំងឡាយក្នុងចំណោមការពិចារណា៖

- *ការណែនាំឲ្យស្គាល់បានគ្រប់គ្រាន់សម្រាប់ចៅក្រម និងបុគ្គលិកអន្តរជាតិ៖* តុលាការកូនកាត់ភាគច្រើនខ្វះខាតកម្មវិធីណែនាំឲ្យស្គាល់ហ្មត់ចត់ សម្រាប់ចៅក្រម និងបុគ្គលិកថ្មី។ អ្វីដែលល្អវិសេសគឺត្រូវធ្វើទស្សនកិច្ចវិលជុំ ទៅកាន់ស្ថាប័នច្បាប់នានាក្នុងស្រុក និងចូលរួម ក្នុងការជំនុំជម្រះក្តីក្នុងស្រុកជាមធ្យោបាយមួយ ក្នុងការស្វែង-យល់ឲ្យកាន់ប្រសើរឡើងនូវបរិបទ នៃកម្មវិធីណែនាំឲ្យស្គាល់ត្រូវគ្របដណ្តប់លើកត្តាវប្បធម៌ ក៏ដូចជាការបណ្តុះបណ្តាលអំពីរបៀបពីភាក្សាបញ្ហាជាមួយនឹងប្រព័ន្ធជាតិ ដោយមិនបើកចំហផងដែរ។ ការបកប្រែ ក៏អាចជាលក្ខ័ណ្ឌទាមទារឲ្យមាន និងចាំបាច់នូវផែនការដើម្បីធ្វើឲ្យតួអង្គអន្តរជាតិយល់ដឹងច្បាស់សមស្រប និងផ្តល់ការ-បណ្តុះបណ្តាលពួកគេអំពីច្បាប់ក្នុងស្រុក។

- *ការវាយតម្លៃអំពីតម្រូវការមុនការបណ្តុះបណ្តាល៖* កម្មវិធីជាច្រើនវាយតម្លៃខុសអំពីចំណេះ ដឹងផ្នែកច្បាប់ជាមូលដ្ឋានទាំងបុគ្គលិកជាតិ និងអន្តរជាតិ។ សិក្ខាសាលាស្តីពីវិស័យជំនាញលើច្បាប់ខ្ពស់ៗត្រូវធ្វើការវាយតម្លៃជាមុន អំពីចំណេះដឹងរបស់អ្នកចូលរួម ដោយមានបទបញ្ញត្តិ ជាបឋមអំពីបុគ្គលទាំងឡាយ ដែលត្រូវការចាំបាច់បំផុតអំពីកម្មវិធីអភិវឌ្ឍន៍ជំនាញ របស់ពួកគេបានផ្តោតការយកចិត្តទុកដាក់ស្តីពីគោលការណ៍សំខាន់ ផ្នែកច្បាប់ជាមូលដ្ឋានច្រើនថែមទៀត។

- *ការបណ្តុះបណ្តាលឯកទេស សម្រាប់ចៅក្រមជាតិ ឬអន្តរជាតិ៖* ក្នុងបរិបទជាក់ស្តែង ដូចជា នៅកូសូវ៉ូ មិនមានការការបណ្តុះបណ្តាលមុនចូលបំរើការងារ ស្តីពីច្បាប់សិទ្ធិមនុស្ស និងមនុស្សធម៌ ក្រម-

ព្រហ្មទណ្ឌ ឬក្រមនីតិវិធីព្រហ្មទណ្ឌទេ។ ការបណ្តុះបណ្តាលឯក-ទេស គឺជាការបណ្តុះបណ្តាលចាំបាច់ សម្រាប់ទាំងបុគ្គលិកជាតិ និងអន្តរជាតិ។ លើសពីនេះទៀត កម្មវិធីការបណ្តុះបណ្តាលគួរត្រូវធ្វើជាបន្ត និងត្រូវតំរូវតាមសេចក្តីត្រូវការពិសេស នៃការរីកចំរើនរបស់តុលាការកូនកាត់។ ឧទាហរណ៍ ការបណ្តុះបណ្តាលបឋមអាចផ្តោតលើទស្សនៈ នៃច្បាប់អន្តរជាតិ ដែលអាចអនុវត្តបាន និងនីតិវិធីមុនដំណាក់កាលជំនុំជម្រះ។

- *ការបណ្តុះបណ្តាលត្រូវតែសម្របសម្រួល ជាមួយកម្មវិធីតុលាការ៖* ក្រៅពីការបណ្តុះបណ្តាល បឋមមុនពេលចាប់ផ្តើមដំណើរការក្តី ការ-បណ្តុះបណ្តាល ដែលទំនាស់នឹងការប្តេជ្ញាចិត្តរបស់តុលាការនឹងត្រូវទទួលបាន ដោយអ្នកចូលរួមមិនបានផលល្អឡើយ។ ការបណ្តុះ-បណ្តាល ត្រូវរៀបចំកម្មវិធីសម្រាប់ពេលឈប់សំរាករបស់តុលាការតាមអាចធ្វើទៅបាន។

- *ការរៀបចំការបណ្តុះបណ្តាលមួយ មានលក្ខណៈអនុវត្តជាក់ស្តែងជាជាងទ្រឹស្តី៖* កម្មវិធីនេះ ជាទូទៅត្រូវប្រើវិធីសាស្រ្តបែបអន្តរកម្មការចូលរួម និងតំរង់ទិសបែបអនុវត្តជាក់ស្តែង ប៉ុន្តែ មិនមែនតាមលក្ខណៈក្នុងប្រព័ន្ធ និងទ្រឹស្តីឡើយ។ ការបណ្តុះបណ្តាលជំនាញផ្នែកច្បាប់ ជាមូលដ្ឋាន រាប់បញ្ចូលទាំងការលើកហេតុតាមផ្លូវច្បាប់វិធីសាស្រ្តក្នុងការសរសេរការចោទប្រកាន់ សាលក្រម និងការសួរដេញដោលសាក្សីគឺជាតម្លៃយ៉ាងធំធេង។ ការផ្លាស់ប្តូរកម្មវិធី ដូចជាកម្មវិធីមួយរៀបចំសម្រាប់ចៅក្រម របស់តុលាការពិសេសសម្រាប់ប្រទេសសេរាឡេអូន ដល់សាលាក្តីព្រហ្មទណ្ឌអន្តរជាតិ សម្រាប់អតីតប្រទេសយូហ្គូស្លាវីក៏ជាកម្មវិធីមានប្រសិទ្ធភាពផងដែរ។

- *ការជួលគ្រូឧទ្ទេសជាតិតាមអាចធ្វើទៅបាន៖* ការយកចិត្តទុកដាក់យ៉ាងខ្លាំងត្រូវធ្វើឡើង ក្នុងការកំណត់អ្នកវិជ្ជាជីវៈច្បាប់ជាតិ ដើម្បីដំណើរការការបណ្តុះបណ្តាល ជាជាងពឹងផ្អែកទាំងស្រុងតែលើអ្នកជំនាញការអន្តរជាតិ។ វិធីសាស្ត្រនេះក៏ធ្វើឲ្យកម្មវិធីនៃការបណ្តុះ-បណ្តាលមានប្រសិទ្ធភាពច្រើន ដោយការធានាថា កម្មវិធីបណ្តុះ-បណ្តាលទាំងនេះត្រូវធ្វើឲ្យមានភាពទាក់ទងគ្នា ជាមួយនឹងអ្នកចូលរួមជាតិ។ ឧទាហរណ៍ ការបង្រៀនច្បាប់អន្តរជាតិ និងនីតិវិធីរៀបចំឡើងដោយធ្វើការយោង ដល់ចំណុចស្រដៀងគ្នាទាំងឡាយ ឬដោយការចាប់ផ្តើមពីច្បាប់ជាតិ ដែលអ្នកចូលរួមដឹងច្បាស់។

- *ការពង្រីកឱកាសនានាក្នុងការបណ្តុះបណ្តាលដល់អ្នកវិជ្ជាជីវៈច្បាប់ដ៏ទូលំទូលាយ៖* កម្មវិធីនេះអាស្រ័យលើការរក្សាទំនាក់ទំនងវិជ្ជមានជាមួយអ្នកវិជ្ជាជីវៈច្បាប់ដ៏ទូលំទូលាយ។ ការបណ្តុះបណ្តាលសម្រាប់អ្នកវិជ្ជាជីវៈច្បាប់ដ៏ទូលំទូលាយ ក្នុងស្រុកត្រូវរៀបចំផែនការយុទ្ធ-សាស្ត្រស្តីពីវត្តមានរបស់អន្តរជាតិ។

## ៣. *ការអភិវឌ្ឍន៍វិជ្ជាជីវៈសម្រាប់ចៅក្រម*

ចៅក្រមអាចតវ៉ាដោយសារតែជួបប្រទះនឹងបញ្ហាប្រឈម លើចំណេះដឹងរបស់ពួកគេ ហើយសន្មត់ថា ពួកគេមិនត្រូវការនូវការអភិវឌ្ឍន៍វិជ្ជាជីវៈណាមួយឡើយ ជាពិសេស ប្រសិនបើ បញ្ហានោះមិនត្រូវបានលើកឡើងពីដំបូង។ ចំណុចខាងក្រោមនេះអាចបង្កើតបានជាផ្នែកមួយ នៃវិធីសាស្ត្រគ្រោងទុកមុន ដែលលើកកម្ពស់ការផ្លាស់ប្តូរយោបល់ ក្នុងចំណោមចៅ-ក្រមទាំងឡាយ៖

- *ការយល់ដឹង និងការយកចិត្តទុកដាក់ទៅវិញទៅមក៖* មានបណ្តឹងជាច្រើនបានទទួល រាប់ទាំងចៅក្រមអន្តរជាតិ ដែលបាន

បរិយាយថា ត្រូវបានដាក់ឲ្យឃ្លាតឆ្ងាយ និងមិនបំរើមុខតំណែងមានប្រយោជន៍ ហើយចៅក្រមជាតិត្រូវការការយកចិត្តទុកដាក់ពីបុគ្គលិកអន្តរជាតិ។ ចៅក្រមនៅទីម័ខាងកើតរាយការណ៍ថាពួកគេមិនត្រូវបានប្រព្រឹត្តស្មើគ្នាទេ ដោយសារបុគ្គលិកអន្តរជាតិបង្ហាញអំពីកង្វះការយល់ដឹងចរិយាវប្បធម៌ក្នុងស្រុក និងសារតារជាប្រវត្តិសាស្ត្រ ជាពិសេសក្នុងការសួរដេញដោលសាក្សី និងអន្តរកម្មរបស់គេជាមួយសហការីជាតិ។

- *ជំនាញជាជាងចំណេះដឹងផ្នែកច្បាប់៖* ចៅក្រមអាចបើកចំហរកាន់តែច្រើនថែមមទៀត ចំពោះការរៀនសូត្របច្ចេកទេសថ្មីៗ ដែលមិនបានឆ្លុះបញ្ចាំងដោយផ្ទាល់ នូវសមត្ថភាពផ្នែកច្បាប់របស់គេដោយរាប់បញ្ចូលទាំងការគ្រប់គ្រងបន្ទប់តុលាការ ព័ត៌មានវិទ្យាទិដ្ឋភាពផ្សេងៗនៃនីតិវិធី។

- *ការប្រើប្រាស់បុគ្គលិកវ័យក្មេងៗ ដូចជាជំនួយការចៅក្រម៖* ការ-ប្រើប្រាស់បែបនេះអាចត្រូវបានធ្វើឡើង សម្រាប់ក្រឡាបញ្ជីអន្តរ-ជាតិដោយសារតែចៅក្រមមួយចំនួនអាចបើកចំហច្រើន ចំពោះមតិយោបល់ចេញពីអ្នកនៅក្រោមបង្គាប់ ក្នុងឋានានុក្រមការងារក្នុងករណីរបស់ចៅក្រម។

## *៤. ការអភិវឌ្ឍន៍វិជ្ជាជីវៈសម្រាប់មេធាវី*

ជាទូទៅ តុលាការកូនកាត់នៅកន្លែងផ្សេងៗទៀត ជាញឹកញាប់បានបំពេញការងារ ដើម្បីធ្វើការពង្រឹងតួនាទីរបស់ព្រះរាជអាជ្ញា ទោះជាក្នុងប្រព័ន្ធដែលពីមុនមកធ្លាប់ស្និទ្ធនឹងប្រព័ន្ធច្បាប់ស៊ីវិលក៏ដោយ ដូចជានៅបូស្នៀ និងហឺហ្សីហ្គូវីណា (Bosnia and Herzegovina) ទីម័ខាងកើត និងកូសូវ៉ូ។ វិធីសា-ស្ត្រថ្មីនេះអាចត្រូវការបណ្តុះបណ្តាល ដែលនៅក្នុងនោះព្រះរាជអាជ្ញា តែ

មិនមែនចៅក្រមស៊ើបអង្កេតទេ ដែលនាំមុខក្នុងការស៊ើបអង្កេត និងរៀបចំសេចក្តីព្រាងក្នុងបទចោទប្រកាន់។

ដោយមិនគិតដល់ថា តើជាប្រព័ន្ធច្បាប់ស៊ីវិល ឬខមម៉ុន (civil or common law) គោលដៅ កេរ្តិ៍ដំណែលទូទៅ និងអាចសម្រេចបាន សម្រាប់តុលាការកូនកាត់គឺអាចត្រូវបង្កើតសមត្ថភាព បច្ចេកទេសអចិន្ត្រៃយ៍ ដើម្បីស៊ើបអង្កេត និងផ្តន្ទាទោសទម្រង់ឧក្រិដ្ឋកម្មបែបចាត់តាំង ដែលមានលក្ខណៈស្មុកស្មាញ ដោយរាប់បញ្ចូលទាំងឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក៏ប៉ុន្តែក៏រាប់បញ្ចូលទាំងឧក្រិដ្ឋកម្ម ដែលមានលក្ខណៈស្មុកស្មាញផ្សេងៗទៀតផងដែរ ដូចជា ការជួញដូរមនុស្ស ឬគ្រឿងញៀន និងអំពើពុក-រលួយ ។ ប្រភេទនៃឧក្រិដ្ឋកម្ម ទាំងនេះអាចបង្កើតបានជាបញ្ហាទោល និងរួមនៃវិធីសាស្ត្រពហុវិន័យ ដែលត្រូវធ្វើការវិភាគ ការគ្រប់គ្រងសំណុំរឿង ការការ-ពារសាក្សី ព័ត៌មានវិទ្យា និងកិច្ចសហប្រតិបត្តិការជាអន្តរជាតិ។ សមត្ថភាពអចិន្ត្រៃយ៍ ដើម្បីផ្តន្ទាទោសឧក្រិដ្ឋកម្មទាំងនេះ ជាពិសេសទាក់ទង នឹងបរិបទក្រោយជម្លោះ។ ស្រដៀងគ្នានេះដែរ ជាញឹកញាប់ តុលាការកូនកាត់មានឆន្ទានុសិទ្ធិផ្តន្ទាទោសយ៉ាងធំធេងជាងនៅកំរិតតុលាការជាតិ នៅក្នុងការ-តាក់តែងយុទ្ធសាស្ត្រផ្តន្ទាទោសមួយ ដែលអាចធ្វើបានសម្រាប់ធ្វើការជ្រើស-រើសសំណុំរឿង។ នៅពេលជាមួយគ្នានេះដែរ បញ្ហានេះត្រូវប្រព្រឹត្តទៅ ដោយប្រុងប្រយ័ត្ន ពីព្រោះឆន្ទានុសិទ្ធិធំធេងពេក ក៏អាចនាំមកនូវសក្តានុពលខ្លាំងសំរាប់ការជ្រៀតជ្រែកនយោបាយផងដែរ។

ជាញឹកញាប់អង្គភាពផ្នែកការពារក្តីត្រូវបានគេបោះបង់ចោល ក្នុងការបង្កើតតុលាការកូនកាត់។ ទោះបីជាយ៉ាងណាក៏ដោយ មេធាវីការពារក្តីអាចផ្តល់ឱកាសច្រើនសម្រាប់កេរ្តិ៍ដំណែល ពីព្រោះ ជាញឹកញាប់អង្គភាពនេះពាក់ព័ន្ធជាមួយតួអង្គជាតិ យ៉ាងច្រើនជាងអង្គភាពផ្សេងៗ របស់តុលាការ។ មេធាវីការពារក្តីឯកជនមានការលើកទឹកចិត្តយ៉ាងធំធេង ដើម្បីអនុវត្តតាម

និងរៀនសូត្រជំនាញថ្មីៗ ដែលទាក់ទងនឹងការងារថ្មីៗផ្ទាល់របស់គេ ប្រកប ដោយជោគជ័យ ក្នុងការការពារកូនក្តីអំពីចំណុចផ្លូវច្បាប់ ដែលមេធាវីជាច្រើនមិនបានដឹង។ ស្ទើរតែគ្រប់តុលាការកូនកាត់ទាំងអស់ បុគ្គលិកជាតិ ជាច្រើនបានធ្វើការងារនៅផ្នែកការពារក្តី ពីព្រោះជាញឹកញាប់ ជនជាប់ចោទ យល់ឃើញថា ងាយស្រួលច្រើនក្នុងការស្តាបនាទំនាក់ទំនងទំនុកចិត្តជាមួយ មេធាវី នៃសញ្ជាតិផ្ទាល់របស់គេ។

គំរូដែលអាចនឹងនាំមក នូវជោគជ័យត្រូវបានរកឃើញ នៅក្នុងការិ-យាល័យផ្នែកការពារក្តី នៅតុលាការពិសេសសម្រាប់ប្រទេសសេរាឡេអូន។ ការិយាល័យនេះចងក្រងនូវក្រុមស្នូល នៃមេធាវីផ្នែកការពារក្តី ក្នុងស្រុក ដែលដើរតួនាទីជាអ្នកការពារក្តីសាធារណៈ ដែលអមដំណើរដោយមេធាវីម្នាក់ៗ ពីបញ្ជីឈ្មោះរបស់មេធាវីបានអនុម័តរួចហើយ ដែលអាចត្រូវបានចាត់តាំង ដល់ជនជាប់ចោទនីមួយៗ។ ជនជាតិសេរាឡេអូនធ្វើជាតំណាងបានល្អ ទាំងក្នុងការិយាល័យការពារក្តី និងក្រុមការពារក្តី៖ ពួកគេដឹកនាំក្រុម៣ក្នុង ចំណោមក្រុមទាំង១០។ ការិយាល័យការពារក្តីបានសម្រេចនូវកិច្ចខិតខំ ប្រឹងប្រែងជាច្រើន ដើម្បីបញ្ចូលមេធាវីជាតិក្នុងក្រុមរបស់គេ ទោះជាសហ-មេធាវី ឬជំនួយការផ្នែកច្បាប់។ ក្រុមចំរុះធ្វើការយ៉ាងជិតស្និទ្ធជាមួយគ្នា។ កាលពីពេលថ្មីៗនេះ ការិយាល័យការពារក្តីបានស្នើសុំបង្កើនកិច្ចខិតខំប្រឹង ប្រែងកសាងសមត្ថភាព ដើម្បីធ្វើឲ្យប្រព័ន្ធច្បាប់ជាតិកាន់តែទូលំទូលាយ ថែម-ទៀត ស្តីពីគំរោងមួយឈ្មោះថា "គំរោងកសាងសមត្ថភាពនីតិរដ្ឋ និងវិស័យ យុត្តិធម៌សម្រាប់សេរាឡេអូន"។ តុលាការឧក្រិដ្ឋកម្មសង្គ្រាម និងអង្គជំនុំជម្រះ វិសាមញ្ញ ការិយាល័យការពារក្តីបានស្វែងរកឲ្យមានអន្តរកម្ម ជាមួយអង្គការ វិជ្ជាជីវៈច្បាប់ជាតិ។ បញ្ហានេះត្រូវធ្វើឡើងតាមវិធីផ្សេងៗ ដោយរាប់ទាំងការ បង្កើតនូវការិយាល័យទាំងឡាយ នៅក្បែរតុលាការជាតិ ទោះបីជាមធ្យោ-បាយនេះ នៅឆ្ងាយខ្លាំងពីតុលាការកូនកាត់ក៏ដោយ។ ជាទូទៅ វិធីសាស្ត្រ

ដែលចាត់វិធានការដោយការិយាល័យ ការពារក្តីក្នុងតុលាការកូនកាត់ផ្តល់ទាំងការជំរុញឲ្យមានគំនិតច្នៃប្រឌិត និងបទពិសោធន៍ដ៏មានតម្លៃ ស្តីពីការ-កសាងទំនាក់ទំនងដោយជោគជ័យជាមួយមេធាវីក្នុងស្រុក និងបង្កើតកម្មវិធីកសាងសមត្ថភាពប្រកបដោយប្រសិទ្ធភាព ។

## *៥. ការផ្ទេរជំនាញសម្រាប់អ្នកវិជ្ជាជីវៈមិនមែនផ្នែកច្បាប់*

ជាទូទៅ ការផ្ទេរជំនាញមានវិវាទប្បដិវាទតិចតួច នៅពេលដែលការផ្ទេរជំនាញនេះមិនទាក់ទងនឹងជំនាញផ្នែកច្បាប់។ វិស័យផ្សេងៗទៀត ដែលការផ្ទេរជំនាញអាចផ្តល់ផល កេរ្តិ៍ដំណែលគួរឲ្យកត់សំគាល់នោះ រាប់ទាំងជំនាញភាសា និងឧបករណ៍សម្រួលក្នុងការបកប្រែ ការគ្រប់គ្រងតុលាការ ការការពារក្តី និងគាំពារសាក្សី ចិត្តសាស្ត្រ កោសលវិច្ឆ័យ បុគ្គលិក លទ្ធកម្ម របាយការណ៍ផ្នែកច្បាប់ ព័ត៌មានវិទ្យា ការងារសិទ្ធិមនុស្ស ព័ត៌មានសាធារណៈ និងវិជ្ជាជីវៈសារព័ត៌មានក្នុងស្រុក និងការគ្រប់គ្រងសំណង់។ សម្រាប់វិស័យទាំងអស់នេះ គេអាចបង្កើតកម្មវិធីកេរ្តិ៍ដំណែលផ្សេងៗ ដែលនឹងអភិវឌ្ឍសមត្ថ-ភាពនោះក្នុងស្រុក ឬដែលអាចខិតខំប្រឹងប្រែងពេលជាមួយគ្នាដែរ ដើម្បីបំពេញសេចក្តីត្រូវការរបស់សាលាក្តី និងប្រព័ន្ធយុត្តិធម៌ដ៏ទូលំទូលាយ ដោយការរៀបចំនូវផែនការ គ្រប់គ្រាន់។

តុលាការកូនកាត់ទាំងអស់បានទទួលជោគជ័យ គួរឲ្យកត់សំគាល់ក្នុងការអភិវឌ្ឍន៍ជំនាញជា មួយអ្នកស៊ើបអង្កេត និងឬនគរបាល។ នៅប្រទេសសេរាឡេអូន អ្នកស៊ើបអង្កេតមកពីប្រព័ន្ធក្នុងស្រុកបានពាក់ព័ន្ធ ក្នុងការរៀបចំផែនការប្រតិបត្តិការ ដ៏សំខាន់បំផុតមួយចំនួន ក្នុងចំណោមផែនការសំខាន់ៗទាំងឡាយមកដល់បច្ចុប្បន្ននេះ ហើយពួកគេបានបំរើការងារក្នុងតួនាទីសំខាន់ៗស្ទើរតែគ្រប់ក្រុម ដែលបានបំពេញការងារតាមកន្លែងផ្សេងៗ។ ជាញឹកញាប់សេវាកម្មនគរបាលកូសូវ៉ូត្រូវបានដកស្រង់ថា ជាកេរ្តិ៍ដំណែលមួយដ៏ជោគជ័យបំផុតរបស់បេសកកម្មសហប្រជាជាតិនៅកូសូវ៉ូ ក្នុងចំណោមកេរ្តិ៍ដំណែលដ៏

ជោគជ័យបំផុត ទាំងឡាយរបស់បេសកកម្មនេះ។ សេវាកម្មបានចាប់ផ្តើមឡើងដោយការជួលមន្ត្រីថ្មីៗចំនួន៦០០០នាក់។ ទោះបីជា បេសកកម្មនេះបានស្រូបយកកងទ័ពរំដោះកូសូវ៉ូចំនួន៥០ %ក៏ដោយ ក៏វាអាចធ្វើឲ្យមានការផ្លាស់ប្តូរគួរឲ្យកត់សំគាល់ដល់វប្បធម៌ស្ថាប័ន។

## *៦. ការផ្សារភ្ជាប់ការកសាងសមត្ថភាពទៅនឹងកម្មវិធីបណ្តុះបណ្តាលផ្សេងៗ*

អគ្គព្រះរាជអាជ្ញារងទទួលបន្ទុកឧក្រិដ្ឋកម្ម កំរិតធ្ងន់ចាប់ផ្តើមលើការងារ ស្តីពីការរៀបចំនូវរចនាសម្ព័ន្ធការិយាល័យ យ៉ាងទូលំទូលាយ នៅពេលចូលកាន់កាប់អង្គភាពឧក្រិដ្ឋកម្មកំរិតធ្ងន់ ដើមឆ្នាំ២០០២។ ការរៀបចំនេះរាប់ទាំងការតាក់តែងនូវការផ្តួចផ្តើមគំនិតនានា ដើម្បីកសាងសមត្ថភាពនៅទីម័ខាងកើត ដោយធ្វើការបណ្តុះបណ្តាលបុគ្គលិកនៅការិយាល័យអយ្យ-ការ ស៊ើបអង្កេត កោសលវិច្ច័យ និងការគ្រប់គ្រងភស្តុតាង។ ការបណ្តុះ-បណ្តាលតាមបណ្តាអង្គភាពត្រូវរៀបចំឡើងទាំង ការអនុវត្តន៍ជាក់ស្តែង និងទ្រឹស្តី ដោយរាប់បញ្ចូលទាំងលំហាត់ និងវីឌីអូសាកល្បង។ សិក្ខាកាមម្នាក់ៗត្រូវបានចាត់តាំងក្នុងក្រុមអយ្យការ ដែលខ្លួនបានអមដំណើរទៅតុលាការ។ កម្មវិធីនេះចូលរួម ដោយព្រះរាជអាជ្ញា អ្នកគ្រប់គ្រងសំណុំរឿង និងអ្នកវិភាគ ដោយមានកម្មវិធីបណ្តុះបណ្តាលមួយ ដាច់ដោយឡែក សម្រាប់អ្នកស៊ើប-អង្កេតនគរបាល។ មានសិក្ខាកាមប្រហែលចំនួន៣០នាក់ប៉ុណ្ណោះត្រូវបានបណ្តុះបណ្តាលគឺជាការរួមវិភាគទានដ៏មានសារសំខាន់ ប្រកបដោយសក្តានុ-ពល ចំពោះប្រទេសតូចៗដូចជាប្រទេសទីម័ខាងកើត។ ទោះបីជាយ៉ាងណាក៏ដោយ ជាបន្តបន្ទាប់កម្មវិធីបណ្តុះបណ្តាលថ្មីបានលើកឡើង នៅឯមជ្ឈ-មណ្ឌលបណ្តុះបណ្តាលតុលាការថ្មី បានបង្កើតឡើងដោយរដ្ឋាភិបាលទីម័ខាងកើត និងអង្គការយូ.អិន.ឌី.ភី។ កម្មវិធីនេះមិនទំនងជាពិចារណាអំពីគុណវុឌ្ឍិរបស់អ្នកបានចូលរួម ក្នុងការបណ្តុះបណ្តាល ដែលបានរៀបចំឡើងដោយអង្គភាពឧក្រិដ្ឋកម្មកំរិតធ្ងន់។ កម្មវិធីបណ្តុះបណ្តាលនេះត្រូវបានរៀបចំឡើង

ជាភាសាប៉ុទុយហ្កាល ជាភាសា ដែលសិក្ខាកាមព្រះរាជអាជ្ញាមិនយល់ ហើយដូច្នេះ បើទោះបីជា បេក្ខជនទាំងឡាយបានបញ្ចប់នូវការបណ្តុះបណ្តាលទាំងស្រុងរៀបចំឡើងដោយអង្គភាពឧក្រិដ្ឋកម្មកំរិតធ្ងន់ ដែលបរាជ័យជាប្រព័ន្ធក្នុងការប្រឡងក៏ដោយ។

ការសម្របសម្រួល ស្តីពីកិច្ចប្រឹងប្រែង ក្នុងការបណ្តុះបណ្តាលគឺជាធាតុផ្សំដ៏មានសារសំខាន់ សម្រាប់អនាគតសាលាក្តីកូនកាត់។ ការទទួលស្គាល់នូវការបញ្ចប់ទាំងស្រុងប្រកបដោយជោគជ័យ នៃកិច្ចការមុនៗគម្បីត្រូវបានគេទទួលយកប្រកដដោយវិជ្ជាជីវៈ ប្រសិនបើកិច្ចការទាំងនេះទាក់ទងជាមួយការងារ ដែលនឹងត្រូវបំពេញគួរឲ្យជឿជាក់បាន។ វិធីសាស្ត្របែបនេះនឹងត្រូវពិចារណាសម្រាប់ ការអនុវត្តន៍ការបណ្តុះបណ្តាលជាន់ខ្ពស់ច្រើនថែមទៀត ដែលត្រូវសន្មត់ជាមុននូវកំរិត នៃចំណេះដឹងប្រហាក់ប្រហែលគ្នាក្នុងចំណោមសិក្ខាកាមទាំងអស់ ប្រសិន បើពួកគេស្ថិតក្នុងតម្រូវការនោះបានទទួលការបណ្តុះបណ្តាលជាបឋម ដើម្បីឲ្យពួកគេមានចំណេះដឹងស្មើគ្នា។ នេះគឺជាវិសាលភាព នៃវិធីសាស្ត្របញ្ច្រៀបបែបវប្បធម៌ ដែលត្រូវទទួលយកក្នុងការបង្កើតរដ្ឋបាល និងការបិទសាលាក្តីកូនកាត់ទាំងឡាយ។

ការបណ្តុះបណ្តាល និងការកសាងសមត្ថភាពត្រូវផ្សារភ្ជាប់ទៅនឹងនីតិវិធីនៃការតែងតាំងពិសេស។ នៅប្រទេសកម្ពុជា អង្គការ យូ.អិន.ឌី.ភី (UNDP) បានរៀបចំការបណ្តុះបណ្តាលមុខវិជ្ជាទាំងឡាយ សម្រាប់ចៅក្រមនិងមេធាវីស្តីពីច្បាប់អន្តរជាតិ មុនពេលនៃការជ្រើសរើសសម្រាប់មុខតំណែងនៅអង្គជំនុំជម្រះវិសាមញ្ញ។ ការបណ្តុះបណ្តាលនេះមានសារសំខាន់ ប្រសិនបើមុខវិជ្ជាទាំងនោះបានបញ្ចប់ទៅ ប្រកបដោយជោគជ័យជាសេចក្តីត្រូវការសម្រាប់ការជ្រើសរើសនេះ។

# V. ហេដ្ឋារចនាសម្ព័ន្ធ ឬសម្ភារៈជាក់ស្តែង ចាត់ទុកជាកេរ្តិ៍ដំណែល

កេរ្តិ៍ដំណែលក៏អាចកើតមានផងដែរ ក្នុងទម្រង់នៃហេដ្ឋារចនាសម្ព័ន្ធ ដូចជាមធ្យោបាយ ឬបរិក្ខារជួយសម្រួលទាំងឡាយ ក៏ដូចជាវិស័យជាក់ស្តែង នៃភស្តុតាង និងបណ្ណាសារនៃរបាយការណ៍ របស់តុលាការ។ កេរ្តិ៍ដំណែលជាក់ស្តែងគឺជាកត្តាដ៏មានសារសំខាន់ ដោយហេតុថា បញ្ហានានា ដូចជាជំរើសក្នុងបរិវេណតុលាការអាចជាអត្ថន័យ នៃនិមិត្តរូបដ៏មានសារសំខាន់។

កេរ្តិ៍ដំណែលជាក់ស្តែងសន្មត់ជាមុនថា មានសារសំខាន់យ៉ាងធំធេង ដែលក្នុងនោះតុលាការកូនកាត់មិនមានបំណាងណាមួយ ស្ថិតនៅជាស្ថាប័នអចិន្ត្រៃយ៍ឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ នៅបូស្នៀ និងហឺហ្សីហ្គូវីណា ជាទីដែលអង្គជំនុំជម្រះឧក្រិដ្ឋកម្មសង្គ្រាមនឹងបន្តការងារ បន្ទាប់ពីការចាក-ចេញ នៃសមាសភាពអន្តរជាតិ មនុស្សជាច្រើននាក់មានមោទនភាពជាខ្លាំង ចំពោះមធ្យោយ និងបរិក្ខារនានារបស់តុលាការជាតិ។ នៅប្រទេសសេរា-ឡេអូន កិច្ចពិគ្រោះយោបល់កំពុងតែរៀបចំ ផែនការស្តីពីវិធីត្រូវប្រើប្រាស់ទី-តាំងរបស់តុលាការពិសេស ដែលមានកំរិតអភិវឌ្ឍន៍ខ្ពស់ ខាងវិស័យបរិក្ខារបច្ចេកទេស ឬវិទ្យាសាស្ត្រ បន្ទាប់ពីការបញ្ចប់នូវអាណត្តិរបស់ខ្លួន។ បច្ចុប្បន្ននេះ នៅប្រទេសកម្ពុជា អង្គជំនុំជម្រះវិសាមញ្ញតាំងនៅបរិវេណយោធាទើបតែសាងសង់ថ្មី ដោយផ្អែកតាមការសន្មត់ជាមុនថា បន្ទាប់ការបញ្ចប់ការងារទាំង-ស្រុងរបស់អង្គជំនុំជម្រះនេះ មធ្យោបាយ និងគ្រឿងបរិក្ខារសម្រួលទាំង-ឡាយនឹងត្រូវប្រគល់ដល់យោធាវិញ ក្នុងការប្រើប្រាស់ ដែលជាសេចក្តី-សម្រេចមួយ ដែលមិនពិចារណាអំពីកេរ្តិ៍ដំណែលឡើយ។

ទិដ្ឋភាពមួយទៀត នៃក្ដីកង្វល់នានាអំពីកេរ្ដិ៍ដំណែលគឺភស្ដុតាង ដែលនឹងត្រូវប្រមូល ក៏ដូចជា បណ្ណាសារនៃការជំនុំជម្រះក្ដីនានា។ ទ្វេគ្រោះដែលអង្គភាពឧក្រិដ្ឋកម្មកំរិតធ្ងន់ និងគណៈវិនិច្ឆ័យពិសេស នៅទីម៉ខាងកើតបានប្រឈមមុខ គឺជាបញ្ហាតែមួយប៉ុណ្ណោះ ដើម្បីបញ្ចប់ទាំងស្រុងនូវអាណត្តិរបស់គេ ជាសូចនាករនៃបញ្ហានានា ដែលអាចកើតមានឡើង និងត្រូវការចាំបាច់ត្រូវលើកឡើងជាដំណោះស្រាយ។ បណ្ណាសាររបស់គណៈវិនិច្ឆ័យពិសេសត្រូវប្រគល់ជូនតុលាការស្រុកនៅឌីលី។ ទោះបីជាយ៉ាងណាក៏ដោយ ភាពស្មុក-ស្មាញនៃស្ថានការណ៍កើតមានឡើង ពីព្រោះតែអង្គភាពឧក្រិដ្ឋកម្មកំរិតធ្ងន់មានលទ្ធភាពស៊ើបអង្កេត ត្រឹមតែឃាតកម្មចំនួន៦៧២ករណីប៉ុណ្ណោះក្នុងចំណោមឃាតកម្មចំនួន១៤០០ករណី ដែលបានកើតមានឡើងក្នុងកំឡុងកុប្បកម្មឆ្នាំ១៩៩៩។ ដូច្នេះ សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខ ១៥៩៩ (២០០០) បានបញ្ជាក់ថា ច្បាប់ចម្លងទាំងស្រុងនៃបណ្ណាសាររបស់អង្គភាពនេះត្រូវរក្សាទុកនៅទីក្រុងញូយ៉ក ក្នុងកិច្ចព្រមព្រៀងជាមួយនឹង អាជ្ញាធរទីម៉-ខាងកើត។ ក្នុងព្រឹត្តិការណ៍ហិង្សានាពេលថ្មីៗនេះ ការិយាល័យអគ្គព្រះរាជ-អាជ្ញា ដែលគ្រប់គ្រងបណ្ណាសារឧក្រិដ្ឋកម្ម កំរិតធ្ងន់ច្បាប់ដើមត្រូវបានរើក-កាយ និងបណ្ណាសារមួយចំនួនទៀត ត្រូវបាត់បង់។ បញ្ហានេះលើកឡើងជាសំណួរនៃភាពសម្ងាត់ នៃសេចក្ដីថ្លែងការណ៍របស់សាក្សី និងជោគវាសនារបស់សាក្សីត្រូវការពារ ដែលត្រូវបានធានាថា ព័ត៌មាននោះនឹងមិនត្រូវបានចែករំលែក ឡើយ។

ក្រៅពីបញ្ហានានានៃភាពម្ចាស់ការ និងទីតាំងតុលាការ បញ្ហាផ្សេងៗទៀតក៏មិនត្រូវបានសន្និដ្ឋានជាមុនថា ជាបណ្ណាសារជាប្រវត្តិសាស្រ្ត ដែលបន្សល់ទុកដោយតុលាការនោះអាចប្រើប្រាស់បាន យ៉ាងមានសារសំខាន់ដល់សាធារណជនជាទូទៅឡើយ។ យុទ្ធសាស្រ្តនានា ដើម្បីលើកកម្ពស់ក្នុងការប្រើប្រាស់នេះគឺរាប់ទាំងការផលិតឯកសារ ឬខ្សែភាពយន្តខ្លីៗបោះពុម្ព-

ផ្សាយសំណៅសង្ខេបនៃ សាលក្រមនានា និងការដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សាតាមសាលារៀននូវរបកគំហើញទាំងឡាយ នៃករណីយុត្តិសាស្ត្រ។ ស្វះស្វែងរកទំនាក់ទំនងជាមួយអង្គការក្រៅរដ្ឋាភិបាល ដែលអាចអភិរក្សឯកសារទាំងឡាយ ដូចជាការកែប្រែមជ្ឈមណ្ឌលឯកសារកម្ពុជា ទៅជាកន្លែងស្រាវជ្រាវ។ គោលនយោបាយច្បាស់លាស់ចាំបាច់ត្រូវតាក់តែងឡើងពីដំបូង ដោយមានទស្សនៈជួយសម្រួបសម្រួល នូវកេរ្តិ៍ដំណែលបណ្ណា-សាររបស់តុលាការ និងសម្ភារៈផ្សេងៗទៀត តួយ៉ាងដូចជា ឯកសារទាំង-ឡាយណា ដែលនឹងត្រូវរក្សាទុកជាអចិន្ត្រៃយ៍។

# VI. កំណែទម្រង់ច្បាប់ចាត់ទុកជាកេរ្តិ៍ដំណែល

## ក. ការរួមវិភាគទានរបស់តុលាការក្នុងការចំពោះកំណែទម្រង់ច្បាប់

ការរៀបចំឡើងវិញប្រកបដោយជោគជ័យនៃកេរ្តិ៍ដំណែល និងកំណែទម្រង់ច្បាប់ចាត់ទុកជាបរិយាកាសនយោបាយមួយ ដែលផ្តល់ផលប្រយោជន៍ដល់កំណែទម្រង់ច្បាប់។ បញ្ហានេះក៏ចាត់ទុក ជាការរួមគ្នានៃរបៀបវារៈរបស់អន្តរជាតិ និងជាតិផងដែរ។ នៅពេលជាមួយគ្នានេះដែរ ការរួមវិភាគទានចំពោះកំណែទម្រង់ផ្នែកច្បាប់អាចជាកេរ្តិ៍ដំណែលមួយ ដ៏មានសារសំខាន់ជាពិសេស ប្រសិនបើការកំណែទម្រង់នេះនាំមកនូវប្រព័ន្ធច្បាប់មួយដ៏រឹងមាំ ដែលក្នុងនោះ អ្នកវិជ្ជាជីវៈច្បាប់ទទួលរងតិចតួចនូវសម្ពាធពីខាងក្រៅ។ ការងារច្បាប់ដែលច្បាស់លាស់ និងរឹងមាំមួយសម្រាប់ស្ថាប័នកូនកាត់ដោយផ្ទាល់គឺមានសារសំខាន់ជាទីបំផុត ដល់ការផ្តល់វិភាគទានចំពោះកំណែទម្រង់ច្បាប់នេះ។

ឧទាហរណ៍ របៀបវារៈរួមគ្នាប្រកបដោយជោគជ័យ រវាងភាគីអន្តរ-ជាតិ និងជាតិ ដែលបានមកដោយសារវត្តមាន របស់តួអង្គច្បាប់អន្តរជាតិ ក្នុងតុលាការកូនកាត់គឺនៅកូសូវ៉ូ បូស្នៀ និង ហឺហ្សេហ្គោវីណា។ ទាំងនៅកូសូវ៉ូ និងបូស្នៀ និងហឺហ្សេហ្គោវីណា ទាំងតួអង្គអន្តរជាតិ និងជាតិបានទទួលស្គាល់យ៉ាងឆាប់រហ័សអំពីសេចក្តីត្រូវការ ដើម្បីរៀបចំកំណែទម្រង់ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីដ៏ទូលំទូលាយមួយ។ ឧទាហរណ៍ នៅកូសូវ៉ូត្រូវបានដកចេញនូវស្វ័យភាពរបស់ខ្លួននៅឆ្នាំ១៩៨៩ ដោយមិនមានច្បាប់ព្រហ្មទណ្ឌរបស់ខ្លួន

ផ្ទាល់ឡើយ នៅពេលខ្លួនស្ថិតក្រោមការរដ្ឋបាលរបស់សហប្រជាជាតិ។ នៅថ្ងៃទី០៦ ខែមេសា ឆ្នាំ២០០៤ ក្រមព្រហ្មទណ្ឌបណ្ដោះអាសន្ន និងក្រមនីតិវិធីព្រហ្មទណ្ឌថ្មីរបស់កូសូវ៉ូបានចូលជាធរមាន ដែលចូលមកជំនួសច្បាប់ព្រហ្មទណ្ឌផ្សេងៗប្រកបដោយ ជោគជ័យ។ ក្រមទាំងនេះត្រូវបានព្រាងដោយក្រុមអ្នកប្រកបវិជ្ជាជីវៈច្បាប់ផ្សេងៗ រាប់បញ្ចូលទាំងតំណាងទាំងឡាយ នៃក្រុមប្រឹក្សាអឺរ៉ុប ហើយត្រូវបានចងក្រងដោយនាយកដ្ឋានកិច្ចការច្បាប់ នៃបេសកកម្មរបស់សហប្រជាជាតិនៅកូសូវ៉ូ។ នៅបូស្នៀ និងហឺហ្សេហ្គោវីណា សន្ទុះសម្រាប់ការបង្កើតតុលាការថ្នាក់រដ្ឋគឺជា លទ្ធផលកិច្ចសហប្រតិបត្តិការរវាងភាគីអន្តរជាតិ និងជាតិយ៉ាងទូលំទូលាយ ហើយជាលក្ខ័ណ្ឌមុនសម្រាប់ការចូលរួមពិភាក្សាជាមួយសហភាពអឺរ៉ុប។ នៅពេលជាមួយគ្នានេះដែរ ក្រមព្រហ្មទណ្ឌថ្មីត្រូវបានប្រកាសឲ្យប្រើប្រាស់នៅខែមិនា ឆ្នាំ២០០៣ និងការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សមានតួនាទីដ៏សំខាន់ ក្នុងសេចក្ដីព្រាងដើម តាមដែលបានប្រកាសឲ្យប្រើប្រាស់បាន។ គេរំពឹងថា ដោយមានការពិនិត្យឡើងវិញម្ដងទៀត ច្បាប់នេះទទួលបាននូវលក្ខណៈបែបជាតិកាន់តែច្បាស់ថែមទៀត។

ប្រព័ន្ធទាំងពីរត្រូវបានលើកទឹកចិត្តឲ្យមានការកែទម្រង់ តាមរយៈភាពអាចអនុវត្តន៍បាន នៃសន្ធិសញ្ញាអឺរ៉ុប សម្រាប់ការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ហើយក្នុងករណីនៅកូសូវ៉ូ ភាពអាចអនុវត្តន៍បានដោយផ្ទាល់នៃអនុសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ហើយនិង ការទទួលខុសត្រូវ នៃបេសកកម្មរបស់សហប្រជាជាតិនៅកូសូវ៉ូគឺត្រូវការពារ និងលើកកម្ពស់សិទ្ធិមនុស្ស។ លើសពីនេះទៀត វត្តមានរបស់បុគ្គលិកអន្តរជាតិត្រូវបានលើកទឹកចិត្តក្នុងការបញ្ចូល ដោយលើសលុបនូវទ្រឹស្ដីច្បាប់ខមម៉នឡ (common law) ទៅក្នុងសង្គមនិយមដែលប្រើប្រពន្ធ័ស៊ីវិលឡ (civil law)។ ឧទាហរណ៍ផ្សេងៗរាប់បញ្ចូលទាំងវិធាននានា ដែលទាក់ទង

នឹងតួនាទីដ៏រឹងមាំរបស់ព្រះរាជអាជ្ញា ការប្រើប្រាស់ប្រព័ន្ធ នៃការទទួលយកការប្រព្រឹត្តខុសផ្នែកព្រហ្មទណ្ឌ វិធានទំនើប ៗសម្រាប់ការស៊ើបអង្កេតឧក្រិដ្ឋ-កម្ម ដែលមានលក្ខណៈចាត់តាំង ដូចជាការលួចស្តាប់ ឬថតសម្លេង ការ-ទិញជាតិអាភៀនដែលគេគ្រប់គ្រង បន្ធូរបន្ថយទោសសាក្សីសហការ និងកម្មវិធីសម្រាប់ការការពារសាក្សី ដោយមានលិខិតុបករណ៍នីតិវិធី ដែលពិចារណាសម្រាប់អនាមិកភាព។ ក្រមថ្មីៗទាំងនេះ ក៏ត្រូវបញ្ចូលផងដែរនូវបទល្មើសព្រហ្មទណ្ឌទាំងឡាយក្រោមច្បាប់អន្តរជាតិ និងបទល្មើសផ្លូវភេទដែលពីមុនមកមិនមែនជាបទឧក្រិដ្ឋ។ ជាទូទៅ ក្រមទាំងនេះត្រូវបានគេស្វាគមន៍ ដោយហេតុថា ក្រមទាំងអស់អាចត្រូវការចាំបាច់នូវពេលវេលាមួយខ្លះៗ ដើម្បីឲ្យគេទទួលស្គាល់ជាច្បាប់ក្នុងស្រុកយ៉ាង ពិតប្រាកដ។

កិច្ចប្រឹងប្រែងទាំងឡាយ ក្នុងការកែទម្រង់ច្បាប់បានប្រឈមមុខនឹងភាពពិបាកជាច្រើននៅទីម៉ខាងកើត។ គេអាចរំពឹងទុកជាមុនគឺថា ក្របខ័ណ្ឌច្បាប់របស់គណៈវិនិច្ឆ័យពិសេស ដោយរាប់ទាំងវិធាននៃនីតិវិធីអន្តរកាលផងនោះ បង្កើតបានជាមូលដ្ឋានសម្រាប់កំណែទម្រង់ច្បាប់ថែមទៀត។ ទោះ-បីជាយ៉ាងណាក៏ដោយ ក្របខ័ណ្ឌច្បាប់នេះបានព្រាងឡើងដោយបុគ្គលិកអន្តរជាតិដោយមិន មានយោបល់ច្រើនពីបុគ្គលិកក្នុងស្រុកឡើយ និងបទ-បញ្ញត្តិទាំងនោះមានលក្ខណៈស្មុកស្មាញយ៉ាងខ្លាំង ដែលពឹងផ្អែកទាំងស្រុងលើលក្ខ័ន្តិកៈក្រុងរ៉ូម។ បទបញ្ញត្តិច្បាប់ទាំងនោះមានលក្ខណៈស្មុកស្មាញក្នុងការប្រើប្រាស់ ហើយចៅក្រមខ្លះបានទទួលការបណ្តុះបណ្តាលមិនគ្រប់គ្រាន់លើពាក្យសុំរបស់គេ។ ក្រមព្រហ្មទណ្ឌទីម៉ខាងកើតថ្មីបង្ហាញពីការចាកចេញជាស្ថាពរពីវិធីសាស្រ្តចាត់ឡើង ដោយអាជ្ញាធរអន្តរកាលរបស់សហប្រជាជាតិនៅទីម៉ខាងកើត ដែលជាជំនួសពឹងផ្អែកយ៉ាងខ្លាំងលើច្បាប់ប៉័ទុយហ្កាល។ ជាក់ស្តែងមិនមានកិច្ចពិគ្រោះយោបល់ជាសាធារណៈ ក្នុងដំណើរការស្តីពីការ-ព្រាង ឬការអនុម័តក្រមទាំងនេះទេ។ គួរឲ្យចាប់អារម្មណ៍ ជាជាងអនុម័ត

ដោយសភាទើបតែជ្រើសតាំងថ្មី របស់ទីម៉ខាងកើត ក្រមនីតិវិធីព្រហ្មទណ្ឌ និងក្រមព្រហ្មទណ្ឌត្រូវបានអនុម័ត ដោយបទបញ្ញត្តិនីតិប្រតិបត្តិ បន្ទាប់ពីការ-ពិចារណាដោយក្រុមប្រឹក្សារដ្ឋមន្ត្រី។ ក្រមបានស្នើឡើងនេះមានតែជាភាសាប៉ទុយហ្កាលប៉ុណ្ណោះ និងជាភាសាដែលមេធាវីភាគច្រើនមិនអាចអានបាន ហើយមានតែឥស្សរជនតែមួយ ក្រុមតូចប៉ុណ្ណោះនិយាយភាសានេះ។

ឱកាសសម្រាប់ផលប៉ះពាល់ជាវិជ្ជមាន គឺពឹងផ្អែកយ៉ាងខ្លាំងលើការរួមគ្នាទាំងរបៀបវារៈទាំងភាគីអន្តរជាតិ និងភាគីជាតិ នៅទីកន្លែងណាដែលតុលាការកូនកាត់ប្រតិបត្តិការរបស់ខ្លួនក្នុងរង្វង់ប្រព័ន្ធ ក្នុងស្រុកមានស្រាប់។ មានតែទំនាក់ទំនងផ្ទាល់ពីរ ឬបីប៉ុណ្ណោះរវាងតុលាការពិសេស និងរបៀបវារៈកំណែទម្រង់ច្បាប់ក្នុងស្រុកនៅប្រទេសសេរាឡេអូន។ ទោះបីជាយ៉ាងណាក៏ដោយ អង្គការបានហៅ ការផ្តួចផ្តើមគំនិតកំណែទម្រង់ច្បាប់នេះថា មិនមានបុគ្គលិកអន្តរជាតិ របស់តុលាការពិសេសចូលរួមដោយផ្ទាល់ ជំរុញលើកទឹកចិត្តដោយសារសន្ទុះ នៃវត្តមានរបស់តុលាការ ដើម្បីផ្តោតការយកចិត្តទុកដាក់កំណែទម្រង់ច្បាប់ ដែលបានកំណត់ជាមុន ជាពិសេសក្នុងការតាក់តែងឡើងវិញនូវច្បាប់នីតិវិធីព្រហ្មទណ្ឌ និងការព្រាងក្រមសីលធម៌សម្រាប់ចៅក្រម។ ការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅប្រទេសកម្ពុជា គឺជួនពេលជាមួយនឹងការរៀបចំបញ្ចប់សេចក្តីព្រាងក្រមនីតិវិធីព្រហ្មទណ្ឌថ្មី ដែលត្រូវបានគេរៀប-ចំឡើងដោយមានការជួយជ្រោមជ្រែង ពីរដ្ឋាភិបាលបារាំង អស់រយៈពេល ១០ឆ្នាំកន្លងមកនេះ។ ពីព្រោះតែគេរំពឹងថា ក្រមនេះនឹងបង្កើតបានជាមូល-ដ្ឋាននៃនីតិវិធីរបស់អង្គជំនុំជម្រះវិសាមញ្ញ ក្រមនេះក៏អាចត្រូវការនូវការធ្វើវិសោធនកម្ម ឬការបំពេញបន្ថែម ដើម្បីដោះស្រាយលក្ខ័ណ្ឌតម្រូវការផ្សេងៗនៃកិច្ចដំណើរការក្តីរបស់គេ។ អង្គជំនុំជម្រះវិសាមញ្ញអាចអនុវត្តតាមបទដ្ឋានអន្តរជាតិនានា ចំពោះបញ្ហាទាំងឡាយ ដែលមិនបានគ្របដណ្តប់បានគ្រប់-គ្រាន់ដោយច្បាប់របស់កម្ពុជា ដោយយោងតាម កិច្ចព្រមព្រាងរវាងសហប្រជា-

ជាតិ និងប្រទេសកម្ពុជា។ ពួកគេបានបង្កើតគណៈកម្មការច្បាប់ ដើម្បីស្នើសុំវិសោធនកម្មបន្ថែមនៃនីតិវិធី និងក្រមសីលធម៌ ដែលនឹងស្រង់យកពីលក្ខន្តិកៈទីក្រុងរ៉ូមរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ ជាសាលាក្តីពិសេស និងតុលាការកូនកាត់ផ្សេងៗទៀត។

ការអនុវត្តន៍លក្ខន្តិកៈទីក្រុងរ៉ូម របស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ អាចផ្តល់ឲ្យនូវឱកាស ជាច្រើនសម្រាប់កិច្ចខិតខំប្រឹងប្រែងរួមគ្នា ដើម្បីពិនិត្យឡើងវិញនូវច្បាប់ដែលមានស្រាប់នានា។ ផលប៉ះពាល់ក៏អាចមានកំរិតធំធេងផងដែរ នៅទីណាដែលមានវេទិកាជាក់លាក់សម្រាប់តួអង្គជាតិ និងអន្តរជាតិជួបជុំ និងពិភាក្សាគ្នាអំពីកំណែទម្រង់ទាំងឡាយ។

## ១. ផលប៉ះពាល់នៃករណីយុទ្ធសាស្ត្រ

ផលប៉ះពាល់របស់តុលាការកូនកាត់ គឺទាំងលើករណីយុត្តិសាស្ត្រព្រហ្មទណ្ឌជាតិ និងអន្តរជាតិនឹងពឹងផ្អែកមិនត្រឹមតែលើគុណភាពរបស់ចៅក្រមប៉ុណ្ណោះទេ តែក៏ពឹងផ្អែកលើតួនាទីនៃករណីយុត្តិសាស្ត្រផងដែរ ជាពិសេសគឺក្នុងបរិបទច្បាប់។ តុលាការកូនកាត់មានយុត្តាធិការធំធេង និងអាចធ្វើឲ្យមានប្រសិទ្ធភាពដល់ការផ្លាស់ប្តូរ ផ្នែកច្បាប់ក្នុងប្រព័ន្ធពិតប្រាកដ។ បញ្ហានេះអាចជាករណីផងដែរ នៅទីណា ដែលសាលាឧទ្ធរណ៍របស់តុលាការកូនកាត់ពិនិត្យឡើងវិញ នូវករណីយុត្តិសាស្ត្ររបស់តុលាការថ្នាក់ទាប។ ទោះបីជាយ៉ាងណាក៏ដោយ យុត្តាធិការលើប្រភេទសំណុំរឿងពិសេសមានលក្ខណៈចង្អៀត របស់តុលាការកូនកាត់ គឺដោយសារតែកត្តានៃការកំណត់ព្រំដែន។ ទិដ្ឋភាពអវិជ្ជមាន នៃកេរ្តិ៍ដំណែលរបស់តុលាការកូនកាត់គឺកង្វះ នៃការបោះពុម្ពផ្សាយ និងអលទ្ធភាពក្នុងការប្រើប្រាស់នូវករណីយុត្តិសាស្ត្ររបស់តុលាការ។ កង្វះនៃការបោះពុម្ពផ្សាយចោទជាសំណួរ នៃតម្លាភាពលើកឡើងខាងលើ ហើយរឹតតែសំខាន់ជាងនេះទៀត គឺរារាំងមិនឲ្យឯកសារតុលាការពាក់-

ព័ន្ធក្នុងការពិភាក្សា តាមបរិយាការវិទ្យាល័យ ដែលជាបន្តបន្ទាប់អាចផ្តល់ជូនបាននូវព័ត៌មាន ត្រឡប់ផ្នែកតុលាការដ៏មានតម្លៃ។

ស្រដៀងគ្នានេះដែរទីណា ដែលពហុភាសាត្រូវបានគេប្រើប្រាស់ក្នុងតុលាការកូនកាត់សំខាន់ គឺត្រូវបកប្រែសាលក្រមជាភាសា ដែលអាចប្រើ-ប្រាស់បានយ៉ាងទូលំទូលាយក្នុងស្រុក។ លើសពីនេះទៀត ករណីយុទ្ធសា-ស្ត្រអាចប្រើប្រាស់បានយ៉ាងទូលំទូលាយ និងចែកចាយយ៉ាងសកម្មថែមទៀតដល់សារព័ត៌មានក្នុងស្រុកសាលាច្បាប់ ស្ថាប័នពាក់ព័ន្ធផ្សេងៗ ជាពិសេសគឺដើម្បីទទួលបានផល ប៉ះពាល់នៅក្នុងវិស័យមួយចំនួន ដែលបានពិពណ៌-នាក្រោម "ផលនិទស្សន៍" ខាងលើ។ បញ្ហានេះគឺមានសារសំខាន់ផងដែរសម្រាប់តម្លាភាព។

# សេចក្តីសន្និដ្ឋាន

តុលាការកូនកាត់មិនត្រូវបានគេរំពឹងថានឹងលើកស្ទួយ ឬបំផ្លិចបំផ្លាញប្រព័ន្ធច្បាប់ក្នុងស្រុក ក៏ប៉ុន្តែខិតខំរៀបចំវិភាគទានជាយុទ្ធសាស្ត្រ តាមដែលអាចធ្វើបាន។ កេរ្តិ៍ដំណែលមិនត្រូវបានគេមើលឃើញថា ជាការបំបែកចេញ ប៉ុន្តែជាភាពស្រុះស្រួលគ្នា ក្នុងអាណត្តិដ៏មានសារសំខាន់របស់តុលាការកូន-កាត់ ហើយដែលបំពេញបន្ថែមជាមួយនឹងវិធីសាស្ត្រទាំងមូល ចំពោះការលើកស្ទួយនីតិរដ្ឋ និងការគោរពស្ថាប័នច្បាប់។ យុទ្ធសាស្ត្រ ដែលមានគោល-បំណងលើកកម្ពស់កេរ្តិ៍ដំណែល ត្រូវបញ្ចូលនូវការពិចារណាអំពីផលប៉ះពាល់និរន្តរភាព និងការប្រើប្រាស់តាមគោលដៅកំណត់នៃធនធានទាំងឡាយទៅក្នុងការបង្កើត និងការអនុវត្តន៍របស់តុលាការកូនកាត់។

សំខាន់គឺត្រូវរៀបចំតុលាការកូនកាត់នោះ ដោយមានទស្សនៈមួយគឺទទួលបាននូវផលប៉ះពាល់មកលើប្រព័ន្ធយុត្តិធម៌ ក្នុងសាមីប្រទេសជាអចិ-ន្ត្រៃយ៍ និងយូរអង្វែង ។ ការបង្កើតតុលាការនេះ គឺជាដំណាក់កាលដ៏មានសារសំខាន់មួយ ដែលក្នុងកំឡុងពេលនោះទំនាក់ទំនងជាមួយតួអង្គក្នុងស្រុកត្រូវតែរាប់បញ្ចូល និងគ្រប់គ្រងដោយប្រយ័ត្នប្រយែង។ ចំណុចស្នូលនៃកេរ្តិ៍ដំណែល គឺជាទស្សនាទាននៃនិរន្តរភាព ជាអាទិ៍គឺវិធីបង្កើនឲ្យបានជាអតិបរិមានូវអន្តរាគមន៍ជាអន្តរជាតិ ដែលជាលទ្ធផលនៃមហាឧក្រិដ្ឋកម្ម និងវិធីដើម្បីសម្រេចបាននូវការវិភាគជាអចិន្ត្រៃយ៍ ដល់សមត្ថភាពរបស់ប្រទេសដើម្បីដោះស្រាយឧក្រិដ្ឋកម្មជាប្រព័ន្ធ។

ក្នុងចំណោមផលប៉ះពាល់ដ៏មានសារសំខាន់បំផុត ដែលសាលាក្តីកូនកាត់អាចមានមកលើនីតិរដ្ឋ គឺផលនិទស្សន៍នៃដំណើរការជំនុំជម្រះក្តីដោយ

យុត្តិធម៌ ទោះជាឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរបំផុតក៏ដោយ។ វិស័យដ៏ទូលំទូលាយមួយទៀត ដែលតុលាការកូនកាត់អាចប្រើប្រាស់បានជាគំរូ គឺការបញ្ចូលអំពីវិវត្តន៍ថ្មីៗក្នុងច្បាប់មនុស្សធម៌ ច្បាប់សិទ្ធិមនុស្ស និងវិធានការស៊ើបអង្កេត និងចោទប្រកាន់ឧក្រិដ្ឋកម្មពិសេសៗ ដោយរាប់បញ្ចូលទាំងការប្រើប្រាស់សាក្សីដែលសហការ។ ក្របខ័ណ្ឌច្បាប់មួយ ដែលទាក់ទងគ្នាមានតម្លាភាព និងស្ថេរភាពនឹងមានសារសំខាន់សម្រាប់តុលាការកូនកាត់ ដើម្បីអនុវត្តដ៏មានប្រសិទ្ធភាព និងអាចបន្សល់ទុកនូវកេរ្តិ៍ដំណែលតាមរយៈករណីយុទ្ធសាស្ត្រ។

ផលប៉ះពាល់អវិជ្ជមាននានា ដូចជាការធ្វើឲ្យទន់ខ្សោយដល់សមត្ថ-ភាពក្នុងស្រុក ដែលអាចជៀសវាងបានដោយស្រួល។ ផ្ទុយទៅវិញ គេត្រូវសម្រេចអោយបាននូវគោលនយោបាយបុគ្គលិក និងកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈដែលអាចយកមកពិចារណា សម្រាប់ការកសាងសមត្ថភាពក្នុងស្រុកប្រកបដោយនិរន្តរភាព ដើម្បីស៊ើបអង្កេត ចោទប្រកាន់ វិនិច្ឆ័យទោស និងការពារក្តីឧក្រិដ្ឋកម្មដែលមានលក្ខណៈស្មុគស្មាញ។ វិធីសាស្ត្រសម្រាប់ការជ្រើសរើសបុគ្គលិកអន្តរជាតិគម្បីត្រូវពិនិត្យមើលឡើងវិញ ដើម្បីពិចារណាអំពីការជ្រើស-រើសបេក្ខជន ដែលមានគុណភាពខ្ពស់ទាន់ពេលវេលា។ កេរ្តិ៍ដំណែលជាក់-ស្តែងរបស់តុលាការទាមទារឲ្យមានផែនការ និងការពិចារណារជាមុនយ៉ាងប្រយ័ត្នប្រយែងជាមុន។ ប្រសិន បើប្រើប្រាស់ដោយប្រសិទ្ធភាពនូវឱកាសដែលបានមកដោយសារការបង្កើតតុលាការកូនកាត់ នោះតុលាការកូនកាត់អាចដើរតួនាទីជាកាតាលីករសម្រាប់ការផ្លាស់ប្តូរក្នុងស្ថាប័ន និងវប្បធម៌ច្បាប់ជាក់ជាពុំខាន។

# ឧបសម្ព័ន្ធ

## *សេចក្តីសង្ខេប*

១. អន្តរាគមន៍នានា ដើម្បីបង្កើតតុលាការកូនកាត់បង្កើតបានឱកាសតែមួយគត់ក្នុងក្របខ័ណ្ឌ នៃការយកទុកដាក់ពីសហគមន៍អន្តរជាតិ លើធនធាននានា និងកិច្ចខិតខំប្រឹងប្រែង និងឱកាសដ៏ពិសិដ្ឋនេះគម្បីត្រូវបង្កើនឲ្យបានជាអតិប្បរមា។

២. កេរ្តិ៍ដំណែលអាចត្រូវបានគេផ្តល់និយមន័យថា ជាផលប៉ះពាល់ដ៏យូរ-អង្វែងរបស់តុលាការកូនកាត់មួយ ស្តីពីការលើកកម្ពស់នីតិរដ្ឋ នៅក្នុងសង្គមណាមួយ ដោយដំណើរការជំនុំជម្រះក្តីប្រកបដោយប្រសិទ្ធភាព ដើម្បីចូលរួមចំណែកចំពោះការបញ្ចប់និទណ្ឌភាព ហើយនៅពេលជាមួយនេះ ដែរក៏ធ្វើការពង្រឹងសមត្ថភាពក្នុងស្រុកផងដែរ។ ផលប៉ះពាល់នេះអាចបន្តទៀត ទោះបីជាការងារ របស់តុលាការបញ្ចប់ក៏ដោយ។

៣. កេរ្តិ៍ដំណែលគម្បីញែកខុសគ្នាផងដែរ ពីកិច្ចខិតខំប្រឹងប្រែងដ៏ទូលំទូលាយ ដើម្បីកសាងនីតិរដ្ឋ ក្នុងបរិបទណាមួយជាក់លាក់ ដែលអាចត្រូវចំណាយពេលអស់ជាច្រើនឆ្នាំ។ កេរ្តិ៍ដំណែលមានទិសដៅ ខិតខំធ្វើឲ្យភាពចន្លោះ-ប្រហោងកាន់តែរួមតូច ក្នុងការប្រគល់អំណាច ចំពោះការផ្តន្ទាទោសឧក្រិដ្ឋកម្មធ្ងន់ធ្ងរដ៏មានកំរិតមួយចំនួន តាមរយៈតុលាការកូនកាត់ ភ្លាមៗបន្ទាប់ពីលទ្ធផល នៃជំលោះហើយកង្វះជាញឹកញាប់ នៃការប្រគល់អំណាចក្នុងប្រព័ន្ធយុត្តិធម៌ក្នុងស្រុកក្នុងបរិបទក្រោយជម្លោះ។

៤. បរិបទ និងភាពសមហេតុផល ចំពោះការបង្កើតតុលាការកូនកាត់នីមួយៗ គម្បីប្រាប់ឲ្យដឹងអំពីសេចក្តីសម្រេច ស្តីពីកេរ្តិ៍ដំណែលនេះ។ គំរូនីមួយៗ

គួរតែមានលក្ខណៈតែមួយ ហើយក៏ទាមទារឲ្យមានយុទ្ធសាស្រ្តដោយផ្ទាល់របស់វា។

៥. កេរ្តិ៍ដំណែលទាមទារឲ្យមានយុទ្ធសាស្រ្ត និងកេរ្តិ៍ដំណែលនឹងមិនកើតឡើងដោយស្វ័យប្រវត្តិយ៉ាងពិតប្រាកដនោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ សេចក្តីរំពឹងចំពោះកេរ្តិ៍ដំណែលត្រូវការចាំបាច់ចាត់ចែង។

៦. កេរ្តិ៍ដំណែលត្រូវតែម្ចាស់ការ និងជំរុញដោយសមីប្រទេស។ តុលាការកូនកាត់មិនត្រូវបានគេយល់ថា ជាអ្នកជំរុញឡើយ តែជាកាតាលីករមួយសម្រាប់ជំរុញលើកទឹកចិត្តឲ្យមានការផ្តួចផ្តើមគំនិតដ៏ទូលំទូលាយ។

៧. សារសំខាន់នៃកេរ្តិ៍ដំណែលត្រូវបានគេយល់ យ៉ាងច្បាស់បំផុត ប្រសិនបើតួនាទីរបស់អយ្យការនៃ ការរំលោភបំពាន់សិទ្ធិមនុស្សធ្ងន់ធ្ងរមិនត្រូវបានគេយល់ថា ជាវិសាលភាពនៃយុត្តាធិការព្រហ្មទណ្ឌសាមញ្ញប៉ុណ្ណោះទេ តែជាឱកាសវិសាមញ្ញសម្រាប់សង្គមមួយ ដើម្បីកសាងអន្តរកាលឆ្ពោះទៅកាន់ វប្បធម៌និតិរដ្ឋមួយ។

៨. ដើម្បីឲ្យទទួលបានជោគជ័យ តាមបទពិសោធន៍បង្ហាញថា កេរ្តិ៍ដំណែលត្រូវមានអាណត្តិ និងទទួលបានកិច្ចគាំពារច្បាស់លាស់ពីថវិកាស្នូល។ ការប្តេជ្ញាចិត្តចំពោះការប្រើប្រាស់ និងការកសាង សមត្ថភាពតាមអាចធ្វើទៅបាន រួមផ្សំជាមួយនឹងភាគរយសមហេតុផលនៃថវិកាសរុប (ដូចជាពី៥ ទៅ១០%) បំរុងទុកសម្រាប់សកម្មភាពផ្សព្វផ្សាយ និងកេរ្តិ៍ដំណែលជាក់លាក់ ដែលនឹងត្រូវធ្វើដំណើរ ដ៏វែងឆ្ងាយ។

៩. ដើម្បីធានានូវប្រយោជន៍ ជាអតិប្បរមានៃបទអន្តរាគមន៍អន្តរជាតិ និងគាក់តែងនូងយុទ្ធសាស្រ្ត ដ៏មានប្រសិទ្ធិភាពមួយសម្រាប់កេរ្តិ៍ដំណែលទាមទារឲ្យមានផែនការកម្មឲ្យបានច្រើនជាងអ្វីៗ ដែលមានរហូតមកដល់ពេលបច្ចុប្បន្ននេះ។

១០. សមាសភាពនៃក្រុមវាយតម្លៃមានសារសំខាន់ ហើយក្រុមទាំងនេះត្រូវដឹកនាំដោយតួអង្គសហប្រជាជាតិ ដែលមានចំណេះដឹងពិស្តារអំពីប្រទេសនោះ ដោយរាប់ទាំងតួអង្គផ្នែកច្បាប់នៅថ្នាក់ជាតិ ត្រូវបញ្ចូលក្នុងសមាសភាពក្រុមវាយតម្លៃមានសារសំខាន់ផងដែរ។

១១. បញ្ហាប្រឈមសំខាន់ៗសម្រាប់តុលាការកូនកាត់ គឺដៃគូការងារជាតិ និងអន្តរជាតិត្រូវសម្រេចឲ្យបាន នូវកម្រិតភាពម្ចាស់ការមួយដ៏សមស្រប។ ភាពម្ចាស់ជាការ គឺជាបញ្ហាមួយមិនត្រឹមតែនៅពេលបង្កើតនោះទេ ក៏ប៉ុន្តែ នៅពេលណាមានសេចក្តីសម្រេចសំខាន់ណាមួយត្រូវបានធ្វើឡើងក៏ដោយ ក្នុងពេលវត្តមានរបស់តុលាការទាំងស្រុង។ ភាពម្ចាស់ការត្រូវរាប់បញ្ចូល ទាំងការចូលរួមពីតួអង្គផ្សេងៗ ជារួមមានសង្គមស៊ីវិល។ គំរូវិជ្ជមានមួយសម្រាប់ភាពម្ចាស់ការអាចរកបាននៅអង្គជំនុំជម្រះឧក្រិដ្ឋសង្គ្រាម។

១២. ដៃគូសន្ទនាមួយចំនួន ដែលសហគមន៍អន្តរជាតិព្យាយាមដាក់ឲ្យចូលពាក់ព័ន្ធក្នុងកំឡុងពេល នៃកិច្ចចរចារ ស្តីពីការបង្កើតតុលាការកូនកាត់ ដើរតួនាទីដ៏សំខាន់មួយ ក្នុងការធានាកិច្ចគាំពារ ពីដៃគូការងារសង្គមស៊ីវិល និងសហគមន៍ច្បាប់។ ជាលទ្ធផល គួរមានកិច្ចពិគ្រោះយោបល់ជាមួយដៃគូសន្ទនា ក្នុងវិសាលភាពមួយដ៏ទូលំទូលាយ ដោយរាប់ទាំងដៃគូការងារសំខាន់ៗ។

១៣. ជាញឹកញាប់ តុលាការកូនកាត់ខិតខំប្រឹងប្រែងពង្រឹងបន្ថែមលើច្បាប់ជាតិ ប៉ុន្តែសំខាន់ត្រូវ បញ្ជាក់ឲ្យច្បាស់ពីដើមដំបូងថា ច្បាប់ណាខ្លះនឹងត្រូវអនុវត្ត។ កំណែទម្រង់នានាអាចមានសារសំខាន់ ដើម្បីបង្កើតតុលាការកូនកាត់មួយ ដោយអនុលោមតាមច្បាប់សិទ្ធិមនុស្ស និងអនុញ្ញាតឲ្យភាពពិសេសនេះ ដើម្បីផ្តន្ទាទោសឧក្រិដ្ឋកម្មធ្ងន់ធ្ងរ។

១៤. ជាទូទៅ គំរូបែបមជ្ឈការនៃការប្រើប្រាស់សមត្ថភាពអន្តរជាតិ (ពោល គឺថា ការបង្កើតតុលាការពិសេស ឬអង្គជំនុំជម្រះពិសេស ជាជាងការ-ពង្រាយដោយខ្ចាត់ខ្ចាយ នូវសមត្ថភាពអន្តរជាតិទូទាំងប្រព័ន្ធតុលាការ) ហាក់ដូចជាទទួលនូវជ័យជំនះ និងអាចទទួលនូវការពេញចិត្ត។ សម-ត្ថភាព បែបមជ្ឈការអាចមានប្រសិទ្ធិភាពច្រើន ហើយអាចបណ្តាលឲ្យមានឱកាសច្រើន សម្រាប់ការបណ្តុះបណ្តាល ការរៀបចំ និងការអភិវ-ឌ្ឍន៍ជំនាញពិសេស នៃក្រុមដៃគូជាតិមុនពេលជ្រើសរើស (និងអន្តរ-ជាតិ)។ រឹតតែសំខាន់ទៀត ដោយសារឧក្រិដ្ឋកម្ម និងជនសង្ស័យនានា កំពុងត្រូវបានជំនុំជម្រះក្តីនោះ តុលាការនេះក៏សម្របសម្រួលនូវនីតិវិធីសន្តិសុខដ៏មុឺងម៉ាត់ថែមទៀងផងដែរ។

១៥. ជាទូទៅ រដ្ឋបាលបែបសមាហរណកម្មនៃដៃគូជាតិ និងអន្តរជាតិ នៃតុលាការកូនកាត់គប្បីត្រូវលើកទឹកចិត្ត នៅពេលណាក៏ដោយ តាមដែលអាចធ្វើទៅបាន។

១៦. រដ្ឋាភិបាល ដែលស្នើនូវសុំជំនួយពីអន្តរជាតិត្រូវរៀបចំផែនការ តាមមធ្យោបាយនានាដែលមិនត្រូវបាត់បង់នូវទំនុកចិត្ត ក្នុងប្រព័ន្ធច្បាប់ក្នុងប្រទេសរបស់គេឡើយ។ មធ្យោបាយសំខាន់ៗ ដែលត្រូវចៀសវាងគឺ "កេរ្តិ៍ដំណែលអវិជ្ជមាន" ជារួមមាន (ក) ចៀសវាងការដាក់ជំនួសចំៗនូវធនធានក្នុងស្រុកដោយធនធានអន្តរជាតិ ឬការបង្កើតប្រព័ន្ធដែលស្របគ្នា (ខ) ព្យាយាមធ្វើឲ្យតុលាការកូនកាត់សម្រេចបានក្នុងក្របខ័ណ្ឌទូទៅ សម្រាប់ធ្វើការពង្រឹងប្រព័ន្ធច្បាប់ក្នុងស្រុក និង(គ)រៀបចំផែន-ការរឹងមាំមួយសម្រាប់ការប្រគល់ ដោយផ្អែកលើលក្ខ័ណ្ឌនានាជាជាងពេលវេលា។

១៧. នៅពេលគាត់តែងយុទ្ធសាស្រ្ត បញ្ចប់អាចនាំមកនូវឱកាសជាច្រើនសម្រាប់កេរ្ដិ៍ដំណែល បទពិសោធន៍អន្តរជាតិបានបង្ហាញថា មានផលប៉ះពាល់ប្រកបដោយសក្តានុពលយ៉ាងច្រើនបំផុត ប្រសិនកេរ្ដិ៍ដំណែលជាផ្នែកមួយដ៏សំខាន់ នៃផែនការកម្មគោលនយោបាយពីទស្សនាទាននៃតុលាការកូនកាត់។

១៨. តុលាការកូនកាត់អាចរួមវិភាគទាន ចំពោះការផ្លាស់ប្ដូរវប្បធម៌តាមរយៈការលើកកម្ពស់សិទ្ធិទាំងឡាយ ហើយអាចឈានទៅរកការទាមទារឲ្យមានការផ្លាស់ប្ដូរ ឬគណនេយ្យភាពកាន់តែច្រើនឡើង។ ផ្នែកមួយដ៏សំខាន់ នៃបញ្ហានេះគឺនឹងធ្វើការបង្ហាញអំពី *ឧត្តមភាពនៃច្បាប់* និងឯករាជភាពរបស់ខ្លួនពីការពិចារណាផ្នែកនយោបាយ។ នេះគឺជាមូលហេតុដ៏មានសារសំខាន់ថា ការផ្ដួចផ្ដើមគំនិតចម្រុះប្រាថ្នានូវបទដ្ឋានដ៏ខ្ពស់បំផុតនៃឯករាជភាព ភាពមិនលំអៀង និងការអនុវត្តន៍បទដ្ឋាន នៃនីតិវិធីច្បាប់ និងសិទ្ធិមនុស្សអន្តរជាតិ។ តាមរយៈនៃផលនិទស្សន៍នៃបទដ្ឋាន និងគុណតម្លៃទាំងនេះ តុលាការកូនកាត់អាចមានផលប៉ះពាល់មកលើប្រព័ន្ធក្នុងស្រុក និងរួមវិភាគទានចំពោះវប្បធម៌សិទ្ធិមនុស្ស។

១៩. ព័ត៌មានសហគមន៍ និងសាធារណៈដ៏មានប្រសិទ្ធិភាពមានសារសំខាន់ចំពោះកេរ្ដិ៍ដំណែល និងត្រូវបង្កើតបានជាផ្នែកមួយនៃថវិកាស្នូល។ ការផ្សព្វផ្សាយដ៏មានប្រសិទ្ធភាពពាក់ព័ន្ធនឹង (ក) យុទ្ធសាស្រ្តមួយសកម្មមុន ដែលពុះពារកំណត់គោលដៅវិស័យផ្សេងៗរបស់ប្រជាជន (ខ) វិធីសាស្រ្តដ៏ទូលំទូលាយមួយ ដែលផ្ដោតមិនត្រឹមតែលើព្រះរាជអាជ្ញាប៉ុណ្ណោះទេ ប៉ុន្តែផ្ដោតលើគ្រប់ផ្នែកទាំងអស់ នៃកិច្ចដំណើរការជំនុំជម្រះដោយរាប់ទាំងសិទ្ធិទទួលបានការជំនុំជម្រះក្ដី ដោយយុត្តិធម៌ និងការការពារក្ដីដ៏មានប្រសិទ្ធភាព (គ) បណ្ដាញមួយ ដែលអាចផ្សព្វផ្សាយ

ព័ត៌មានដ៏សុក្រឹត្យយ៉ាងរហ័ស ដែលគ្របដណ្តប់លើភូមិសាស្ត្រដ៏ទូលំ-ទូលាយ (ឃ) ជាក់ស្តែង ការប្រាស្រ័យទាក់ទងគ្នាតាមមធ្យោបាយ២ យ៉ាង ដែលពាក់ព័ន្ធនឹងកិច្ចសន្ទនា និងឱកាសនានាសម្រាប់ផ្តល់ព័ត៌មាន ត្រឡប់មកវិញ។

២០. ភាពជាដៃគូជាមួយសង្គមស៊ីវិល ក្នុងស្រុកមានសារសំខាន់ ក្នុងការ-បង្កើនកេរ្តិ៍ដំណែលឲ្យបានជាអតិបរមា។ តុលាការកូនកាត់អាចដើរតួ-នាទី ដ៏សកម្មក្នុងការបញ្ជាក់ឲ្យច្បាស់ អំពីតួនាទីដ៏សំខាន់របស់សង្គម ស៊ីវិលក្នុងស្រុក។ ចំពោះហេតុផលនេះ តុលាការកូនកាត់ត្រូវពុះពារ ដើម្បីដាក់សង្គមស៊ីវិលក្នុងស្រុកឲ្យពាក់ព័ន្ធក្នុងការងាររបស់គេ។

២១. កិច្ចសហការដែលជោគជ័យ ដើម្បីកសាងសមត្ថភាពវិជ្ជាជីវៈគឺពិបាក នឹងសម្រេចបាន ហើយនឹងពឹងផ្អែកលើការលើកកម្ពស់ពីដំបូងគឺទំនាក់-ទំនងរវាងតួអង្គអន្តរជាតិ និងជាតិ ដែលនាំមកនូវលទ្ធផលនៃការផ្ទេរ ជំនាញ។ ចំណុចទាំងនេះមាន (ក) ចូលពាក់ព័ន្ធក្នុងផែនការកម្មគ្រប់-គ្រាន់ និងការវិភាគស៊ីជម្រៅលើបរិបទច្បាប់ជាតិ (ខ) មានដំណើរការ កំណត់អត្តសញ្ញាណហ្មត់ចត់ដើម្បីស្វែងរកបេក្ខជនជាតិ និងអន្តរជាតិ ក្នុងការចូលរួមក្នុងដំណើរការនេះ (ឬត្រូវឆ្លងកាត់ការត្រួតពិនិត្យបេក្ខជន ដែលមិនសមរម្យ) និង (គ) ចូលពាក់ព័ន្ធក្នុងកិច្ចពិគ្រោះយោបល់ក្នុង ដំណើរការទាំងមូល។

២២. សម្រាប់តួអង្គអន្តរជាតិ ដំណើរការក្នុងការជ្រើសរើសត្រូវកំណត់បេក្ខជន ទាំងឡាយ ដែលអាចប្រព្រឹត្តទៅដោយរលូន ក្នុងបរិយាកាសជាអន្តរ-ជាតិមួយ ហើយពួកគេត្រូវមានឆន្ទៈចាកចេញពីប្រព័ន្ធច្បាប់ផ្ទាល់របស់ គេ ប្រសិន បើចាំបាច់ និងមានឆន្ទៈរៀនសូត្រអំពីប្រព័ន្ធច្បាប់ក្នុងស្រុក ហើយពួកគេសមនឹងបំពេញការងារបែបស្ពានជាមួយដៃគូក្នុងស្រុក។

២៣. កិច្ចសន្យាការងាររបស់បុគ្គលិកអន្តរជាតិ យ៉ាងហោចណាស់ក៏ត្រូវមានរយៈពេល១ឆ្នាំដែរ និងត្រូវបន្តជាថ្មី ដោយផ្អែកលើការបំពេញការងាររបស់គេ។

២៤. តម្លាភាព និងភាពមិនលំអៀងត្រូវបានគេគោរព ក្នុងការជ្រើសរើសបុគ្គលិកណាមួយ។ លើសពីនេះទៀត សម្រាប់បុគ្គលិកអន្តរជាតិ ប្រព័ន្ធនៃគណនេយ្យភាពដូចជាក្រមសីលធម៌អាចមានសារសំខាន់ ជាពិសេសប្រសិនបើពួកគេមិនមែនស្ថិតក្រោមកម្មវត្ថុ នៃរចនាសម្ព័ន្ធវិន័យក្នុងស្រុក។

២៥. ជំរើសច្នៃប្រឌិតផ្សេងៗ ត្រូវបានប្រើប្រាស់ ដើម្បីបំពេញចន្លោះប្រហោងក្នុងលក្ខ័ណ្ឌនានានៃសេវាកម្មរវាងបុគ្គលិកអន្តរជាតិ និងជាតិ ដូចជាចំណាត់ថ្នាក់កន្លែងការងារជាជាងចំណាត់ថ្នាក់បុគ្គល ឬការដាក់ឲ្យអនុវត្តនូវរចនាសម្ព័ន្ធ សម្រាប់ជាការលើកទឹកចិត្ត។ ភាពចន្លោះប្រហោងហួសហេតុអាចបណ្តាលឲ្យមានការអាក់អន់ស្រពន់ចិត្ត និងរារាំងដល់កេរ្តិ៍ដំណែល។

២៦. ការផ្តួចផ្តើមគំនិតកេរ្តិ៍ដំណែលទាមទារការប្តេជ្ញាចិត្ត ផ្នែករដ្ឋបាលដ៏រឹងមាំ ហើយក៏អាចទាមទារឲ្យមានបុគ្គលិក ដែលមានទេពកោសល្យ ឬការបង្កើតក្រុមការងារ។

២៧. មានការព្រមព្រៀងគ្នាជាទូទៅមួយតាមបទពិសោធន៍ពីប្រទេសផ្សេងៗជាច្រើនថា កេរ្តិ៍ដំណែល បានជួយជ្រោមជ្រែងដល់មនុស្សជាច្រើនធ្វើការកន្លែងតែមួយ និងមានឱកាសធ្វើការក្នុងក្រុមចម្រុះ ឬជាក្រុម។ ទោះបីជាយ៉ាងណាក៏ដោយ នៅពេលដែលធ្វើអន្តរកម្មជាមួយដៃគូការងារផ្សេងៗ (ដៃគូជាតិ ឬអន្តរជាតិ) អាចផ្តល់នូវឱកាសដ៏មានតម្លៃ

សម្រាប់ការអភិវឌ្ឍន៍វិជ្ជាជីវៈ ហើយតាមបទពិសោធន៍បង្ហាញថា ភាគ-ច្រើន អន្តរកម្មបែបនោះគឺជាអន្តរកម្មពិសេស និងចាំបាច់ត្រូវគ្រប់គ្រងដោយប្រុងប្រយ័ត្ន ដើម្បីទទួលបាននូវផលប្រយោជន៍។ តួយ៉ាងដូចជាប្រសិន បើការប្រឹក្សាយោបល់បានធ្វើឡើង ដោយអន្តរជាតិត្រូវបានគេជឿជាក់នោះ ការប្រឹក្សានេះនឹងបង្កើតបានជាផ្នែកមួយ នៃបទពិពណ៌នាការងារ ហើយត្រូវបញ្ជាក់ឲ្យបានជាក់លាក់ក្នុងកិច្ចសន្យា ។

២៨. ដំបូងឡើយ ការផ្តោតការយកចិត្តទុកដាក់លើកម្មវិធីបណ្តុះបណ្តាលក្នុងតុលាការកូនកាត់ ជាបឋមគឺផ្តោតលើការបណ្តុះបណ្តាលសម្រាប់ *បុគ្គលិកជាតិ* មកដល់ពេលនេះ។ ការកសាងសមត្ថភាពក្នុងទម្រង់ នៃការបណ្តុះបណ្តាលត្រូវផ្អែកលើ *ការផ្លាស់ប្តូរយោបល់គ្នាទៅវិញទៅមក* ដើម្បីឲ្យមានប្រសិទ្ធិភាព។ ការតវ៉ាជាទូទៅនៅក្នុងតុលាការកូន-កាត់គឺជាការតវ៉ា ដែលខ្វះវិធីសាស្ត្រទាក់ទងគ្នារដឹក ចំពោះការបណ្តុះ-បណ្តាលទាំងថៅក្រមជាតិ និងអន្តរជាតិ។ មានកត្តាជាច្រើនដែលត្រូវបង្កើតបានជាផ្នែកមួយ នៃវិធីសាស្ត្រទាក់ទងគ្នានោះត្រូវបានគេគូស-បញ្ជាក់ខាងលើរួចហើយ។

២៩. ការអភិវឌ្ឍន៍វិជ្ជាជីវៈរបស់ចៅក្រមត្រូវបានលើកឡើង អំពីការពិនិត្យពិច័យពិសេស ដែលទាមទារឲ្យមានយុទ្ធសាស្ត្រ ដាច់ដោយឡែកពីគ្នា។ យុទ្ធសាស្ត្រមួយចំនួននៃបណ្តាយុទ្ធសាស្ត្រទាំងនេះ ក៏ត្រូវបានគេគូសបញ្ជាក់ផងដែរក្នុងលិខិតុបករណ៍នេះ។

៣០. គោលដៅនៃកេរ្តិ៍ដំណែលទូទៅ និងសម្រេចបានសម្រាប់តុលាការកូនកាត់ត្រូវតែបង្កើតសមត្ថភាព បច្ចេកទេសជាអចិន្ត្រៃយ៍ដើម្បីធ្វើការស៊ើបអង្កេត និងផ្តន្ទាទោសទម្រង់នៃឧក្រិដ្ឋកម្ម ដែលមានលក្ខណៈស្មុក-ស្មាញ និងបែបចាត់តាំង ដោយរាប់ទាំងឧក្រិដ្ឋសង្គ្រាម និងឧក្រិដ្ឋ-

កម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មដែលមានលក្ខណៈស្មុកស្មាញ។ ប្រភេទនៃឧក្រិដ្ឋកម្មទាំងនេះអាចបង្កើតបានជាបញ្ហាទោល និងរួមនៃវិធីសាស្ត្រពហុវិន័យ ទាមទារឲ្យមានការវិភាគ ការគ្រប់គ្រងសំណុំរឿង ការការពារសាក្សី ព័ត៌មានបច្ចេកវិទ្យា និងសហប្រតិបត្តិការជាអន្តរ-ជាតិ និងសមត្ថភាពអចិន្ត្រៃយ៍ ដើម្បីធ្វើការផ្តន្ទាទោសជនទាំងនោះ ជាពិសេស ទាក់ទងនឹងបរិបទក្រោយជម្លោះ។

៣១. មេធាវីការពារក្តីអាចផ្តល់នូវឱកាសនានា តែមួយគត់សម្រាប់កេរ្តិ៍ដំ-ណែល ដោយសារតែជាញឹកញាប់ក្រុមការពារក្តីពាក់ព័ន្ធជាមួយតួអង្គជាតិច្រើនជាងផ្នែកផ្សេងៗ របស់តុលាការ។ មេធាវីការពារក្តីឯកជនអាចមានការលើកទឹកចិត្តយ៉ាងខ្លាំង ដើម្បីអនុវត្តតាម និងរៀនសូត្រជំនាញថ្មីៗ ដែលពាក់ព័ន្ធជានិច្ចក្នុងការងាររបស់គេ។ ទោះបីជាយ៉ាង-ណាក៏ដោយ ការផ្តល់កិច្ចគាំពារស្ថាប័នគ្រប់គ្រាន់សម្រាប់មេធាវីការពារក្តីនៅតែជាបញ្ហាប្រឈម ហើយនៅពេលគំរូដែលនឹងនាំមកនូវជោគ-ជ័យត្រូវបានអភិវឌ្ឍឡើង នេះគឺជាវិស័យមួយ ស្ថិតក្រោមគំរូវការផត-ឈប់ឈរ នៃការយកចិត្តទុកដាក់។

៣២. មានវិស័យផ្សេងៗជាច្រើនទៀត ដែលការផ្ទេរជំនាញអាចនាំមកនូវផលប្រយោជន៍ដល់កេរ្តិ៍ដំណែល ដ៏គួរឲ្យកត់សំគាល់ ជារួមមានការស៊ើបអង្កេត ជំនាញភាសា និងមធ្យោបាយសម្រួលក្នុងការបកប្រែ ការគ្រប់គ្រងផ្នែកតុលាការ ការការពារ និងគាំពារសាក្សី ចិត្តសាស្ត្រ កោសលវិច័យ បុគ្គលិក លទ្ធកម្ម របាយការណ៍ផ្នែកច្បាប់ ព័ត៌មានបច្ចេកវិទ្យា ការងារសិទ្ធិមនុស្ស ព័ត៌មានសាធារណៈ និងវិជ្ជាជីវៈផ្នែកព័ត៌មានក្នុងស្រុក និងការគ្រប់គ្រងសំណង់។ ចំពោះកេរ្តិ៍ដំណែលទាំងអស់នេះ គេមានលទ្ធភាពបង្កើតនូវកម្មវិធីកេរ្តិ៍ដំណែលទាំងឡាយ

ដែលនឹងអភិវឌ្ឍសមត្ថភាពក្នុងស្រុក ឬដោយមានផែនការគ្រប់គ្រាន់ ហើយនៅជាមួយគ្នានេះអាចប្រឹងប្រែង ដើម្បីបំពេញបាននូវសេចក្ដី-ត្រូវការរបស់សាលាក្ដី និងប្រព័ន្ធយុត្តិធម៌ដ៏ទូលំទូលាយ។

៣៣. កម្មវិធីកសាងសមត្ថភាព ដែលត្រូវបានបង្កើតឡើងដោយតុលាការកូនកាត់នោះ ត្រូវផ្សារភ្ជាប់ដោយប្រយ័ត្នប្រយែងជាមួយនឹងការផ្ដួច-ផ្ដើមគំនិត ដែលអាចកើតមានក្នុងរង្វង់នៃប្រព័ន្ធក្នុងស្រុក។

៣៤. រូបវន្តកេរ្ដិ៍ដំណែល (ឧ. អគារតុលាការ) អាចមានសារសំខាន់ ជាពិសេសទស្សនៈវិស័យជានិមិត្តរូប អាចចោទជាសំណួរដ៏ស្មុកស្មាញអំពីភាព-ម្ចាស់ការ ហើយត្រូវពិចារណាដោយប្រយ័ត្នប្រយែង និងទាមទារឲ្យមានការពិគ្រោះយោបល់។ គោលនយោបាយដ៏ច្បាស់លាស់មួយត្រូវតាក់តែងឡើងតាំងពីដំបូង ដោយមានទស្សនៈជួយសម្របសម្រួលបណ្ណាសារកេរ្ដិ៍ដំណែលតុលាការ និងសម្ភារៈផ្សេងៗទៀត ឧទាហរណ៍តើឯកសារណាខ្លះ ដែលត្រូវរក្សាទុកជាអចិន្ត្រៃយ៍។

៣៥. ការរៀបចំឲ្យមានប្រសិទ្ធភាពផ្នែកកេរ្ដិ៍ដំណែល និងកំណែទម្រង់ ដែលជោគជ័យអាចាត់ទុកជាបរិយាកាសនយោបាយមួយ ដែលអំណោយផលដល់កំណែទម្រង់ច្បាប់។ បញ្ហានេះក៏ចាត់ទុកជាគោលបំណងតែមួយ នៃរបៀបវារៈអន្តរជាតិ និងជាតិ ដើម្បីសម្រេចបាននូវកំណែទម្រង់ពិតប្រាកដនានា។ ដោយសារតែ បញ្ហានេះនៅតែជាវិស័យដ៏ប្រឈមមួយ ការរួមចំណែកចំពោះកំណែទម្រង់ច្បាប់ អាចជាកេរ្ដិ៍-ដំណែលមួយដ៏មានសារសំខាន់ ជាពិសេស ប្រសិនបើ កំណែទម្រង់នេះនាំមកនូវប្រព័ន្ធច្បាប់ដ៏រឹងមាំមួយ ដែលអ្នកវិជ្ជាជីវៈផ្នែកច្បាប់ទទួលរងនូវសម្ពាធពីខាងក្រៅតិចតួច។ ចំពោះបញ្ហានេះ ក្របខ័ណ្ឌច្បាប់ដ៏

ច្បាស់លាស់ និងរឹងមាំមួយសម្រាប់ស្ថាប័នកូនកាត់ដោយផ្ទាល់មានសារសំខាន់ក្រៃលែង។

៣៦. ការអនុវត្តន៍លក្ខ័ន្តិកៈទីក្រុងរ៉ូម នៃតុលាការព្រហ្មទណ្ឌអន្តរជាតិអាចផ្តល់នូវឱកាសនានាសម្រាប់កិច្ចប្រឹងប្រែងរួមគ្នា ដើម្បីពិនិត្យឡើងវិញនូវច្បាប់មានស្រាប់។ ម្យ៉ាងវិញទៀត ផលប៉ះពាល់ស្តីពីកំណែទម្រង់ច្បាប់អាចមានវិសាលភាពធំធេញ ដែលមានវេទិកាជាក់លាក់មួយ សម្រាប់តួទាំងអង្គជាតិ និងអន្តរជាតិជួបប្រជុំ និងពិភាក្សាគ្នាអំពីកំណែទម្រង់នានា។

៣៧. ផលប៉ះពាល់ នៃករណីយុត្តិសាស្ត្រនឹងមិនត្រឹមតែពឹងផ្អែកលើគុណភាពរបស់ចៅក្រមប៉ុណ្ណោះទេ ក៏ប៉ុន្តែពឹងផ្អែកលើតួនាទីករណីយុត្តិសាស្ត្រក្នុងបរិបទច្បាប់ជាក់លាក់ណាមួយ។ ការបោះពុម្ពផ្សាយ ការផ្សព្វផ្សាយសាលក្រមជាភាសា ក្នុងស្រុកគឺមានសារសំខាន់ សម្រាប់ផលប៉ះពាល់លើកេរ្តិ៍ដំណែល និងជាបន្តបន្ទាប់នឹងក្លាយជាការលើកទឹកចិត្តឲ្យមានគុណភាព។

៣៨. ចំណុចខ្លឹមអំពីកេរ្តិ៍ដំណែលគួរតែជាទស្សនទាន នៃនិរន្តរភាព វិធីបង្កើនឲ្យបានជាអតិបរមា នូវអន្តរាគមន៍ជាអន្តរជាតិ ដែលជាលទ្ធផលនៃមហាឧក្រិដ្ឋកម្ម និងការរួមវិភាគទានជាអចិន្ត្រៃយ៍ដល់សមត្ថភាពរបស់ប្រទេស ដើម្បីដោះស្រាយបញ្ហាឧក្រិដ្ឋកម្មទាំងឡាយជាប្រព័ន្ធ។

ISBN 978-92-1-154182-3